ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ឌុច (ប្រធានមន្ទីរស_២១)

◆ សុខ (និរសារបស់សមមិត្តឌុច)

លេខ៦ ខែមិថុនា ឆ្នាំ២០០០

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦ ខែមិថុនា ឆ្នាំ២០០០

## មាតិកា


- សំបុត្រៈ ព្រះគម្ពីរ........................................................ ១

### ផ្នែកឯកសារ

- បក្ខជន........................................................................ ២
- ជួបជាមួយសិស្ស និងមិត្តភក្តិជិតនិត របស់សមមិត្ត ឌុច........... ៤
- ប្រវត្តិរូប ដួន ប្រាសិទ្ធ...................................................... ៨
- កុមារ សឿ ពីតំបន់៣១មកគុកទួលស្លែង.......................... ១២
- បញ្ជីរាយនាមញាតិវង្សដែលជាប់ឃុំឃាំងនៅមន្ទីរស-២១....... ១៤
- ឯកសារសន្តិបាលមន្ទីរស-២១ ........................................ ១៦
- ភោគ ឆាយ មុនពេលក្លាយទៅជាអ្នកទោស...................... ១៩
- ការរៀបចំឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍........... ២២

### ផ្នែកប្រវត្តិសាស្ត្រ

- សម្លេងពីមន្ទីរស-២១ ..................................................... ២៦
- ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ.............................. ៣២
- គ្រោះថ្នាក់នៃអព្យាក្រឹតភាព (ភាគបញ្ចប់) ........................ ៣៤

### ផ្នែកច្បាប់

- គំរូមួយនៃភ័ស្តុតាងឯកសារ.............................................. ៤០
- ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ .................................................. ៤៣
- លក្ខខណ្ឌនៃភ័ស្តុតាង........................................................ ៤៦

### វេទិកាពិភាក្សាជាសាធារណៈ

- វត្ថុអស្ចារ្យពីរប្រភេទ......................................................... ៥០
- តើអ្វីទៅជាខ្មែរក្រហម....................................................... ៥៦

### ធំព័រស្រាវជ្រាវរកគ្រួសារ

- សុបិនអាក្រក់នៅតែមិនទាន់រលត់........................................ ៥៨
- ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន...........គ្របក្រោយ




សមមិត្ត ហី



សមមិត្ត ឌុច



សមមិត្ត សុខ




**វាគ្មិនលេខនេះៈ** ចាយ៉ា រ៉ាមជី, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ហ្វូលីយ៉ូ ហៀលជ្រេស, គ្រេក អ៊ិចឆេសាន់, ហេឡែន ហ្ការីស, ដេវីត ឆេនដល័រ, រ៉នី យិមស៊ុត, យែនតុនក្លែមម័រ, ស៊ីវ៉ែ ហេឌ័រ, ឆាំង សុង **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រៈ*

# ព្រះគម្ពីរ

*នៅក្នុងព្រះគម្ពីរបរិសុទ្ធសញ្ញាចាស់និងសញ្ញាថ្មីនៃគ្រិស្តសាសនា បានកត់ត្រានូវបន្ទូលរបស់ព្រះនៅក្នុងសារបានលោកុប្បត្តិ ទំព័រ១៣ ជំពូក៩ៈ៥ថា «រីឯជីវិតមនុស្សវិញ បើអ្នកណាយកជីវិតគេ នោះអញនឹងទារឈាមដែលជាជីវិតរបស់អ្នកនោះជាមិនខាន អញនឹងទារឈាមអ្នកនោះ ដោយសារអស់ទាំងសត្វ ហើយដោយសារដៃរបស់មនុស្ស គឺដោយសារដៃរបស់បងប្អូននៃអ្នកដែលស្លាប់នោះផង ។ អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ ដ្បិតព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់» ។ ប្រសិនបើ ឌុច ពិតជាបានអានព្រះគម្ពីរសាសនាគ្រិស្ត ហើយពិតជាបានជឿព្រះ និងពិតជាបានលាងបាបដោយសុទ្ធចិត្តតាមពិធីបុណ្យជ្រមុជទឹកមែននោះ ឌុច ត្រូវតែបានយល់ច្បាស់ពីបន្ទូលរបស់ព្រះដែលបានកត់ត្រាទុកខាងលើ ។ ព្រះបានធ្វើការបែងចែកច្បាស់លាស់ណាស់អំពីអ្វីដែលជា «អំពើបាប» និងអំពីអ្វីដែលជា «ការទទួលខុសត្រូវ»ចំពោះមនុស្សដទៃទៀត ។*

*ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ហើយដែលជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់នូវជីវិតអ្នកទោសយ៉ាងហោចណាស់ជាង១ម៉ឺននាក់ កំពុងទាញហេតុផលដោយយកសាសនាគ្រិស្តមកបិទបាំងនូវការទទួលខុសត្រូវរបស់ខ្លួន ។ ឌុច ក៏កំពុងបានប្រើប្រាស់បន្ទូលរបស់ព្រះនៅក្នុងផ្លូវខុស ។ ព្រះពិតជាប្រោស ឌុច ឲ្យរួចផុតពី «បាប» ប៉ុន្តែព្រះនឹងទាមទារយកមកវិញនូវឈាមដែល ឌុច បានយកមកពីជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំសូមចង្អុលទៅឯកសារមួយចំនួនតូចយ៉ាងសង្ខេបជាទីបំផុតក្នុងចំណោមឯកសារជាង៤សែនទំព័រ ដែលទាក់ទងនឹង ឌុច ដូចខាងក្រោមនេះ÷*




*ក្នុងឯកសារ I១០៧៧៣ ទាក់ទងទៅនឹងអ្នកទោសឈ្មោះ មុត ហេង ចុះថ្ងៃទី ២១ ខែ៦ ឆ្នាំ១៩៧៦ ឌុច បានបញ្ជាឲ្យកម្មាភិបាលថ្នាក់ក្រោមរបស់ខ្លួនចាប់ទាំងឪពុក ទាំងជីតា របស់ជនរងគ្រោះយកទៅវាយសួរចម្លើយ ។ ក្នុងឯកសារប្រអប់លេខ៥ ទាក់ទងទៅនឹងជនរងគ្រោះឈ្មោះ យ៉ា ចុះថ្ងៃទី១ ខែ១០ ឆ្នាំ១៩៧៦ ឌុច បានបញ្ជាប្រធានសួរចម្លើយរបស់ខ្លួនឈ្មោះ សមមិត្ត ប៉ុន ថាៈ «ជាមួយល្បែងយ៉ានេះសមមិត្តអាចប្រើធម៌ក្តៅបានខ្លាំងហើយយូរ ទោះបីភ្លាត់ទៅដល់ស្លាប់ក៏សមមិត្តមិនឆ្គងនឹងអង្គការវិន័យ ។ អង្គការសម្រេចថា អាម្សៀ យ៉ា នេះ បើវានៅតែត្រេងត្រាងលាក់ខ្សែក្បត់និងសកម្មភាពក្បត់វាតទៅទៀតទេអង្គការសម្រេចឲ្យវាយចោលទៅ» ។ ក្នុងឯកសារ G១៩៦១ ចុះថ្ងៃទី៣០ ខែ៥ ឆ្នាំ១៩៧៨ ឌុច បានបញ្ជាឲ្យកូនចៅរបស់ខ្លួនសម្លាប់ កុមារា និងកុមារីព្រមទាំងប្រជាជនដទៃទៀតសរុបចំនួន១៧នាក់ ។*

*ករណីសង្ខេបដ៏ខ្លីខាងលើនេះ ខ្ញុំសូមទុកជូនតុលាការដើម្បីទាញហេតុផលតាមផ្លូវច្បាប់លើទំហំនិងប្រភេទនៃពិរុទ្ធភាពថាតើ ឌុច នឹងត្រូវទទួលទោសបែបណា ហើយយោងតាមច្បាប់អ្វីខ្លះ ។ ខ្ញុំពុំទាន់បានរៀបរាប់ដល់ការសម្លាប់ជនជាតិភាគតិច ឬបរទេសនៅឡើយទេ ។ ឯកសារដែលទាក់ទងទៅនឹងអំពើព្រៃផ្សៃរបស់ ឌុច មានស្ទើរពេញមួយបន្ទប់ថ្នាក់រៀនសិស្សសាលាឯណោះ ។ គ្មានអ្វីដែល ឌុច អាចយកមកបិទបាំងបានឡើយ សូម្បីតែព្រះគម្ពីរបរិសុទ្ធ ។ ព្រះគម្ពីរបរិសុទ្ធគឺជាបន្ទូលរបស់ព្រះ ហើយ ឌុច ដែលជាមនុស្សមានបាបគ្មានអំណាចអ្វីមកកែប្រែបន្ទូលរបស់ព្រះ ឬយកបន្ទូលរបស់ព្រះមកលុបបំបាត់អំពើឧក្រិដ្ឋរបស់ខ្លួនបានឡើយ ។ ព្រះពិតជាបានដឹងនូវអំពើទាំងអស់របស់ ឌុច ហើយព្រះពិតជាមិនយក ឌុច នៅកាន់ឋានសួគ៌ជាមួយព្រះអង្គដរាបណា ឌុច មិនទាន់ត្រូវបានវិនិច្ឆ័យទោសនិងដាក់ទណ្ឌកម្មដោយតុលាការឯករាជ្យមួយ ។*

**ឆាំង យុ**



# អំពីបក្ខជន

## (ឯកសារទង់បដិវត្តន៍ លេខ៧ ខែកក្កដា ឆ្នាំ១៩៧៦ ជំពូកទី១)

◆◆◆ *សំណូមពរៈ រៀនជំពូកទី១ នេះគឺៈ*

*១) ដើម្បីក្តាប់ឲ្យជាប់នូវគោលការណ៍ស្តីអំពីបក្ខជនពិសេសអំពីការពង្រីកបក្ខជន និងភារកិច្ចបក្ខជន ។*

*២) ត្រូវជ្រួតជ្រាបឲ្យជ្រៅជ្រះថែមទៀតអំពីវិន័យរបស់បក្សចំពោះគ្រប់បក្ខជន ។*

*ក) នៅក្នុងជំពូកទី១នេះមាន៤មាត្រា ។ មាត្រាទី១ ទី២ និងទី៣ ជាលក្ខការណ៍ដើម្បីពង្រីកបក្ខជន ពង្រឹងបក្ខជន ។ ត្រូវឈរលើគោលការណ៍នេះដាច់ខាត ត្រូវបំពាក់បំប៉នគោលការណ៍នេះដាច់ខាត ។ ត្រូវអប់រំបក្ខជនឲ្យក្តាប់ជាប់គោលការណ៍នេះ ។*

*កន្លងមកការបញ្ចូលបក្សភាគច្រើនគឺត្រឹមត្រូវ ។ តែមួយចំនួនច្រើនគួរសមដែរគឺបញ្ចូលខុសពិសេសនៅឆ្នាំ១៩៧០-៧១ ។ ដូច្នេះសមាសភាពឱកាសនិយមវាចូលបានច្រើន ។ តែបក្សបិទទ្វារសម្រិតសម្រាំងបានជាអតិបរមា ។ ដូច្នេះតទៅមុខទៀត មុននឹងសម្រេចបញ្ចូលបក្សត្រូវបើកលក្ខន្តិកៈមើល ។*

*នៅក្នុងនេះតាមពិសោធន៍ត្រូវក្តាប់ប្រវត្តិរូបឲ្យបាន ។ បើប្រវត្តិរូបមិនច្បាស់ទោះជាល្អក៏ដោយក៏កុំអាលបញ្ចូល ។ ប្រយ័ត្នពួកសេ.អ៊ី.អា វាជ្រៀតចូល ។ សេ.អ៊ី.អា វាវាយបដិវត្តន៍ដោយបញ្ចូលថ្នាំតាមសរសៃឈាមរបស់បដិវត្តន៍ ។ ដូច្នេះត្រូវក្តាប់ប្រវត្តិរូបឲ្យច្បាស់ ។*

*ខ) អំពីវិន័យរបស់បក្សៈ មាត្រា៤ៈ*

*ចំពោះវិន័យរបស់បក្សចង់សង្កត់លើចំណុចខ្លះៈ*

*១) ត្រូវមានទស្សនៈច្បាស់លាស់ចំពោះវិន័យរបស់បក្ស ។ ក្តាប់វិន័យ យល់សារៈសំខាន់របស់វិន័យ ការចាំបាច់របស់វិន័យ ។ វិន័យរបស់បក្សធ្វើឡើងដើម្បីសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្ស ។ ទស្សនៈចំពោះវិស័យនេះកន្លងមកនៅស្រាល ។*

### ***ហេតុអ្វីបានត្រូវមានវិន័យ? សារៈសំខាន់នៃវិន័យយ៉ាងណា?***

*ទាល់តែមានវិន័យបានមានសាមគ្គីភាព-ឯកភាពផ្ទៃក្នុងបក្សរឹង ។ វិន័យមិនមែនឈរលើបុគ្គល វិន័យមិនមែនឈរលើបុគ្គលនេះ បុគ្គលនោះ គណៈកម្មាធិការនេះ គណៈកម្មាធិការនោះទេ គឺឈរលើមាគ៌ា ។*

*យើងចង់បំផុសមហាជនឲ្យកាន់តែយល់មាគ៌ា យល់សតិអារម្មណ៍ យល់លក្ខការណ៍ចាត់តាំងរបស់បក្ស ដើម្បីមហាជន*

មានកម្លាំងជួយកសាងបក្ស ពង្រឹងពង្រីកបក្ស ។ ឲ្យគេយល់វិន័យរបស់បក្ស ។ យល់សម្រាប់ខ្លួនគេ យល់សម្រាប់វិនិច្ឆ័យបក្ខជនវិនិច្ឆ័យកម្មាភិបាល ។ អនុវត្តន៍សតិអារម្មណ៍ខុស គេមើលឃើញ ។ អនុវត្តន៍ចាត់តាំងខុសគេមើលឃើញ ពីព្រោះមាគ៌ាតែមួយ ។ ដូច្នេះនាំឲ្យបក្សយើងរឹង ។ ពីព្រោះកន្លងមកមានធ្ងន់មានស្រាល ។ បើថ្នាក់លើធ្វើខុសវិន័យ ជួនណាមហាជនឃើញដែរ តែមិនហ៊ាននិយាយ ។ ជួនណាមហាជនមិនឃើញ មកពីមិនយល់អំពីវិន័យរបស់បក្ស ។ ត្រូវអប់រំជាបន្តបន្ទាប់ ។

(២) ត្រូវមានការអនុវត្តវិន័យដោយហ្មត់ចត់ដើម្បីឲ្យបក្សខ្លាំងសាមគ្គីភាព-ឯកភាពរឹងប៉ឹង ។ គោលការណ៍របស់បក្សគឺទិតៀន-ស្វ័យទិតៀនដើម្បីកសាង ។ នេះជាមូលដ្ឋាន ។ ប៉ុន្តែបើកសាងជាបន្តបន្ទាប់ហើយមិនកែប្រែ មិនចម្រើន ត្រូវតែអនុវត្តវិន័យបានមហាជនមានជំនឿហើយបក្សរឹង បានយើងលម្អគោលការណ៍របស់បក្ស លម្អមាគ៌ារបស់បក្សបាន ។

ប៉ុន្តែត្រូវប្រយ័ត្នប្រយែង«ឆ្វេង»ស្តាំ ។ មកដល់ថ្ងៃនេះយើងច្រើនធូររលុងក្នុងការអនុវត្តវិន័យ ។ ក្នុងន័យនេះយើងស្តាំ ។តែប្រយ័ត្នឆ្វេង គឺអនុវត្តវិន័យទទឹងទទែងមិនពិនិត្យពិច័យហ្មត់ចត់ ។

ទន្ទឹមនេះ ក្នុងការអនុវត្តវិន័យត្រូវមានវិធានការហ្មត់ចត់ ។ មុននឹងសម្រេចវិន័យមួយៗត្រូវតស៊ូមួយរយៈកាល កសាងមួយរយៈកាល ។ បើសម្រេចវិន័យត្រូវមានវិធានការហ្មត់ចត់ការពារប្រតិកម្មប្រឆាំង ។

អនុវត្តវិន័យរបស់បក្សហ្មត់ចត់មិនមែនធ្វើឲ្យបក្សខ្សោយទេ ។ គឺធ្វើឲ្យបក្សខ្លាំង ។ បើអនុវត្តវិន័យរបស់បក្សបានត្រឹមត្រូវបំផុសមហាជនក៏បានលឿនទៀត ។

# មាត្រាស្តីអំពីការអនុវត្តន៍ច្បាប់នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

**(ប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦)**


ខៀវ សំផន

## ជំពូកទី៦

### អំពីអង្គការអនុវត្តច្បាប់

**មាត្រា៨:**

រដ្ឋាភិបាលជាអង្គការមានភារកិច្ចអនុវត្តច្បាប់និងអនុវត្តមាគ៌ានយោបាយទាំងអស់របស់សភាតំណាងប្រជាជនកម្ពុជា ។

រដ្ឋាភិបាលត្រូវជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជាហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខសភាតំណាងប្រជាជនកម្ពុជាក្នុងកិច្ចដំណើរការទាំងអស់របស់ខ្លួនទាំងក្នុងប្រទេសទាំងក្រៅប្រទេស ។


អៀង ធីរិទ្ធ

## ជំពូកទី៧

### អំពីតុលាការ

**មាត្រា៩:**

តុលាការជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន ។ តុលាការគ្រប់ជាន់ថ្នាក់ត្រូវសភាតំណាងប្រជាជន ជ្រើសរើស និងតែងតាំង ។

**មាត្រា១០:**

ប្រភេទល្មើសច្បាប់រដ្ឋប្រជាជនមានដូតទៅៈ

- ចំពោះប្រភេទសកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ហើយគ្រោះថ្នាក់ដល់រដ្ឋ ប្រជាជន ត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត ។

- ចំពោះប្រភេទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន ។ ◆◆◆


ប៉ុល ពត


នួន ជា


អៀង សារី

# ជួបជាមួយសិស្ស និងមិត្តភក្តិជំនិត របស់ កាំង ហ្គិចអៀវ ហៅ សមមិត្ត ឌុច នៅខេត្តកំពង់ធំ

**ផាត កុសល និង ពៅ ដារ៉ា**

*(គីម សួរ ជាអតីតសិស្សរបស់ ឌុច នៅកំពង់ធំ)*

*(លាម សារុន ជាអតីតមិត្តជិតស្និទ្ធរបស់ ឌុច កាលនៅ វត្តខណ្ឌលោម ក្រុងភ្នំពេញ)*

**កុសលៈ** លោកពូស្គាល់ ឌុច ដែលមានរូបដូចក្នុងកាសែតដែលលោកពូកំពុងអាននេះមែនទេ?

**គីម សួរៈ** បាទ! មានភាពស្និទ្ធស្នាលស្គាល់គ្នាតាំងពីនៅរៀន ខ្ញុំអាចបំភ្លឺបន្ថែមបាន ប្រសិនជាថា ឌុច ហ្នឹងមានឈ្មោះដើមកំណើតជា កាំង ហ្គិចអៀវ ។


គីម សួរ

**កុសលៈ** បាទ! ខ្ញុំជម្រាបថាប្រវត្តិវិទូល្បីៗបានបញ្ជាក់ថា ឌុច មានឈ្មោះដើម កាំង ហ្គិចអៀវ ។ រឿងនេះគឺច្បាស់មែនទែន សូម្បី ឌុច ខ្លួនឯងក៏ទទួលស្គាល់ដែរ ហើយមានឯកសារច្រើនទាក់ទងនឹង ឌុច ។

**គីម សួរៈ** ខ្ញុំសូមជម្រាបថាខ្ញុំធ្លាប់រៀននៅស្គន់ រៀននៅថ្នាក់ទី៣ (កម្មវិធីសិក្សាសង្គមចាស់) ។ ឌុច ហ្នឹងជាគ្រូបង្រៀន រូបវិទ្យា គីមី និងគណិតវិទ្យា ។

**លាម សារុនៈ** ក៏ប៉ុន្តែរូបវិទ្យា-គីមី ក៏បង្រៀន ខ្មែរក៏បង្រៀនដែរ ។

**គីម សួរៈ** ខ្ញុំបាទធ្លាប់រៀននៅជាមួយគាត់នៅវិទ្យាល័យស្គន់ប្រហែលជាឆ្នាំ១៩៦៤-៦៥ ។ ពេលនោះសកម្មភាពរបស់គាត់គឺខុសប្លែកពីសាស្ត្រាចារ្យដទៃទៀត ។

**កុសលៈ** ប្លែកយ៉ាងម៉េចទៅ?

**គីម សួរៈ** គឺគាត់ចូលចិត្តជាមួយកូនសិស្ស បាទ៎! ស្និទ្ធស្នាលជាមួយកូនសិស្សណាស់ហើយកូនសិស្សហាក់ដូចជាស្រលាញ់គាត់ហ្នឹងតែម្តង ។ ហើយពេលហ្នឹងគឺថាសាស្ត្រាចារ្យខ្លះគេធ្វើបុកធំធ្វើឲ្យកូនសិស្សខ្លាចដល់គ្រូ ។ កាំង ហ្គិចអៀវ នេះគាត់មិនធ្វើឲ្យកូនសិស្សខ្លាចទេ គាត់ធ្វើឲ្យកូនសិស្សស្រលាញ់ រហូតដល់កូនសិស្សឱប ឬក៏ចាប់លើកបោះអីចឹង ភាគច្រើនគឺកូនសិស្សស្រលាញ់គាត់ណាស់ ។

**កុសលៈ** តាមរយៈសកម្មភាពអ្វីខ្លះក្នុងសាលាដែលគាត់ធ្វើឲ្យសិស្សស្រលាញ់ម្ល៉េះ?

**គីម សួរៈ** សកម្មភាពហ្នឹងតាមខ្ញុំដឹង... កាលណោះខ្ញុំនៅវត្តស្គន់ (វត្តអនុគុណ) កាលដើមឡើយមិនដឹងយ៉ាងម៉េចទេ នៅតាមវត្តមានបាចត្រាក់ ត្រាក់ដាក់នៅតាមជណ្តើរលោក (ព្រះសង្ឃ) ខ្ញុំមិនដឹងថា គ្រូហ្នឹងប្រើសិស្សដាក់ ឬ មិនមែនក៏ខ្ញុំអត់ដឹងដែរណា៎ ពេលនោះគឺមានត្រាក់ចាប់មានសកម្មភាពខ្មែរក្រហម បានមួយឆ្នាំខ្ញុំបែកពីគាត់ទៅ ។

**ដារ៉ាៈ** តើពេលនោះគាត់មានគ្រួសារ (ប្រពន្ធកូន) ឬនៅ?

**គីម សួរៈ** អត់មានទេ ។

**សារុនៈ** ដល់ជាប់គុកចេញពីគុកវិញ រហូតដល់៧៣ចូលព្រៃ

ចុង៧៣ចូលព្រៃក៏អត់ទាន់មានប្រពន្ធដែរ ។

**កុសលៈ** ឌុច កើតឆ្នាំអីដែរ?

**សារុនៈ** ឌុច កើតឆ្នាំមមី ឆ្នាំ១៩៤២ ប៉ុន្តែក្នុងកាតរបស់ ឌុច ដាក់អាយុបន្ថយមួយឆ្នាំ ។

**កុសលៈ** ហេតុអីបានជាពូដឹងថាកើតឆ្នាំមមី?

**សារុនៈ** បានជាដឹងព្រោះថាខ្ញុំចេះធ្វើគ្រូទាយ កាលខ្ញុំបួសនៅជាសង្ឃនៅវត្តខណ្ឌលោម ហើយ អាគៀវ(ឌុច) វាឲ្យខ្ញុំទាយឲ្យ ។ ឈ្មោះក្រៅរបស់ កាំង ហ្គិចអៀវ គឺ គៀវ ។

**ដារ៉ាៈ** អ៊ីចឹងធ្លាប់ជាប់គុកដឹង?

**សារុនៈ** ជាប់គុក៦៧ដល់៧០ ។ នៅឆ្នាំ១៩៧០ដោយរបប លន់ ណុល ធ្វើរដ្ឋប្រហារគេត្រូវលើកលែងទោសទាំងអស់ ចេញពីគុកមក អា «គៀវ» ទៅនៅកុដិលេខ៣វត្តខណ្ឌលោមដដែល ។

**ដារ៉ាៈ** មុនពេលមកនៅកុដិលេខ៣ ធ្លាប់នៅវត្តហ្នឹងប៉ុន្មានឆ្នាំដែរ?

**សារុនៈ** ពី៦១ដល់ទៅ៦៤ ដែលចេញទៅធ្វើគ្រូគឺ៣ឆ្នាំ ដល់ពី៧០មក៧៣ គឺ៣ឆ្នាំទៀត ។

**ដារ៉ាៈ** ហើយកាលពីនៅជាមួយគ្នា ដែលតាមលោកពូសម្គាល់ចរិតគាត់យ៉ាងម៉េចដែរ?

**សារុនៈ** បើមើលចរិត ចរិតរបៀបមនុស្សមិនបានការទេ ប៉ផ្ដេស ប៉ផ្ដោះ ចុំនិយាយលេងសើច ហើយអត់កាចទេ ។

**កុសលៈ** អត់កាចទេ?

**សារុនៈ** អត់កាចទេ ហើយបើទស្សនៈបដិវត្តន៍ គឺនុំនៅកុដិហ្នឹងនរណាក៏ដឹងដែរថាវា (កាំង ហ្គិចអៀវ) ជាមេខ្មែរក្រហម ហើយខ្ញុំនិយាយមិនលាក់ទេ កាលជំនាន់នោះគេថាខ្ញុំខ្មែរក្រហម ។ គៀវ ជិតនិតជាមួយ ខៀវ សំផន ប៉ុន្តែតាមពិតវាជិតនិតជាមួយនឹង សុខ ធួក ហៅ វ៉ន វ៉េត ជាង ។ សុខ ធួក ហ្នឹងបើតាមខ្ញុំដឹងធ្លាប់ធ្វើមេគយ ។ ហើយអ៊ីចឹងទៅវាបបួលខ្ញុំទៅ ខ្ញុំថាអត់ទេ អញមិនទៅព្រៃជាមួយឯងទេ ។ (ខ្ញុំនៅជាសង្ឃរហូតដល់អាពតជម្លៀសខ្ញុំឆ្នាំ៧៦) ខ្ញុំដឹងទាំងអស់ នៅកំពង់ធំ វាបោះត្រាក់អីក៏ខ្ញុំដឹង ព្រោះនៅកំពង់ធំវាមានប៉ុន្មាននាក់ដែរ «ក្រុមហ៊ុន» របស់វា សកម្មភាពខ្មែរក្រហមអ៊ីនោះក៏ខ្ញុំដឹង ។ ខ្ញុំធ្លាប់ព្រមានវានៅនឹងកុដិជាមួយខ្ញុំ ។ លោកគ្រូខ្ញុំនិងលោកគ្រូវាហ្នឹងឯង គាត់ជិតនិតនឹងសម្តេចព្រះសង្ឃរាជ ជួន ណាត ព្រមានវាថា «ហ្អែងកុំធ្វើនយោបាយ» ។ វាឆ្លើយថា «លោកតាធ្វើនយោបាយដើម្បីរំដោះរាស្ត្រ ដើម្បីជួយរាស្ត្រ» វាថាអ៊ីចឹង វានិយាយសើចអ៊ីចឹង ហើយលោកតាហ្នឹង គាត់គ្រាន់តែស្តីឲ្យប៉ុណ្ណឹង ។ ហើយបើចរិតវា គឺបើវាខឹងអត់ដែលមានតនឹងអ្នកណាទេ ។ គេប្រមាថវា គេជេរវាយ៉ាងម៉េចក៏វាអត់ត ចិត្តធ្ងន់ ។ រួចបើដឹងតែគេកាទីកាទើរកវ៉ៃ វាបែរទៅលួងលោមទៅវិញ ។ វាមិនជាបើទេវាមនុស្សនោះតែវ៉ៃទេ ។ ហើយ (សារុន ចង្អុលទៅរូប ឌុច នៅក្នុងទំព័រកាសែត) រូបនេះឯងមើលក៏មិនដូចជាប្លែកទេ ខ្ញុំឃើញតែមុខដដែល ហើយមាំពោះវា វាទាញបញ្ចូលខ្មែរក្រហមទាំងអស់ ។ ប្អូនវាបង្កើត៣នាក់ ទាញឲ្យធ្វើខ្មែរក្រហមទៀត ។ ពេលដាច់ឆ្នាំ៧៥មក វាបញ្ជាកូនចៅវាឲ្យមករកខ្ញុំដើម្បីជួយខ្ញុំកុំឲ្យស្លាប់...ហើយដៃគូរបស់វាជាមួយអាមួយនៅសណ្តាន់ ឈ្មោះ ដលាំសៀន ប្រធានសន្តិសុខភូមិភាគកំពង់ចាមស្កាត់រក ក៏ប៉ុន្តែទៅជាខុសវា ដល់តែក្រោយមកដឹងថាវាប្រធានគុកទួលស្លែង ។

**កុសលៈ** ឆ្នាំណាទៅពូ?

**សារុនៈ** ឆ្នាំ៧៨ ។

**កុសលៈ** ធ្វើម៉េចបានដឹង?

**សារុនៈ** ដឹងដោយសារក្រុមខ្មែរក្រហមមកពីភ្នំពេញមកស្រាវជ្រាវរកបណ្តាញ កុយ ធួន ហ្នឹង ចាប់ពួកអស់ហ្នឹងទាំងអស់ ។ នៅស្រុកបារាយណ៍នេះ អាកូនសិស្សខ្ញុំកូនដែលជាសិស្សវាដែរមកពីភ្នំពេញ ហើយអាកូនអាសិស្សនោះជួបខ្ញុំប្រាប់ថា នែ៎ «គៀវ» នៅភ្នំពេញ នៅគុកទួលស្លែង ប៉ុន្តែគេដាក់ឈ្មោះផ្សេង ហើយមិនដឹងឈ្មោះអីទេ តែវានៅភូមិភាគនៅមុខវាំង ។ ហើយដល់ពេលក្រោយមកដឹងថា ម៉ម ណៃ ក៏នៅជាមួយគ្នាដែរ ។ ម៉ម ណៃ ហៅ ចាន់ បើ



តាមពួកម៉ាកទៅធ្វើនៅបរប៉ៃលិន ស្រាវជ្រាវទៅ គេថានៅរស់នៅឡើយ ។

**កុសលៈ** សុំសួរពូបន្ថែមបន្តិចទាក់ទងជីវិតផ្ទាល់ខ្លួនកាលនៅជាមិត្តភក្តិ តើខុចក្រៅពីសកម្មក្នុងនយោបាយ តើមានជីវិតឯកជនបែបណា ចង់និយាយថា ដូចជាមានមិត្តនារី មិត្តស្រីអ៊ីទេ?

**សារុនៈ** អត់ អត់ អត់ អត់សូវចូលចិត្តទេ គ្មានផឹក គ្មានស៊ី ។ បារីជក់ បើថាវាវក់ជក់ ម៉ាថ្ងៃហ្នឹងគឺអុចបន្តរហូតអស់២កញ្ចប់ក៏មាន ៣កញ្ចប់ក៏មាន ហើយល្បែងអត់មានទេ នៅម៉ាកុដិ អាណាលេងបៀ អាណាលេងអី ក៏វាអត់លេងដែរតែបើវាបញ្ចុះបញ្ចូលដូចលោក គីម សួរ និយាយអម្បាញ់មិញ អាណាក៏ដើរត្រូវនឹងវាដែរ ។ ល្បែង ស្រី ស្រា អត់ទាំងអស់ ។

**កុសលៈ** ជនបដិវត្តន៍សុទ្ធសាធតាំងតែពីពេលហ្នឹង?

**សារុនៈ** បាទ ហើយបើថាឃើញគេពិបាកអី គ្រោះថ្នាក់ ភ្លៀតដល់ហើយជួយ បានជាគេស្រលាញ់វាច្រើននៅនឹងកុដិ ។ ហើយនៅស្គន់ វាបំផុសកូនសិស្សឲ្យទៅជួយស្ទូង ឲ្យទៅជួយធ្វើស្រែអី បានជាកូនសិស្សទៅព្រៃចូលជាមួយ ។ ដល់គេចាប់មកទាំងសិស្សចាប់ទាំងវា ពេលដែលយកទៅដាក់គុក ខ្ញុំទៅសួរ ខ្ញុំនៅជាលោកសង្ឃនៅឡើយ កាលណាទៅសួរ គេតាមដាន កាលណោះ ហ៊ូ នឹមក៏ស្គាល់ខ្ញុំដែរ ។ ហ៊ូ នឹម ថាអ្ហឺ! លោកប្អូនឯងទៅរញ៉េរញ៉ៃធ្វើអីឲ្យពិបាកគេ ។ ខ្ញុំថា «ចុះពិបាកអីបើគ្រាន់តែទោស មានទាន់ទៅណាវា បើមិនទៅសួរវាដូចអត់កើត..» ហើយបានប៉ូលិសថា «លោកតាអើយកុំធ្វើអីខ្មែរក្រហមនោះ» ។ ការពិតខ្ញុំគ្មានខ្មែរក្រហមអីខ្ញុំ (គាត់និយាយដោយសើច) ។ ផ្ទះវានៅស្មោង ផ្ទះវាខ្ញុំស្គាល់ ខ្ញុំកាលពីដើមទៅដល់តែផ្ទះហ្នឹង ក៏ប៉ុន្តែក្រោយ៧៩ខ្ញុំទៅអត់ឃើញទេប្អូនវាដែលធ្វើខ្មែរក្រហមគេវៃចោលដែរ ។ (គាត់ងាកទៅសួរលោក គីម សួរ) ឪពុកឃួន ម្តាយគាត់ចិនបានជា



ហោម សារុន

ឈ្មោះ កាំង ហ្គិចអៀវ ហើយរៀននៅកំពង់ធំនេះល្បីវារៀនពូកែខាងគណិតវិទ្យា គឺលេខ១រហូត ប្រឡងទូទាំងប្រទេសគឺវាជាប់លេខ១ទៀត គណិតវិទ្យាហ្នឹងឯង ។

**ដារ៉ា:** ឆ្នាំណា?

**សារុន:** ឆ្នាំ៦១បាក់អង ដល់ទៅវារៀនជាប់បាក់អងទៅប្រឡងធ្វើសាស្ត្រាចារ្យជាប់ទៀត ។ ដល់ពេលចេញមកវិញរៀនយកសញ្ញាប័ត្រជាមួយខ្ញុំខាងអក្សរសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញវិញ អត់យកគណិតវិទ្យាទេ ។

**កុសល:** ចុះក្នុងរយៈពេលប៉ុន្មានឆ្នាំដែលគាត់នៅជាមួយតើ ឌុច (កាំង ហ្គិចអៀវ ឬ គៀវ) ធ្លាប់ដែលប្រាប់ពូពីរឿងអ្វីផ្សេងៗផ្ទាល់ខ្លួនដូចជា ការលំបាកក្តី ឬក៏ចំណង់ចំណូលចិត្តពិសេសអីដែលលោកពូចាំបានដែរទេ?

**សារុន:** វាអត់មាននិយាយអំពីជីវភាពវាទេ វានិយាយតែប៉ុណ្ណឹងថាមិនត្រូវទុកឲ្យអាណានិគមនិងចក្រពត្តិជាន់ក្បាលរាស្ត្រទេ ។

**កុសល:** ឪពុកម្តាយដែលទៅលេងទេ?

**សារុន:** ឪពុកម្តាយវាមិនសូវទៅទេ បើបងប្អូនវាមានទៅ ប៉ុន្តែម៉ាពោះវាអានោះពូកែអប់រំ ។ ម៉ាកុដិជាមួយខ្ញុំហ្នឹងបើក្មេងៗចូលតាមវាច្រើន ពេលចេញទៅឆ្នាំ៧៣ ។ មានតែខ្ញុំទេនៅលោកសង្ឃដដែល ។ ដល់ខ្ញុំនៅជាលោកសង្ឃ វាអត់សូវហ៊ានទាញទេ ព្រោះខ្ញុំថាបើអ្ហែងហ៊ានអូសលោក ផ្តេសផ្តាសវ៉ៃបែកក្បាលប្រយ័ត្ន (គាត់សើច) ហើយបើជួបគ្នាឥឡូវនិយាយសាដើមឡើងវិញ វា (ហ្គិចអៀវ) អត់ហ៊ានប្រកែកនឹងខ្ញុំទេ ។ ខ្ញុំប្រើចិត្តសាស្ត្រមួយពេលដែលវារៀបទៅបង្ហាត់នៅស្គន់ពីព្រោះពីដើមទៅនោះខ្ញុំធ្វើជាគ្រូទាយ ខ្ញុំនិយាយឲ្យអស់ទៅខ្ញុំថា អ្ហែងគ្រោះថ្នាក់ឆ្នាំក្រោយ ។ វាថាឥឡូវគាឯងភ្នាល់គ្នា បើគ្រោះថ្នាក់មែនថ្វាយបន្តិគាឯងរហូត ។ ដល់ឆ្នាំនោះគេចាប់មែន ។ ដល់គេចាប់រួចហើយជាប់គុក ខ្ញុំទៅយកអីឲ្យស៊ីវាថាមិនបាច់ម៉ោទេលោក វាថាអីចឹងណ៎ មិនបាច់ម៉ោទេលោកតា (ហៅលោកតាព្រោះ សារុន នៅជាសង្ឃ) ។ ដល់ចេញមកឆ្នាំ៧០ ឲ្យខ្ញុំទាយម្តងទៀត ខ្ញុំប្រាប់វាថា «ហ្អែងនេះកំពូល ប៉ុន្តែកំពូលខូច» ខ្ញុំនិយាយបើជួបវាខ្ញុំសួរអីចេះ! ថាដើម្បីទាញវា ប៉ុន្តែទាញវាអត់បានទេ ប៉ុន្តែវាអត់ដែលមើលងាយខ្ញុំទេ វាស្រឡាញ់ខ្ញុំណាស់...។

**កុសល:** ពីដើមនោះ លោកពូនិយាយថា គៀវ (ឌុច) ហាក់ដូចជាមានភាពជិតស្និទ្ធជាមួយ ខៀវ សំផន តើតាមរបៀបណាឬក៏តាមព្រឹត្តិការណ៍បែបណាដែលលោកពូបានដឹងថាមានភាពជិតស្និទ្ធ?

**សារុន:** ព្រោះអីចេះ ដែលដឹងថាជិតស្និទជាមួយ ខៀវ សំផន ពីព្រោះវេជ្ជបណ្ឌិត ជួន ជឿន និងខៀវ សំផន វានាំឲ្យស្គាល់ ខៀវ សំផន ក៏វានាំខ្ញុំស្គាល់ ជួន ជឿន ក៏វានាំឲ្យខ្ញុំស្គាល់ដែរ ។

**កុសល:** ឆ្នាំណាទៅលោកពូ?

**សារុន:** ចន្លោះឆ្នាំ៦៥-៦៦ ។ ដល់៦៧ហ្នឹងឯងវាជាប់គុក ។

**កុសល:** ពេលដែល កាំង ហ្គិចអៀវ(ឌុច) នៅក្នុងវត្តតើមានមន្ត្រីខ្មែរក្រហមថ្នាក់ដឹកនាំខ្មែរក្រហមជាន់ខ្ពស់ណាខ្លះដែលបានទៅជួបទេ?

**សារុន:** អត់ អត់ អត់ អត់ដែលឃើញម៉ោទេ អត់មាននរណាទេ ហើយបើវាទៅជួបគឺខ្ញុំសួរថាហ្អែងមានជួបទេ វាឆ្លើយថា «ខ្ញុំជួប» បើថាអត់គឺ «អត់» វាទៅកន្លែងអ្នកទាំងនោះស្ងាត់ៗ ។

**កុសល:** តើមានទំនាក់ទំនងតាមសំបុត្រអីដែរឬទេ?

**សារុន:** អ៊ូ! គ្មាន សំបុត្រមិនប្រើទេគាត់នោះ កិច្ចការសម្ងាត់របស់វាគឺមាត់និងមាត់ ។ ខ្ញុំទៅជួប ខៀវ សំផន ពេលដែលលោកសង្ឃទាមទារស្មើៗនោះណ៎ ហើយខ្ញុំទៅជួប ខៀវ សំផន និង ហ៊ូ នឹម នៅក្បែររដ្ឋសភា ។ កាលណោះគឺសុំឲ្យ ខៀវ សំផន គាត់ជួយអន្តរាគមន៍សភាឲ្យខាងសភាចេញទទួលស្គាល់សញ្ញាប័ត្រលោកសង្ឃស្មើនឹងសញ្ញាប័ត្រសាលាកាលហ្នុងនោះណ៎ ដល់គាត់សុំវិញសុំឲ្យជួយធ្វើបាតុកម្មប្រឆាំងចក្រពត្តិអាមេរិកតែប៉ុណ្ណឹង ។ ហ្នឹងគឺ ខៀវ សំផន ...សុំទៅសុំម៉ោ ។ **(នៅមានត)**

## អត្ថន័យនៃពាក្យខ្មែរក្រហម

**សហករណ៍:** ភូមិ ឃុំ ដែលមានមនុស្សរស់នៅ គិតគូរ ធ្វើការងារ និងទទួលផលជាសមូហភាពជារួមទាំងអស់ ។

**កងចល័ត:** គឺជាយុវជន-យុវនារី ដែលជាកម្លាំងស្រួច លើកគ្នាទៅវាយសម្រុកពីការដ្ឋានធំមួយ ទៅការដ្ឋានធំមួយ ។

**ភារកិច្ចស្នូល:** ការងារធំចាំបាច់ ហើយដែលត្រូវធ្វើមុនគេ ។

(ដកស្រង់ចេញពីសៀវភៅរៀនអក្សរ ថ្នាក់ទី២ បោះពុម្ពដោយក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧)

# ប្រវត្តិរូប ជួន ប្រាសិទ្ធ

## (កត់ត្រាតាមសំណៅដើមទាំងស្រុង)

(តពីលេខមុន)



ជួន ប្រាសិទ្ធ

### ៣) ជាមួយវៀតណាមៈ

ចុងខែកក្កដា ឆ្នាំ១៩៧០ ខ្ញុំបានទៅក្រុងហាណូយ ជាមួយ ចៅ សេង តាមសេចក្តីអញ្ជើញរបស់រដ្ឋាភិបាលវៀតណាម ។ មុនពេលខ្ញុំឡើងយន្តហោះមិត្តចិនម្នាក់មកហៅខ្ញុំថាមានគេចង់ជួប ។ ពេលនោះហើយខ្ញុំជួបមិត្ត រ៉ែត សាមឿន ។ គាត់ត្រូវជិះយន្តហោះទៅហាណូយដែរ ។ គាត់ចង់ជួបខ្ញុំដើម្បីប្រាប់ឲ្យប្រុងប្រយ័ត្ន ធ្វើយ៉ាងណាកុំឲ្យ ចៅ សេង ចាប់អារម្មណ៍ ។ មិត្ត រ៉ែត សាមឿន ជិះក្នុងបន្ទប់បើកយន្តហោះ ។ ទៅដល់ហាណូយខ្ញុំបានជួបគាត់ជាសម្ងាត់ម្តងទៀតអស់ពេលច្រើនម៉ោង ។ ខ្ញុំបានសួរបញ្ជាក់ តើនយោបាយបក្សយើងនិងបក្សវៀតណាមឯកភាពគ្នាទេ? គាត់បានបញ្ជាក់ខ្ញុំថា ប្រហែលគ្នា ទុកចិត្តគ្នាទៅវិញទៅមកបាន ។

គឺនៅក្នុងពេលខ្ញុំនៅហាណូយនេះហើយដែលខ្ញុំបានហាមាត់ឱ្យលុយវៀតណាមបម្រុងឲ្យ «សហភាពនិស្សិតខ្មែរ» ដំណើរការនៅប្រទេសបារាំង ហើយជាមួយនេះឱ្យលុយគេមកដោះស្រាយបញ្ហាផ្ទាល់ជំពាក់ជំពិននឹងផ្ទះនៅប៉ារីស ។ ការខុសយ៉ាងធំនេះ ពេលណាខ្ញុំនឹកឃើញខ្ញុំអួលនិងខឹងនឹងខ្លួនឯងយ៉ាងខ្លាំងក្លាដោយឈឺចាប់បំផុត ។ នេះគឺមកពីគ្មានពិសោធន៍នយោបាយទាំងស្រុង គ្មានមោទនភាពជាតិ និងមានទស្សនៈអន្តរជាតិនិយមខុសស្រឡះ ។ ជាព្រឹត្តិការណ៍មួយដែលខ្ញុំភ្លេចមិនបាន ។

ក្នុងរយៈកាល១ឆ្នាំមុនដំបូងខ្ញុំមានការយល់ខុសច្រើនអំពីវៀតណាម ។ ជាគំនិតនិយមស្មានតែវាស្មោះនឹងយើង គោរពយើង ។ គឺក្នុងស្មារតីនេះហើយបានធ្វើសេចក្តីរាយការណ៍អំពីសភាពការណ៍ផ្ទៃក្នុងយើងជាចំហតាមរយៈវៀតណាម ឲ្យវាដឹងចំណុចខ្សោយរបស់យើងទាំងអស់ ។ នេះរហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧១ ដែលខ្ញុំបានជួបបក្សឡើងវិញយ៉ាងរីករាយបំផុតនៅហាណូយ ។

ពេលនោះវៀតណាមចង់អូសទាញខ្ញុំណាស់ដោយមានក្តីសង្ឃឹម ព្រោះវាស្គាល់ចំណុចខ្សោយរបស់ខ្ញុំរស់នៅប្រទេសបារាំង ជីតាជនជាតិដើមវៀតណាម មានទស្សនៈសេរីដូចវា...។ល។

មុននឹងចូលរណសិរ្សខ្ញុំមិនស្គាល់វៀតណាមទេ ។ មានគំនិតថា ប្រជាជនវៀតណាមធ្វើបដិវត្តន៍ អ្នកបដិវត្តន៍ក៏ត្រឹមត្រូវដែរ ។ ក្នុងរយៈកាល៥ឆ្នាំនេះការអប់រំជាប់របស់បក្សនិងពិសោធន៍ជាក់ស្តែងមួយចំនួនលើឆាកអន្តរជាតិ បានធ្វើឲ្យខ្ញុំយល់ឃើញច្បាស់នូវមុខមាត់ក្រឡិចក្រឡុចរបស់វៀតណាមទាំងអាសន្នគ្រោះថ្នាក់ដល់ជីវិតប្រទេសជាតិយើង ។ ផែនការវាថ្មីៗនេះទៀតប៉ុនប៉ងកម្ទេចក្បាលម៉ាស៊ីនដឹកនាំបក្ស និងកម្ទេចបដិវត្តន៍យើងដ៏រុងរឿងនេះបានមកបញ្ជាក់ម្តងទៀតនូវទំនាស់បដិបក្សស្លាប់រស់រវាងយើងនិងវៀតណាម ។ វាមិនអាចបោះបង់ចោលមហិច្ឆតាលេបយើងទេ ។ សមាជបក្សវាថ្មីៗនេះបានបញ្ជាក់ច្បាស់ទៀតនូវមហិច្ឆតានេះ ។

ពីឆ្នាំ១៩៧០-១៩៧១ នៅក្នុងសន្និសីទអន្តរជាតិមានសហប្រតិបត្តិការគ្នាខ្លះ ។ តែតាំងពីឆ្នាំ១៩៧២មក គឺគណៈប្រតិភូយើងឯករាជ្យ ពិតមែនតែសន្និសីទនោះស្តីអំពីបញ្ហាប្រទេសទាំងបី ។

### ៤) ជាមួយសូវៀតៈ

១) ខ្ញុំជួបពួកសេរីសូវៀតមុនដំបូងបង្អស់នៅពេលខ្ញុំឆ្លងកាត់ម៉ូស្គូទៅប៉េកាំងជាមួយ ចៅ សេង ។ ទៅដល់ម៉ូស្គូ ជា សាន ដែលធ្វើទូតរណសិរ្សយើងនៅពេលនោះនាំខ្ញុំនិង ចៅ សេង ទៅជួបអ្នកដឹកនាំអង្គការសូវៀតនៃសន្តិភាពដែលជាអង្គការមហាជន ។ នៅពេលនោះ ចៅ សេង និង ជា សាន (អតីតឯកអគ្គរដ្ឋទូតប្រចាំក្រុងម៉ូស្គូ) និយាយ (ខ្ញុំគ្មាននាទីអីទេ) អរគុណគេ ពន្យល់គេ ។

២) ខែកញ្ញា ១៩៧០ រដ្ឋាភិបាលរណសិរ្សឲ្យខ្ញុំទៅប្រជុំនៅប៊ែរឡាំង នៅអាល្លឺម៉ង់ខាងកើត ចូលរួមក្នុងការប្រជុំគណៈកម្មការប្រតិបត្តិការនៃ «សន្និសីទស្តុកហុល សម្រាប់វៀតណាម»

ដើម្បីទៅពន្យល់សភាពការណ៍ថ្មីៗ នៅកម្ពុជាតាមសេចក្តីអញ្ជើញរបស់គេ ។ នៅពេលនេះក៏បានជួបពួកសូវៀត ពីព្រោះអង្គការនេះពួកសេរីរីកាន់កាប់ តែវាគ្មាននិយាយអីទេ ។ វាតាមដាន ។

៣) នៅខែតុលា ឆ្នាំ១៩៧០ រដ្ឋាភិបាលរណសិរ្សឲ្យខ្ញុំទៅចូលរួមក្នុង «សន្និសីទអំពីការស្រាវជ្រាវបទឧក្រិដ្ឋចក្រពត្តិអាមេរិកនៅឥណ្ឌូចិន» នៅក្រុងស្តុកហូម ។ ពេលនោះក៏ជួបពួកសូវៀត ។ តែគ្មានជជែកអីទេ ។ តែពួកវាពិនិត្យខ្ញុំ តាមដានទៀត ។

៤) នៅខែវិច្ឆិកា ឆ្នាំ១៩៧០ដដែល រដ្ឋាភិបាលឲ្យខ្ញុំទៅចូលរួមប្រជុំសន្និសីទស្តីអំពីវៀតណាម ឡាវ កម្ពុជា នៅស្តុកហូមដដែល ។ ឆ្លងកាត់តាមម៉ូស្គូខ្ញុំបានឲ្យអំណោយមួយជារូបឆ្លាក់ថ្មទៅអង្គការសន្តិភាពសូវៀត ។ នៅឯក្រុងស្តុកហូម ទូតសូវៀតបានអញ្ជើញគណៈប្រតិភូវៀតណាម ឡាវ និងកម្ពុជា ទៅហូបបាយមិត្តភាពនៅស្ថានទូតវា ។ គណៈប្រតិភូកម្ពុជាមានខ្ញុំ អាក្សត់ ពីទូរ៉េត និងគ្រិន លាន ។ នៅពេលជប់លៀងខ្ញុំក៏បានអរគុណចំពោះការគាំទ្ររបស់ប្រជាជនសូវៀត ។ ត្រឡប់មកតាមម៉ូស្គូវិញពួកអង្គការសូវៀតដើម្បីសន្តិភាពបានធ្វើមីទិងមួយគាំទ្រការតស៊ូប្រជាជនវៀតណាម ឡាវ កម្ពុជា ។ ខ្ញុំក៏បានឡើងនិយាយអំពីសភាពការណ៍ប្រទេសកម្ពុជា និងអរគុណប្រជាជនសូវៀតដែលគាំទ្រការតស៊ូយើង ។

៥) នៅពេលនៅម៉ូស្គូចាំទៅប្រជុំសន្និសីទមួយទៀតនៅក្រុងប៉ារីស ខែធ្នូ ឆ្នាំ១៩៧០ អ្នកទទួលខុសត្រូវសូវៀតម្នាក់ឈ្មោះកូវ៉ាឡង់កូ (គេថាជាសមាជិកមជ្ឈិមបក្សសូវៀត ទទួលខុសត្រូវខាងអាស៊ី) បានមកជួបខ្ញុំនៅឯបន្ទប់ខ្ញុំនៅសណ្ឋាគារ ។ វាមកនិយាយថា សូវៀតជាមហាអំណាចធំតែគ្មានបំណងទៅជិះជាន់ជ្រែកកម្ពុជាទេ ។ វាថាវាមិនទទួលស្គាល់ សីហនុ ទេ ។ វាទទួលស្គាល់រដ្ឋាភិបាល សីហនុ លុះត្រាបក្សកម្ពុជាសុំ ។ វាចង់ជួបបក្សកម្ពុជា តែបើជួបមិនបានវាសុំសំបុត្រពីបក្សយើងមួយសុំឲ្យវាទទួលស្គាល់រដ្ឋាភិបាលរណសិរ្សយើង ។

នេះជាមុនដំបូងបង្អស់ខ្ញុំមានការជួបផ្ទាល់ជាមួយសូវៀត ។ ខ្ញុំបានឆ្លើយប្រាប់វាថា ខ្ញុំមិនដឹងថាមានបក្សនៅកម្ពុជាទេ តែខ្ញុំនឹងរាយការណ៍នេះទៅអ្នកដឹកនាំនៅក្នុងប្រទេស ។

មកដល់ប៉េកាំងចុងខែធ្នូ ខ្ញុំបានរាយការណ៍ទាំងស្រុងជូនបក្សអំពីការជួបសន្ទនានេះ ។ ខ្ញុំបានធ្វើជាផ្លូវចំហតាមរយៈស្ថានទូតវៀតណាមនៅប៉េកាំង ។ តែដោយបានដឹងថាសមមិត្តតំណាងបក្សបានមកដល់ហាណូយហើយ វៀតណាមក្រោយពីបានមើលនិងយកទូរលេខទៅទុកអស់មួយថ្ងៃវាឲ្យមកខ្ញុំវិញដើម្បីខ្ញុំយកទៅជូនតំណាងបក្សផ្ទាល់ឯហាណូយ ។

៦) ក្រោយពីបានជួបបក្សឡើងវិញ និងបានរៀនសូត្រនិងទទួលការអប់រំពីបក្សនៅខែកុម្ភៈ ឆ្នាំ១៩៧២ បក្សបានណែនាំឲ្យខ្ញុំទៅចូលរួមក្នុង «សន្និសីទសកលដើម្បីសន្តិភាពនិងឯករាជ្យឥណ្ឌូចិន» ដែលធ្វើនៅក្រុងវែរសៃ (ប្រទេសបារាំង) ។ វាជាសន្និសីទអង្គការមហាជនដែលពួកសេរីកាន់កាប់ ។

នៅពេលនោះមានខបទ្វេហេតុមួយរវាងគណៈប្រតិភូកម្ពុជានិងសូវៀត ។ គឺតាមរយៈគណៈប្រតិភូបារាំង សូវៀតមិនព្រមឲ្យដាក់ក្នុងសេចក្តីសម្រេចចិត្តនៃសន្និសីទនូវគោលជំហរកម្ពុជាទាំងស្រុង ។ ក្រោយពីបានសន្ទនារហូតម៉ោង៣ភ្លឺ ខ្ញុំបានប្រាប់គេថាបើដាក់គោលជំហរកម្ពុជាមិនបានទាំងស្រុងទេមិនបាច់ដាក់ទេ គឺសេចក្តីសម្រេចចិត្តមិនបាច់និយាយអំពីបញ្ហាកម្ពុជាទេ ។ តែបើសេចក្តីសម្រេចចិត្តនិយាយអំពីបញ្ហាកម្ពុជា ហើយនិយាយមិនចំត្រឹមត្រូវខ្ញុំជំពាក់ឡើងតវ៉ាពេលអង្គប្រជុំហើយ ។ ការឈ្លោះប្រកែកគ្នានេះគេដឹងគេព្រួរហូតកាសែតបារាំងនិងទូរគមន៍បរទេសផ្សាយ ។ ជាទីបញ្ចប់ពួកសូវៀតជំពាក់យល់ព្រម ។ នៅពេលនោះគោលជំហរយើងគឺដោះស្រាយបញ្ហាកម្ពុជាតាម៥ខ នៃសេចក្តីប្រកាសថ្ងៃ២៣ ខែមីនា ឆ្នាំ១៩៧០ ហើយសុំឲ្យគេទទួលស្គាល់រដ្ឋាភិបាលរណសិរ្សកាន់តែច្រើន ។

៧) នៅខែ៥ ឆ្នាំ១៩៧៣ អង្គការសន្និសីទស្តុកហូម អំពីវៀតណាម ឡាវ កម្ពុជា បានអញ្ជើញគណៈប្រតិភូកម្ពុជាទៅខទ្វេសនាមអំពីបញ្ហាកម្ពុជា ។ ពេលនោះវៀតណាមនិងឡាវអស់វាយហើយនៅតែកម្ពុជា ។ បក្សបានសម្រេចឲ្យខ្ញុំដឹកនាំគណៈប្រតិភូនេះហើយសុំឲ្យគេកោះហៅប្រជុំសន្និសីទអន្តរជាតិមួយអំពីកម្ពុជា ។ នៅពេលនោះគណៈប្រតិភូសូវៀតធ្វើឧបាយកលជាច្រើនដើម្បីទប់ទល់មិនឲ្យធ្វើសន្និសីទនេះ ។ តែក្រោយពីជ័យជម្នះយើងថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៣ (ជាថ្ងៃមហាបរាជ័យសង្គ្រាមអាកាសចក្រពត្តិអាមេរិក (ឯកសារ D៦៩៣ ដែលមានចំណងជើងថា

សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួនចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។) ពួកវាជំពាក់តែគាំទ្រសន្និសីទនេះដើម្បីបង្ហាញថា វាគាំទ្រការតស៊ូប្រជាជនកម្ពុជាដែរ ។

៨) សន្និសីទអន្តរជាតិអំពីកម្ពុជាបានបើកប្រជុំ ខែធ្នូ ឆ្នាំ១៩៧៣ នៅប៉ារីស ។ បក្សបានសម្រេចឲ្យខ្ញុំដឹកនាំគណៈប្រតិភូកម្ពុជា ។ សន្និសីទនេះបានយកជ័យជម្នះមួយធំដែរ ។ ពួកសូវៀតឯកោខ្លាំង ។ ក្នុងសុន្ទរកថា ខ្ញុំបាននិយាយអំពីសាមគ្គីភាព




ជាមួយប្រជាជនស្នេហាសន្តិភាពនិងយុត្តិធម៌ ពិសេសរវាងកម្ពុជា វៀតណាម ឡាវ ចិន និងកូរ៉េ ។ ២ ឬ ៣ថ្ងៃ ក្រោយសន្និសីទចប់ អា កូវ៉ាឡង់កូ (ដែលបានមកជួបខ្ញុំ ពីខែធ្នូ ឆ្នាំ១៩៧០ នៅម៉ូស្គូ) បានសុំជួបខ្ញុំ ។ ខ្ញុំក៏បានទទួលវានៅឯបេសកកម្មយើងនៅប៉ារីស ។ ដើម្បីចៀសវាងមិនឲ្យវាមកនិយាយអំពីបញ្ហាទាក់ទងរវាងបក្សនិងបក្ស ខ្ញុំបានយកពួករណសិរ្សម្នាក់ ឬពីរនាក់ចូលរួមក្នុងការសន្ទនានេះ ។ នៅពេលនោះមានឈ្មោះ អៀង គុណសាគី ។ អា កូវ៉ាឡង់កូ មកនិយាយថា «អ្នកឯងបាននិយាយអំពីសាមគ្គីភាពពិសេស



រវាងប្រទេសទាំង៥ ។ តើកម្ពុជាចង់បានមិត្តតែ៥ឬ? ចុះអ្នកឯទៀតដែលជួយគាំទ្រកម្ពុជាដែរតើកម្ពុជាមិនទុកជាមិត្តទេឬ? បើអ្នកឯងនៅតែនិយាយ ដូច្នេះគឺនាំឲ្យខូចខាតដល់ការទាក់ទងរវាងសូវៀតនិងកម្ពុជា» ។ នេះជាការគំរាមកំហែងមួយធំជ្រៀតជ្រែកបញ្ហាផ្ទៃក្នុងយើង និងរំលោភលើអធិបតេយ្យភាពយើង ។ ខ្ញុំបានឆ្លើយទៅវិញថា «ខ្ញុំបាននិយាយអំពីសាមគ្គីភាពរវាងប្រជាជនទាំង៥នេះហើយចេញឈ្មោះ៥នេះ ព្រោះប្រទេសទាំងនោះបានគាំទ្រការតស៊ូយើងខ្ញុំតាំងពីដើមមក ។ ពិសេសប្រទេស និងប្រជាជនចិនបានឧបត្ថម្ភគាំទ្រយើងខ្ញុំតាំងពីដើមលើគ្រប់ផ្នែកដោយស្មោះ និងឥតលក្ខខណ្ឌ ហើយគេមិនដែលមកជ្រៀតជ្រែកក្នុងបញ្ហាផ្ទៃក្នុងយើងខ្ញុំ ដូចប្រទេសខ្លះទេ» ។ អា កូវ៉ាឡង់កូមុខក្រហម តែវាឈប់និយាយអំពីបញ្ហានេះ វានិយាយអំពីជ័យជម្នះនៃសន្និសីទទៅវិញ ។ មុននឹងវាសុំលាខ្ញុំ វានិយាយថា វារីករាយណាស់ដោយបានមកជួបខ្ញុំ ព្រោះបានស្គាល់គ្នាថែមទៀត ។ ខ្ញុំក៏បានឆ្លើយថា «អីចឹងហើយយើងស្គាល់គ្នាថែមទៀត» ។

ដល់ខ្ញុំត្រឡប់មកប៉េកាំងឆ្លងកាត់ក្រុងម៉ូស្គូវិញ (តាមសំបុត្រយន្តហោះដែលសន្និសីទចេញឲ្យ) ពួកទទួលខុសត្រូវអង្គការសូវៀតនៃសន្តិភាពបានមកចាំទទួលខ្ញុំនៅវាលយន្តហោះ ហើយបានអញ្ជើញខ្ញុំហូបបាយនៅវាលយន្តហោះនោះ ព្រោះខ្ញុំចៀសវាងឈប់យូរនៅម៉ូស្គូ គ្រាន់តែឈប់ចាំយន្តហោះទៅប៉េកាំង ។ ពួកវារាក់ទាក់ណាស់ហើយបាននិយាយថា គួរតែកម្ពុជាសរសេរសៀវភៅមួយស្តីអំពីការបរាជ័យនៃរដ្ឋប្រហារចក្រពត្តិអាមេរិក ព្រោះក្នុងប្រវត្តិសាស្ត្រមិនដែលមានទេ ។ នេះជាពេលចុងក្រោយដែលខ្ញុំបានជួបនិយាយជាមួយពួកសូវៀតរហូតខ្ញុំទៅអង្គការសហប្រជាជាតិឆ្នាំ១៩៧៥ ។

៩) ក្នុងចំណោមពួកសេរី ពួកគុយបានេះសកម្មជាមួយយើងជាងគេ ។ ពីព្រោះជាប្រទេសសេរីដែលបានទទួលស្គាល់យើងតាំងពីដើមមក ។ ដូច្នេះក្នុងគ្រប់សន្និសីទ គណៈប្រតិភូគេមករាក់ទាក់យើងនិងគណៈប្រតិភូយើងណាស់ ។ តែនេះជារូបភាពទេ ។ ការពិតគុយបាគ្រាន់តែឡើងសូត្រសុន្ទរកថាយ៉ាងខ្លីតែប៉ុណ្ណោះ ។ ខ្ញុំក៏រាក់ទាក់នឹងគេវិញ ពិសេសជាមួយប្រធានគណៈប្រតិភូឈ្មោះ មេលបា អែរណាន់ដេស ជានារីទី២ ឬទី៣ ដែលបានតស៊ូជាមួយ ហ្វីដែលកាស្ត្រូ ។ ក្រៅពីការរាក់ទាក់នេះគ្មានអ្វីជាសំខាន់ទេ ។

តាមការអត្តនោម័តិរបស់ខ្ញុំ ពួកសូវៀតនិងគុយបាដឹងថាខ្ញុំជាបក្ខជនដោយវៀតណាមខទ្វេសនាមប្រាប់វា ។ នេះជាហេតុផលមួយនាំឲ្យវាខំរាក់ទាក់នឹងខ្ញុំ ។ តែសព្វថ្ងៃនេះវាក៏បានស្គាល់ខ្ញុំដែរហើយ ។ ហេតុនេះការរាក់ទាក់នេះបានបន្ថយច្រើន ។ ច្បាស់លាស់គឺនៅពេលបក្សឲ្យខ្ញុំទៅគុយបាពីខែ៥នេះ ។ គេមិនបានទទួលគណៈប្រតិភូកម្ពុជាយើងដោយកក់ក្តៅទេ ។

១០) ទស្សនៈនិងគោលជំហររបស់ខ្ញុំចំពោះសូវៀត

នៅឆ្នាំ១៩៧០-៧១ ខ្ញុំមិនទាន់ស្គាល់អ្វីហៅថាសេរីរីទេ ។ ចំពោះសូវៀតក៏មិនទាន់កំណត់ច្បាស់ដែរ ។ ហេតុនេះក៏ជាគោលជំហរចង់ធ្វើយ៉ាងណាឲ្យប្រទេសសេរីរីនេះទទួលស្គាល់យើងដែរ គឺបានខំទន់ភ្លន់ពន្យល់គេដោយយល់ថាពួកនេះមានលក្ខណៈបដិវត្តន៍ដែរ ។ ដូច្នេះបើពួកនេះទទួលស្គាល់យើងនេះជាការជំរុញការតស៊ូយើងដែរ ។ តែការអប់រំពីបក្សពិសោធន៍ជាក់ស្តែងមួយចំនួនធំបានឲ្យខ្ញុំយល់និងក្តាប់ធាតុសេរីរីនេះបានមួយកម្រិតហើយ យល់ច្បាស់នូវគ្រោះថ្នាក់សេរីរីមកលើបដិវត្តន៍យើង ។ ជាមាគ៌ាដំណើរការខ្ញុំក៏មិនដែលទៅរករឿងវាទេ ។ តែដាច់ខាតក៏មិនឲ្យវាមកជ្រៀតជ្រែកផ្ទៃក្នុងយើង ឬធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យភាពនិងកិត្តិយសយើងបានទេ ។

តែដោយបានទទួលឥទ្ធិពលសង្គមនាយទុនច្រើនចូលមកធ្វើបដិវត្តន៍នេះគឺនៅសល់ធាតុសេរីរីនៅឡើយ ។ប្រការនេះនាំឲ្យខ្ញុំចាប់អារម្មណ៍ជាប់ហើយប្រុងប្រយ័ត្នជាប់ពិសេសក្នុងពេលទៅបំពេញភារកិច្ចនៅក្រៅប្រទេស ។ ទាំងចក្រពត្តិ ទាំងសេរី វាស្គាល់ជីវប្រវត្តិខ្ញុំមួយកម្រិតធំ ។ វាបានខំអូសទាញខ្ញុំ ហើយវាមិនទាន់អស់សង្ឃឹមនឹងអូសទាញបានទេ ។ ការដែលខ្ញុំបានមករស់នៅក្នុងប្រទេសនេះជាការល្អប្រសើរឲ្យខ្ញុំចាក់ឫស ហើយកម្ចាត់ទស្សនៈសេរីរីបានមួយកម្រិតធំ ។

## ៥) ជាមួយចក្រពត្តិអាមេរិកៈ

តស៊ូដាច់ខាតគ្មានសម្រុះសម្រួល ។ វាជាខ្មាំងស្លាប់រស់តាំងពីដើមមក ។ ក្នុងទស្សនៈនិងជាគោលជំហរខ្ញុំបានឃើញហើយអប់រំពួករណសិរ្សថ្នាក់លើថា សង្គ្រាមនេះត្រូវជាសង្គ្រាមចុងក្រោយបង្អស់គឺតស៊ូដាច់ខាតដើម្បីសម្រេច៥ខរបស់រណសិរ្សយើងទាំងស្រុង ។ តែរហូតដល់ឆ្នាំ១៩៧៣ ខ្ញុំមិនទាន់ឃើញផ្លូវដោះស្រាយយ៉ាងណាទេ ហើយក៏មិនទាត់ចោលទាំងស្រុងលទ្ធភាពចរចាដែរ ។ ចាប់តាំងពីឆ្នាំ១៩៧៣ ពិសេសចាប់តាំងពីខែសីហាខ្ញុំបានជឿជាក់ថាយើងមានជ័យជម្នះដោយអត់ចរចាបានទាំងស្រុង ។ ឯការតស៊ូយូរអង្វែងនេះ បញ្ហាមិនចោទលើខ្ញុំដែលនៅក្រៅប្រទេសទេ ពីព្រោះក្រៅពីការបែកគ្រួសារគ្មានការលំបាកច្រើនទេ ។ ការតស៊ូយូរអង្វែងនេះអាស្រ័យតែលើកម្លាំងប្រជាជនយើងនៅក្នុងប្រទេស ។ នៅលើឆាកអន្តរជាតិនៅក្នុងគ្រប់សន្និសីទខ្ញុំបានប្រកាន់ជាប់នូវទស្សនៈគោលជំហរតស៊ូដាច់ខាតមិនសម្រុះសម្រួល ។ មិនដែលខ្វាស់កន្ទែងណាទេ ។ **(នៅមានត)**

**ពាក្យស្លោកខ្មែរក្រហម**

◆ **បដិសេធកម្មាភិបាលអាក្រក់ ដែលមិនព្រមកែប្រែ កម្ចាត់អាជ្ញានិយម ការិយាល័យនិយម នាម៉ឺននិយម ឱកាសនិយម។**

(ដកស្រង់ចេញពីសៀវភៅខ្មែរក្រហមលេខ០៧៦កណហ)

# កុមារ សឿ ពីតំបន់៣១មកគុកទួលស្លែង

កុមារ សឿ រស់នៅក្នុងតំបន់៣១ (ខេត្តកំពង់ឆ្នាំង) ។ សឿ និងកុមារជាច្រើនទៀតត្រូវពួកខ្មែរក្រហមក្នុងតំបន់៣១ បញ្ជូនទៅបម្រើបដិវត្តន៍ «នៅមជ្ឈិម» ក្នុងឋានៈជាកងការពារនៅគុកទួលស្លែង ។

ក្នុងឆ្នាំ១៩៧៣ ពេល សឿ មានអាយុ១២ឆ្នាំ ត្រូវគណៈឃុំតាដេសឈ្មោះ អួង និងគណៈស្រុកកំពង់ត្រឡាចឈ្មោះ រិន បញ្ចុះបញ្ចូលឲ្យចូលបម្រើកងទ័ពបដិវត្តខ្មែរក្រហមដោយពួកគាត់អះអាងប្រាប់ សឿ ថាពួកគាត់នឹងជួយមើលថែរក្សាម្តាយនិងប្អូនៗរបស់ សឿ ហើយគ្រួសាររបស់ សឿ នឹងបានរស់នៅយ៉ាងសុខសប្បាយនៅក្នុងពេល សឿ ចេញទៅបម្រើបដិវត្តន៍ ។

យាយសន (ម្តាយ សឿ) មិនចង់ឲ្យកូនប្រុសគាត់ចូលបម្រើកងទ័ពខ្មែរក្រហមទេ ។ ពេលដឹងថាកូនគាត់ត្រូវគណៈឃុំនិងគណៈស្រុកតម្រូវឲ្យចូលទ័ព យាយ សន បានទៅអង្វរគណៈឃុំ អួង និងគណៈស្រុក រិន ដើម្បីឲ្យ សឿ បាននៅជាមួយគាត់គ្រាន់ជួយធ្វើការងារខ្លះៗ ។ សឿ រំឭកសម្តីដែលម្តាយគាត់អង្វរគណៈឃុំ និងគណៈស្រុកថាៈ «**អាណិតមីងផង បើអត់ពីវាគ្មាននរណាជួយមើលប្អូនវាទេ ឲ្យវាបាននៅក្នុងភូមិនឹងគេផង**» ។ ពាក្យអង្វររបស់យាយ សន ពុំអាចបញ្ឈប់កង់ប្រវត្តិសាស្ត្រនិងផែនការរបស់បដិវត្តន៍ខ្មែរក្រហមមិនឲ្យវិលទៅមុខបានឡើយ ។

ទីបំផុត សឿ ចូលបម្រើកងទ័ពខ្មែរក្រហមតាមបញ្ជារបស់គណៈស្រុក ដោយសង្ឃឹមថាម្តាយនិងប្អូនៗរបស់ខ្លួនបានរស់នៅសុខសាន្ត ។ សឿ ដូចជាបានកក់ក្តៅ ព្រោះក្មេ (មិត្ត) របស់គាត់ដែលរស់នៅក្នុងភូមិស្រុកជាមួយគ្នា ដូចជា មឿន-ហុង-ទ្រឿ-សៀក និង ពៅ ក៏ត្រូវចេញពីភូមិទៅបម្រើបដិវត្តន៍នៅមជ្ឈិមជាមួយគាត់ដែរ ។

សឿ សប្បាយចិត្ត ហើយលែងព្រួយបារម្ភពីម្តាយនិងប្អូនៗនៅឯភូមិនៅពេលដែលមានកាំភ្លើងស្ពាយលើស្មានិងបានចេញពីភូមិទៅធ្វើការនៅមជ្ឈិម ។ មុននឹងបញ្ជូនទៅធ្វើជាកងការពារនៅគុកទួលស្លែង សឿ ត្រូវឆ្លងកាត់ការហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រទ័ពអំពីការបាញ់ លួនក្រាប និងដាក់មីន អស់រយៈពេល៣ខែ និង ២៨ថ្ងៃ នៅតាខ្មៅ ។ សឿ រៀបរាប់ថា «**ការហាត់នេះអ្នកខ្លះត្រូវស្លាប់ព្រោះការហាត់គឺហាត់ដាក់ស្តែង ។ ឧទាហរណ៍ហាត់ដាក់មីននិងដោះមីនគឺមានម្នាក់អ្នកដាក់ និងម្នាក់ទៀតអ្នកដោះ បើផ្ទុះងាប់គឺងាប់ចោលតែម្តង**» ។

ក្រោយហាត់ហ្វឹកហ្វឺនចប់ សឿ ត្រូវពួកខ្មែរក្រហមបញ្ជូនទៅកងពល៧០៣ ។ កងពលនេះមានភារកិច្ចការពារជុំវិញក្រុងដូចជានៅគុកទួលស្លែង ទួលទំពូង ក្បាលថ្នល់ (ស្ពានមុនីវង្ស) និងជាយក្រុងភ្នំពេញ ។ ភារកិច្ចបន្ទាប់បន្សំខ្លះទៀតរបស់ទ័ពក្នុងកងពល៧០៣គឺការដាំដុះ និងបោសសម្អាតតាមផ្លូវថ្នល់ ។ សឿ បញ្ជាក់ថា ពេលយាមកាមគឺមានការផ្លាស់ប្តូរវេនគ្នាជួនកាលយប់ជួនកាលថ្ងៃ ។ បើយាមយប់គឺចាប់ពីម៉ោង៦ រហូតដល់ម៉ោង១១ ហើយអ្នកយាមបន្តគឺចាប់ពីម៉ោង១១ រហូតដល់ភ្លឺតែម្តង ។ ក្រោយពេលយាមគឺសម្រាក ។ ចំណែកការហូបចុក សឿ អះអាងថាបានហូបគ្រប់គ្រាន់មួយថ្ងៃបីពេល ។

សឿ ពិពណ៌នាអំពីគុកទួលស្លែងដែលមានសមមិត្ត ឌុច និងសមមិត្ត ហ៊ី ជាអ្នកគ្រប់គ្រង ។ អគារទាំងអស់មានកម្ពស់បីជាន់ រុំព័ទ្ធដោយរបងលួសបន្លា និងមានចរន្តអគ្គិសនី ។ បន្ទប់នីមួយៗមានអ្នកទោសតិចច្រើនតាមទំហំបន្ទប់ ។ អ្នកទោសត្រូវដឹកចូលគុកទួលស្លែងដោយឡាន ទាំងយប់ ទាំងថ្ងៃ មកពីគ្រប់ទិសទី ។ ទាហានបូព៌ា ខេត្តស្វាយរៀង ព្រៃវែង និងកំពង់ចាម រាប់រយនាក់ត្រូវពួកខ្មែរក្រហមកុហកថានាំមកភ្នំពេញដើម្បីសម្រាក និងមើលកុនល្ខោន តែត្រូវនាំយកមកដាក់គុកនិងសម្លាប់ចោលទៅវិញ ។

សឿ ក៏ត្រូវពួកខ្មែរក្រហមចាប់ខ្លួននាំទៅសួរចម្លើយដែរ ព្រោះគាត់ត្រូវជាក្មេនឹង ហុង និង មឿន ដែលចេញពីភូមិ ស្រុកជាមួយគ្នា ។ ក្មេរបស់គាត់ត្រូវសមមិត្ត ហ៊ី ចាប់ដាក់គុក និងសម្លាប់ចោលដោយចោទថា ជាខ្មាំងបង្កប់ នៅខែមិថុនា ឆ្នាំ ១៩៧៧ ។ ហុង បានផ្តាំផ្ញើ សឿ ឲ្យទៅប្រាប់ម្តាយក្រោយពីត្រូវជាប់នៅក្នុងគុក ហើយដឹងថាខ្លួននឹងត្រូវស្លាប់ ។ សឿ រំឭកពាក្យផ្តាំ

របស់ ហុង ថា៖ «**បើឯងមានជីវិតរស់បានត្រឡប់ទៅដល់ភូមិស្រុក ជួយប្រាប់ម្តាយអញផងថាអញស្លាប់ហើយ អត់បានទៅស្រុកភូមិវិញទេ**» ។ សឿ ត្រូវពួកខ្មែរក្រហមសង្ស័យថាជាខ្មែរក្បត់ជាមួយ ហុង និង មឿន ហើយចាប់ខ្លួននាំទៅសួរចម្លើយដែរ តែក្រោយមកត្រូវបានដោះលែងវិញ បន្ទាប់ពី សឿ បញ្ជាក់ប្រាប់ពួកខ្មែរក្រហមថា គាត់មិនបានធ្វើជា សេ.អ៊ី.អា ឬ កាហ្សេបេទេ គឺគាត់ចូលបដិវត្តន៍តាំងពីអាយុ១៧ឆ្នាំម្ល៉េះ ។ ពេលត្រូវចាប់ខ្លួននាំទៅសួរចម្លើយនោះ សឿ ដើរកាត់បន្ទប់សួរ


ក្រុមកងការពារហាត់ក្បាច់ប្រយុទ្ធ

ចម្លើយជាបន្តបន្ទាប់ ហើយគាត់សង្កេតឃើញតុមួយ និងកៅអីមួយត្រូវបានរៀបចំគ្រប់បន្ទប់សម្រាប់អ្នកសួរចម្លើយនិងអ្នកទោស ។ សឿ បញ្ជាក់ថាអ្នកសួរចម្លើយ គឺជាប្រភេទក្មេងដាច់ខាត និងសាហាវបំផុតព្រោះពេលអ្នកទោសមិនព្រមឆ្លើយ ឬផ្តល់ចម្លើយមិនពេញចិត្តដល់អ្នកសួរ គឺអ្នកទោសច្បាស់ជាត្រូវក្បាលនឹងដំបង ឬស្បែកជើងនិងខ្សែភ្លើងឆក់មិនខាន ។ «**បើវាវ៉ៃមិនដល់គឺវាឲ្យអ្នកទោសអង្គុយ ឬទំនចុះ រួចវាវ៉ៃផូស ដូនកាលវ៉ៃជ្រុលដៃរហូតដល់ស្លាប់ក៏មានដែរ**» ។ សឿ បង្ហាញករណីសម្លាប់ដ៏គួរឲ្យញាក់សាច់មួយក្នុងចំណោមការសម្លាប់ជាច្រើនដែលគាត់បាន


សឿ ថតក្នុងឆ្នាំ២០០០

ឃើញផ្ទាល់ភ្នែក ការសម្លាប់នេះដែលកើតឡើងក្នុងឆ្នាំ១៩៧៦ គឺនៅពេលដែល សឿ មានភារកិច្ចយាមនៅមុំទួលទំពូង សឿ បានឃើញជនបរទេសស្បែកស (បារាំង) ពីរនាក់ ដែលពួកខ្មែរក្រហមចាប់មកពីខេត្តកោះកុងត្រូវពួកវាចងដៃនិងជើងដាប់ដាក់ឲ្យអង្គុយទល់មុខគ្នានៅមុខវត្តទួលទំពូង រួចពួកវាស៊ីកកង់ឡានពីលើខ្លួននិងជុំវិញ ហើយចាក់សាំងដុតទាំងរស់ប្រកាច់ដូចសត្វ ។

សឿ ចាប់អារម្មណ៍អំពីស្ថានភាពនៅគុកទួលស្លែងថា ពេលទៅដល់ដំបូងដូចជាអត់សូវតឹងប៉ុន្មានទេ តែក្រោយមកចេះតែតឹងតែងទៅៗតែម្តង ។ សឿ ចាំថាក្នុងខែ២ ឆ្នាំ១៩៧៦ គាត់សុំមិត្ត ប៉ែន ប្រធានគាត់មកលេងម្តាយនៅភូមិកំណើត ប៉ែន ថាចាំខែ៦ ។ ពេលដល់ខែ៦ ប៉ែន ថាចាំខែ៩ ។ លុះដល់ខែ៩គឺផ្តាច់ការនិយាយអ៊ីធ្វើអ៊ីក៏មិនបានដែរ ពិសេសការសម្លាប់មានកាន់តែច្រើនរហូតដល់ឆ្នាំ១៩៧៩តែម្តង ។ សឿ បន្ថែមថាកងការពារនៅគុកទួលស្លែងត្រូវពួកខ្មែរក្រហមកុហកបោកប្រាស់ឲ្យប្រឹងប្រែងធ្វើការបម្រើបដិវត្តន៍ដោយមិនត្រូវគិតនឹកបារម្ភពីឪពុកម្តាយនៅឯភូមិស្រុកឡើយ ។ សឿ រៀបរាប់សម្តីភូតកុហកលួងលោមដែលពួកខ្មែរក្រហមប្រើប្រាស់ថា «**ខំប្រឹងធ្វើការងារផែនការរបស់បក្ស ខំហាត់រៀនលត់ដំខ្លួនទៅ ម៉ែឪខាងក្រោយកុំព្រួយ អង្គការទុបត្ថម្ភមួយថ្ងៃបីពេលហើយ**» ។

**អៀ ម៉េងទ្រី**



សមមិត្ត ហឹ

## បញ្ជីរាយនាមញាតិវង្សដែលបានចាប់ឃុំឃាំងនិងស្លាប់នៅទួលស្លែង

| ល.រ | នាមនិងគោត្តនាម | ភេទ | មុខងារ | ប្រភពឯកសារ | ថ្ងៃចូលមន្ទីរស-២១ | ថ្ងៃកម្ទេចចោល |
|---|---|---|---|---|---|---|
| ១ | ស៊ីសុវត្ថិ ប៉ុតសារ៉ា | ប្រុស | ទាហានពាក់សក្តិ២ | បបគ១០៦ | ១-៣-៧៦ | ៣-៥-៧៦ |
| ២ | ស៊ីសុវត្ថិ កេតារ៉ារ៉ាក់ | ស្រី | ប្រពន្ធសក្តិ២ យាមគុក | បបគ១០៦ | ១-៣-៧៦ | កម្ទេច |
| ៣ | ស៊ីសុវត្ថិ ដួងខរ៉ា ហៅម្ចាស់ហ៊ុត | ប្រុស | ពាណិជ្ជករ | K០៦៥០៩ | (ឥតមាន) | (ឥតមាន) |
| ៤ | ស៊ីសុវត្ថិ អៀមម៉ារិយ៉ា | ( ) | កូនស្តេច | TSL០២៨៤ | ១០-១០-៧៦ | ១៤-១០-៧៦ |
| ៥ | ស៊ីសុវត្ថិ ប៉ុនវីរៈវង្ស | ( ) | កូនស្តេច | TSL០២៨៤ | ៣០-១០-៧៧ | (ឥតមាន) |
| ៦ | ស៊ីសុវត្ថិ នរៈនរិនដារ៉ារិទ្ធ ហៅចិន្តា | ស្រី | កូនស្តេច | TSL០២០៤ | ២៩-៨-៧៨ | ១៤-១០-៧៦ |
| ៧ | ម៉ារីយ៉ា ហៅ ម៉ារី | ប្រុស | កូនស្តេច | បបគ១១០ | ៨-១១-៧៦ | (ឥតមាន) |



### ប្រវត្តិអ្នកទោស ស៊ីសុវត្ថិ ប៊ុកសារ៉ា

ឈ្មោះ ស៊ីសុវត្ថិ ប៊ុកសារ៉ា ហៅ ច្រឹង អាយុ៣៣ឆ្នាំ ជាតិខ្មែរ ភេទប្រុស ទីលំនៅកំណើតផ្សារស៊ីញ៉ែក សង្កាត់លេខ៣ ក្រុងភ្នំពេញ ។ មុនឆ្នាំ១៩៧៥ ធ្វើទាហានពាក់សក្តិ២ បច្ចុប្បន្នជាប្រជាជន ឪពុកឈ្មោះ ស៊ីសុវត្ថិ ខ្ជួងលក្ខណា ម្តាយឈ្មោះ សុខ សួន ប្រពន្ធឈ្មោះ គាក់ លីអេង មានកូនប្រុស៤នាក់ កូនស្រី២នាក់ ថ្ងៃទី៣ ខែ៣ ឆ្នាំ១៩៧៦ ត្រូវឃាត់ខ្លួននៅមន្ទីរ១៥ ស្រុកកោះធំ តំបន់២៥ ផ្ទះ០៨ បន្ទប់ធំ៦ ។ ថ្ងៃមក ដល់មន្ទីរស-២១ៈ ខែមីនា ឆ្នាំ១៩៧៦ ថ្ងៃកម្ទេចៈ ថ្ងៃ៣ ខែ ឧសភា ឆ្នាំ១៩៧៦ ។

### ប្រវត្តិអ្នកទោស ស៊ីសុវត្ថិ កេតារ៉ាវ៉ាក់

ឈ្មោះ ស៊ីសុវត្ថិ កេតារ៉ាវ៉ាក់ ហៅក្រៅ កេត អាយុ៨៥ឆ្នាំ ជាតិខ្មែរ ភេទស្រី ទីលំនៅកំណើតៈ កើតនៅភ្នំពេញ មាននាទីជាមេផ្ទះ បច្ចុប្បន្នប្រជាជន ឪពុកឈ្មោះព្រះអង្គម្ចាស់ ខាន់ណារៈ ម្តាយឈ្មោះ អ្នកម្នាងគួ ប្តីឈ្មោះ ឃួន ហេង មានកូនប្រុស២នាក់ កូនស្រី២នាក់ ។ ដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ ត្រូវឃាត់ខ្លួននៅវត្តនិរោធ បន្ទប់ធំ០៤ ។ ចូលមក ដល់មន្ទីរស-២១ ថ្ងៃ១-៣-៧៦ (កម្ទេច) ។

### ប្រវត្តិអ្នកទោស ស៊ីសុវត្ថិ ដួងខារ៉ា

ឈ្មោះ ស៊ីសុវត្ថិ ដួងខារ៉ា ហៅ ហ៊ុត អាយុ៤៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ មានកម្ពស់១ម៦០ សម្បុរសជ្រះ ដំណើរ ញាប់ មុខធំមូល ចិញ្ចើមធម្មតា ច្រមុះទាល ស្លាកស្នាមគ្មាន ។ ពីមុនធ្វើការនៅភ្នំពេញជាពាណិជ្ជករ បច្ចុប្បន្នធ្វើការនៅភូមិស៊ីធរ ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ។ ដល់ខែ៨ ឆ្នាំ១៩៧៥ ចូលក្រុមបាតុកម្មចូលភ្នំពេញ អ្នកខ្ទេសនាមនិងនាំចូល ហ៊ឹងកន្ទុន មាននាទី ជានាយរងក្រុម និងទទួលផែនការដើរបំផុសបំផុលជនជម្លៀសឲ្យធ្វើបាតុកម្មចូលភ្នំពេញ ។

### ប្រវត្តិអ្នកទោស ម៉ារីយ៉ា

ឈ្មោះ ម៉ារីយ៉ា ហៅ ម៉ារី ជាតិខ្មែរ ភេទប្រុស មាននាទីកូនស្តេច ថ្ងៃទី៨ ខែ១១ ឆ្នាំ១៩៧៦ ត្រូវបានឃាត់ខ្លួននៅមន្ទីរស-២១យ ។

### ប្រវត្តិអ្នកទោស នរៈនរិន ដារ៉ាវិទ្ធ

ឈ្មោះ នរៈនរិន ដារ៉ាវិទ្ធ ហៅ ចិន្តា អាយុ៣៦ឆ្នាំ ភេទស្រី ជាតិខ្មែរ ទីលំនៅយូរអង្វែង ពេទ្យលោកសង្ឃ ភ្នំពេញ ។ មុនឆ្នាំ១៩៧៥ លក់ដូរឥវ៉ាន់នៅផ្សារអូរឫស្សី បច្ចុប្បន្នប្រជាជនសហករណ៍អន្ទង់វុន ស្រុកដូនទាវ តំបន់៣ ឪពុកឈ្មោះ សីហនុ ម្តាយឈ្មោះ កេត បូរី ប្តីឈ្មោះ នួន នីរតី

# ឯកសារសន្តិបាលមន្ទីរស-២១

## នយោបាយ សតិអារម្មណ៍ ចាត់តាំង

### ទស្សនៈគោលជំហរចំពោះខ្មាំងដែលបក្សចាប់មក

១) មនុស្សដែលបក្សចាប់មកមានពីរប្រភេទគឺ៖

ក) វាមានសកម្មភាពខ្លាំងនៅមូលដ្ឋានជាការប្រឆាំងគ្រប់យ៉ាង ជាសេរីទាក់ទងក្រោការចាត់ចាំងជាបន្តបន្ទាប់ហូរហែ ។

ខ) តាមសេចក្តីរាយការណ៍របស់ប្រធានសន្តិបាលយើងហើយដែលបក្សបានពិនិត្យតាមដានច្បាស់ហើយ ។

២) ដូច្នេះយើងកុំស្ទាក់ស្ទើរមន្ទិលសង្ស័យក្នុងសតិអារម្មណ៍ដែលធ្វើឲ្យស្ទះដល់ភារកិច្ចរបស់យើង ទោះអ្នកនោះជាបងប្អូនយើងក៏ដោយ ឬជាមនុស្សយើងធ្លាប់ទុកចិត្តដូចម្តេចក៏ដោយ ។

៣) សំខាន់បំផុតសម្រាប់យើងគឺជឿបក្សដាច់ខាត ។

៤) ផលវិបត្តិម្យ៉ាងដែលមនុស្សវាប្រើឧបាយកលបំភ័ន្តយើងគឺ៖

ក) វាតម្អូរតម្អូញអង្វរករយើង ។ វាធ្វើជាឬកស្លូតបូតសម្តីថាវាមិនក្បត់យើងទេ ។

ខ) វាប្រតិកម្មជេរជៀលត្មះយើង ថាយើងធ្វើបាបវា ថាវានេះមិនមែនជាមនុស្សក្បត់ ជួនរហូតដល់មានប្រតិកម្មធំដុំទៀត ។

គ) វាថាវាសារភាពព្រោះឈឺ ៗល ។ ក្នុងករណីនេះបើយើងពុំទាន់តាមដានវាក្នុងប្រការណាមួយក៏មិនអំណោយដល់ការសួរចម្លើយយើងដែរ ។ ផលវិបត្តិគឺសួរយឺតព្រោះមានមន្ទិលថា មិនមែនខ្មាំង ដូច្នេះខុះម្ចាស់ការហើយឈានទៅបាត់ម្ចាស់ការទៀត ។

៥) វិធានការរបស់យើងគឺ៖

ក) រក្សាទស្សនៈឲ្យវារស់យូរដើម្បីយកចម្លើយជូនបក្ស ។

ខ) កុំបណ្តែតបណ្តោយឲ្យវាតម្អូរតម្អូញ ឬមានប្រតិកម្ម



កម្មាភិបាលខ្មែរក្រហម

ក) ត្រូវខំឃោសនាជាមួយវា ធ្វើឲ្យវាមើលឃើញថាបក្សចាប់វាមកមិនច្រឡំទេ ។

- សារភាពជូនបក្សឲ្យវារស់កុំឲ្យវាផាប់ជួសមេ ឲ្យវានឹកដល់ប្រពន្ធកូនវា ។

- គ្មាននរណាជួយវាទេ ឲ្យវាជឿលើបក្ស ដូចនេះយើងបំបែកបំបាក់ឲ្យវាលែងទុកចិត្តគ្នាវា មេវា ផែនការវា ។

- សន្តិបាលនេះជាសន្តិបាលបក្ស ដូច្នេះពុំចាំបាច់តែចាប់សម្លាប់ទេ ។

- តែយើងកុំមានមោទនភាពមិនបដិវត្តន៍ បំពាក់ថាយើងជាសន្តិបាលបក្ស ។

សរុបទៅគឺធ្វើយ៉ាងណាឲ្យវាស្រពេចស្រពិលពីបញ្ហារស់-ស្លាប់ នៅសង្ឃឹមថាវាអាចរស់ ។

ឃ) ត្រូវកំណត់ទស្សនៈថា បញ្ហាទុកវាឲ្យរស់នៅ ឬសុំរឿងវា ឬកម្ទេចវា គឺស្រេចនៅលើបក្សវិនិច្ឆ័យ ចំពោះយើងគឺយើងធ្វើដូចម្តេចឲ្យតែបានចម្លើយជូនបក្សនេះជាភារកិច្ចខ្ពង់ខ្ពស់



កុយ ធួន



អ្នកទោសជ្រះស្រឡះក្នុងការឆ្លើយទោះយើងធ្វើទារុណកម្មក្រោយមកក៏ដោយ ក៏ធ្វើឲ្យវាឆាប់សារភាព ។ គ្រាន់បើជាងយើងគិតតែរឹមិនគិតឃោសនាសោះក្នុងការធ្វើនយោបាយគឺទាមទារដើហរអត់ធ្មត់បំផុតកុំតក់ក្រហល់ ។

រូបភាពឃោសនាដែលយើងធ្វើការកន្លងមកគឺ÷

ក) លួងលោមឲ្យនេះឲ្យនោះស៊ី លួងលោមថាខាងបក្សឲ្យឋានៈវិញ ។

ខ) សម្លុតកំហ៊ើញ បង្កើ បំបែកបំបាក់ដោយការប៉ិនប្រសប់រៀបចំឆាកតូចៗ ធ្វើឲ្យវាស្លុតអស់សង្ឃឹមថាមិនអាចរឹងរូសតទៅទៀតបានទេ ។

គ) នាំវានិយាយលេងសើចខ្លះតែថ្លៃថ្នូរនិងមានប្រយោជន៍ ។

ឃ) អូសទាញមនោសញ្ចេតនាឲ្យវាវិលវល់ក្នុងវង្វង់គ្រួសារ ប្រពន្ធ កូន អាយុជីវិតវា ។ ដោយបញ្ជាក់ថាទោសវាតូចទេ ។ ពេលវាសារភាពក្តី មិនទាន់សារភាពក្តី យើងត្រូវណែនាំវាជាប់ជានិច្ចអំពីខ្លួនវាមិនមែនជាមេធំទេ កុំរឹងរូសនាំឲ្យរឿងកាន់តែធំ កុំឲ្យធ្វើទារុណកម្មទាន់ ឬធ្វើអ្វីធ្ងន់ទៀតនាំឲ្យលំបាកដល់សុខភាពផង និងលំបាកមើលមុខគ្នាទៅថ្ងៃក្រោយផង ។

ង) និយាយរឿងតូចធ្វើឲ្យរឿងវាធំ បើរាយការណ៍រឿងនោះជូនអង្គការវាធូរស្រាលវិញ ។

ច) និយាយមួលបង្កាច់អ្នកបដិវត្តន៍ថាក្បត់ ធ្វើឲ្យខ្លួនវាធ្លាក់ក្នុងឧបាយកលបំផ្លាញកម្លាំងបដិវត្តន៍ ដូច្នេះទោសក៏នៅធ្ងន់ដដែល ។

ឆ) បើវាថាមានគ្នីគ្នាវាចាប់មកមុនគឺត្រូវលើកសរសើរថាពួកមុនរាយការណ៍ច្បាស់អំពីខ្លួនឯងនិងមេវាជូនអង្គការហើយ យើងចោទប្រកាន់ជាប់ជានិច្ចថា នៅមិនទាន់ស្មោះត្រង់ដោយលើកចំណុចខ្សោយវាមកសង្កត់សួរកុំឲ្យវាប្រកែករួច ។

ជ) ចៀសវាងកុំឃោសនាឲ្យវាក្តាប់ចំណុចខ្សោយរបស់

របស់យើង ។

## ទស្សនៈគោលជំហរចំពោះវិធីសួរចម្លើយ

១) វិធានការសម្រាប់យើងម្នាក់ៗក្នុងពេលសួរចម្លើយវាមានពីរយ៉ាង÷

ក) កៀបខាងនយោបាយ គឺយើងឃោសនាកៀបវាជាប់ជានិច្ច ជាបន្តបន្ទាប់គ្រប់ពេលវេលា ។

ខ) ធ្វើទារុណកម្មជាវិធានការរួមផ្សំ ។

២) ពិសោធន៍កន្លងមករបស់មិត្តយើងអ្នកសួរចម្លើយគឺច្រើនធ្លាក់ទៅខាងទារុណកម្ម មើលធ្ងន់ទារុណកម្ម ទៅជាការឃោសនា នេះជាពិសោធន៍ខុសឆ្គងដែលយើងត្រូវបំពាក់ជាប់ជាច់ខាត ។

៣) ខ្មាំងពុំឆ្លើយសារភាពឲ្យយើងស្រួល សារភាពពេលយើងធ្វើនយោបាយក៏វាសារភាពក្នុងកម្រិតទាបបំផុត ចៀសមិនផុតពីទារុណកម្មទេ ។ គ្រាន់តែខុសត្រង់តិចឬច្រើនប៉ុណ្ណោះ តែទុកជាទារុណកម្មជាវិធានការចាំបាច់យ៉ាងនេះក៏ដោយ ក៏យើងត្រូវតែខិតខំធ្វើនយោបាយឲ្យវាសារភាពយើងដាច់ខាតជាប់ជានិច្ចទាល់តែយើងកៀបវាខាងនយោបាយ ច្រកខាងនយោបាយឲ្យវាសារភាព ទើបទៅទារុណកម្មបានដល់ ។

ការដែលយើងខិតខំធ្វើនយោបាយ គឺយើងធ្វើមានសភាពខាងឃោសនាមិនជាន់កែងឯង ។ នេះម្យ៉ាង ម្យ៉ាងទៀតគឺធ្វើឲ្យ

យើងបាន ដូចជាវាដឹងថាយើងចង់ឲ្យវាសារភាពពីនរណា ពីសកម្មភាពអ្វី ។

ឈ) ដាក់សំណួរឲ្យចំទិសហើយនឹងនរ កុំលោភលន់បញ្ហាស្មុគស្មាញដែលធ្វើឲ្យពិបាកឆ្លើយ ហើយវាពុំដឹងយើងសួរអំពីអ្វី ។

៤) បញ្ហាធ្វើទារុណកម្មៈ

ក) សំណូមពរនៃការធ្វើទារុណកម្មគឺយកចម្លើយរបស់វា ពុំមែនធ្វើដើម្បីសប្បាយទេ ដូចនេះត្រូវធ្វើឲ្យវាឈឺដើម្បីឲ្យវាឆាប់ឆ្លើយ ។

សំណូមពរម្យ៉ាងទៀតគឺកាច់វាឲ្យខ្លាចឲ្យបាក់ស្បាត មិនមែនធ្វើតាមកំហឹងបុគ្គលឲ្យអស់ក្តៅ ដូចនេះគឺវៃឲ្យវាខ្លាចតែមិនឲ្យងាប់ដាច់ខាត ។ ពេលធ្វើទារុណកម្មត្រូវពិនិត្យសុខភាពវាមុន ត្រូវពិនិត្យមើលរំពាត់ ។ កុំលោភចង់ឆាប់នាំស្លាប់បាត់ឯកសារខាត ។

ខ) ត្រូវជ្រួតជ្រាបថាធ្វើនយោបាយគឺសំខាន់ណាស់ គឺចាំបាច់ចំណែកឯទារុណកម្មជារឿងបន្ទាប់ ជាបញ្ហារួមផ្សំនឹងនយោបាយក្នុងចំណែកណាមួយប៉ុណ្ណោះ ។ ដូចនេះបញ្ហាធ្វើនយោបាយគឺដើរតួគ្រប់ម៉ោងពេល សូម្បីតែធ្វើទារុណកម្មក៏ត្រូវឃោសនាជាប់ជានិច្ចដែរ ។

គ) ជាមួយនេះក៏ត្រូវចៀសវាងបញ្ហាស្ទាក់ស្ទើរមិនហ៊ានធ្វើទារុណកម្មដែរ ដែលធ្វើឲ្យសួរចម្លើយខ្មាំងមិនចេញនាំឲ្យការងារយឺតយូរការងារយើង ។ សរុបទៅឃោសនាក្តី ធ្វើទារុណកម្មក្តី លើកសំណួរសួរវាក្តី ចោទប្រកាន់វាក្តី ត្រូវប្រកាន់ជំហរម៉ឺងម៉ាត់ កុំស្ទាក់ស្ទើរ ត្រូវដាច់ខាត នោះទើបមានប្រសិទ្ធភាពល្អ ។

៥) ដូចម្តេចបានជាខ្មាំងមានប្រតិកម្មៈ

ក) មូលហេតុសំខាន់បំផុតគឺយើងចាញ់ប្រៀបនយោបាយវាពេលយើងឃោសនា ឬពេលយើងធ្វើទារុណកម្មដំបូង ។ ឧទាហរណ៍ៈ យើងតក់ក្រហល់ពេក ឃោសនាជាន់កែងឯង ។ ឧទាហរណ៍ៈ ធ្វើទារុណកម្មលើវា ដោយភ្លេចត្រៀមយថាហេតុមុនធ្វើឲ្យវាអស់សង្ឃឹម ។

ខ) គុណវិបត្តិផ្តល់ឲ្យយើងពេលវាប្រតិកម្មនេះ ឬម្យ៉ាងផ្អើលគេឯង សំខាន់បំផុតអាចរងគ្រោះថ្នាក់ដល់យើងនិងមិត្តដទៃម្យ៉ាងផ្អើលរំខានការងារមិត្តដទៃទៀត ។ តែសំខាន់បំផុតពេលវាប្រតិកម្មហើយគឺឲ្យខ្លួនយើងមានមន្ទិលក្នុងសតិអារម្មណ៍ជាប់ដោយបារម្ភក្រែងវាមានប្រតិកម្មទៀត ជួនញញើតញញើមវាជួនចេះតែក្តៅក្រហាយនឹងវា ធ្វើឲ្យយើងបាត់ម្ចាស់ការ ហើយចំណែកវាវិញ ជួនក៏ធ្វើឲ្យមានសតិអារម្មណ៍មិនអស់មិនហើយវិលវល់គិតគូបញ្ហាស្លាប់-រស់ ជួនវាគិតផ្សេងពីនេះ ។

គ) វិធានការទប់ទល់របស់យើងៈ

ដំបូងបំផុតយើងឃោសនារំពុកវាអំពីសតិអារម្មណ៍អត្តការវិន័យ និងឧបាយកលរបស់អ្នកមានខ្លួន ពេលជាប់ឃុំឃាំងនេះគឺមានប្រតិកម្មមិនចេះចប់គ្រប់ខ្នាត ។ យើងឃោសនាក្នុងគោលបំណងស្រះដូវបង្ការមុន សង្កេតទឹកមុខនិងអាកប្បកិរិយាវាជាប់ ។ បើវាផ្លាស់ប្តូរប្រុងមានប្រតិកម្មគឺត្រូវដើរចេញ កុំឆេវឆាវវាយវា ។ ធ្វើដូចម្តេចកុំឲ្យម្ចាស់ការមុនយើង ឧទាហរណ៍វារង់ចាំឲ្យយើងតមាត់ជាមួយវា ឬជេរវា ឬវាយវា វាន្ទាលនឹងជេរយើងវាយយើងវិញ ។ ដូចនេះបើយើងភ្ញាត់ស្មៀតមិនអត់ធ្មត់ គឺវាម្ចាស់ការវាប្រតិកម្មបាន ។

ដើម្បីចៀសវាងប្រតិកម្មនេះគឺយើងត្រូវម្ចាស់ការបំបែកសតិអារម្មណ៍វាឲ្យគិតបញ្ហាផ្សេងទៀត ដូចជាឲ្យវានឹកឃើញគ្រួសារឪពុកម្តាយ ប្រពន្ធកូនវា អាយុជីវិតវា ។ល ។

ឃ) ប្រជុំពិសោធន៍មួយ ពេលខ្មាំងផ្ទៃក្នុងរត់រួចគឺជាបរាជ័យដ៏ធ្ងន់របស់ក្រសួងសន្តិបាលយើងជាងលើកណាៗទាំងអស់ពីព្រោះវាជាខ្មាំងផ្ទៃក្នុង ។ បរាជ័យនេះមានអត្ថន័យពីរយ៉ាងគឺ÷

-បែកការសម្ងាត់ៈ ការសម្ងាត់ដែលយើងថែរក្សាពីរ-បីខែកន្លងមកនេះត្រូវផ្ទុះធ្លាយជ្រៅទូលាយណាស់ វាទៅនិយាយខ្ទេចខ្ទីអំពីចម្លើយវា ។ អស់ការសម្ងាត់គឺអស់អ្វីដែលហៅថាសន្តិបាលហើយ អស់ន័យរលីង ។ ឧត្តមគតិរបស់ជនកុម្មុយនិស្តគឺបម្រើបក្ស ។ យើងមិនចង់ឲ្យបក្សលំបាកដោះស្រាយយើងដាច់ខាត តែលើកនេះបក្សលំបាកដោះស្រាយយើង ។ បក្សកំពុងដោះស្រាយរឿងនេះ ន័យយើងបម្រើបក្សត្រូវរលំរលាយហើយ ។

-គិញរត់រួចយើងមិនទាន់សម្រេចសំណូមពរចាប់បានដោយដៃយើងម្តងទេ ។ មិនមែនជាបរាជ័យទេ តែជាការខុះខាតរបស់យើង ដែលយើងត្រូវដោះស្រាយជាបន្ទាន់បំផុត ។ មូលហេតុគឺយើងទាំងអស់គ្នាមើលស្រាលចំពោះករណីគិញរត់រួចពីកន្លែងសួរ ។

**(ឯកសារមន្ទីរស-២១)**

# ភោគ ឆាយ មុនពេលក្លាយទៅជាអ្នកទោស

**(តពីលេខមុន)** ចាប់ពីដើមឆ្នាំ១៩៦៧ ពិពណ៌ត្រូវបានបើក មានមហាជនកុះករមកចូលរួមទស្សនានិងទិញវត្ថុសិល្បៈជារៀង រាល់ថ្ងៃ ។ ពេលនោះស្រាប់តែសម្តេច សីហនុ ស្រែកជេរសមាគម មិត្តភាពខ្មែរ-ចិនថា មើលងាយគាត់ដោយយករូប ម៉ៅ សេទុង ធំខ្ពស់ទៅដាក់សង្កត់លើរូបគាត់ដែលទាបតូច ។ ឡុង ង៉ែត ជា ប្រធានសមាគមមិត្តភាពខ្មែរ-ចិនបានលាឈប់ ហើយទម្លាក់ បញ្ហានេះទៅឲ្យ ហ៊ូ នឹម ជាអ្នកទទួលខុសត្រូវ ។ បន្ទាប់មក សូ ណែម និងមនុស្សមួយចំនួនទៀតក៏លាឈប់ដែរ ។ ហ៊ូ នឹម ក៏ ឡើងជាប្រធានស្តីទីរបស់សមាគមមិត្តភាពខ្មែរ-ចិន តែងតាំង ភោគ ឆាយ ជាអគ្គលេខាធិការជាបណ្តោះអាសន្នទម្រាំសមាគម រៀបចំឡើងវិញ ។ ក្រៅពីនេះនៅក្នុងគណៈកម្មាធិការសមាគម នៅសល់សមាជិកប៉ុន្មាននាក់ទៀតគឺ ហ៊ូ យន់, វ៉ាន់ ទិព្វសុវណ្ណ, ទីវ អុល, កែ គឹមហួត, ព្រាំ សំអាវ, គឹម សេង (បងថ្លៃរបស់ ហ៊ូ យន់) និងទីប្រឹក្សាពីរ-បីនាក់ទៀត ។

តាំងពីចូលជាសមាជិក សេ.អុ.អា មក ភោគ ឆាយ តែងតែទៅខេត្តបាត់ដំបងជាមួយ វ៉ាន់ ទិព្វសុវណ្ណ និង គី សៀនហូ នៅរៀងរាល់ពេលបុណ្យចូលឆ្នាំខ្មែរ ក្នុងបំណងទៅពិនិត្យភូមិសាស្ត្រ ក្នុងព្រៃឲ្យបានច្បាស់លាស់ ត្រៀមបោះទីតាំងនៅពេលណាដែល ឱកាសមកដល់ ។ នៅខែមេសា ឆ្នាំ១៩៦៧ អ្នកទាំងបីបានទៅ ខេត្តបាត់ដំបងម្តងទៀត ។ លើកនេះពួកគេទៅរហូតដល់ភ្នំក្រពើពីរ ។ នៅទីនេះអ្នកទាំងបីកំណត់នូវភារកិច្ចដែលត្រូវធ្វើដូចតទៅ÷

១) ត្រូវយកភ្នំក្រពើពីរធ្វើជាមូលដ្ឋានកាលណាសង្គ្រាម ផ្ទុះឡើង ។

២) បែកភារកិច្ចគ្នាគឺ ភោគ ឆាយ ត្រូវទទួលភារកិច្ច ដោយឡែកខាងនយោបាយ យុវជន និងប្រជាជនទីក្រុង ។ វ៉ាន់ ទិព្វសុវណ្ណ ទទួលភារកិច្ចខាងយោធានិងប្រជាកសិករ ។ រីឯ គី សៀនហូ ទទួលខាងដឹកជញ្ជូន ផ្គត់ផ្គង់ និងសម្ភារ ។

ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៧ «រដ្ឋាភិបាល» ស្តេច សីហនុ ប្រកាសថា ខៀវ សំផន និង ហ៊ូ យន់ បានបាត់ខ្លួនទៅ ហើយ ។ ចាប់ពីដើមខែ៥ ឆ្នាំ១៩៦៧ មានគិញរបស់ «រដ្ឋាភិបាល» សីហនុ ជាច្រើនមកហ៊ុមព័ទ្ធផ្ទះនិងកន្លែងធ្វើការរបស់ ភោគ ឆាយ ហើយតាមដានគាត់គ្រប់ជំហាន ។

ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៦៧ «រដ្ឋាភិបាល» ស្តេច សីហនុ បានប្រកាសបិទសមាគមនិស្សិត ហើយថ្ងៃ៣០ ខែ កញ្ញា ប្រកាសបិទសមាគមមិត្តភាពខ្មែរ-ចិនទៀត ។ ពួកនិស្សិត មានការខឹងសម្បារយ៉ាងខ្លាំងនាំគ្នាបោះខិតប័ណ្ណព្រោងព្រាត ប្រឆាំងនឹង «រដ្ឋាភិបាល» ស្តេច សីហនុ ដោយចោទថា សីហនុ ធ្វើខុសនឹងរដ្ឋធម្មនុញ្ញ ។

ល្ងាចថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៦៧ ភោគ ឆាយ បានទៅចូលរួមពិធីជប់លៀងមួយដែលរៀបចំឡើងដោយសមាគម មិត្តភាពខ្មែរ-ចិន ដើម្បីប្រកាសបញ្ចប់សកម្មភាពរបស់សមាគម មិត្តភាពខ្មែរ-ចិនដែល «រដ្ឋាភិបាល» ស្តេច សីហនុ បានប្រកាស បិទ និងដើម្បីថ្លែងអំណរគុណចំពោះសមាជិកទាំងអស់ដែលបាន ឧបត្ថម្ភគាំទ្រសមាគមជារៀងរហូតមក ។ កន្លែងធ្វើពិធីនៅតាម បណ្តោយផ្លូវជាតិលេខ១ក្បែរធនាគារឥណទានជាតិ មានភ្ញៀវ ប្រមាណ២០០នាក់មកចូលរួម មិនតែប៉ុណ្ណោះឯកអគ្គរដ្ឋទូតចិន ឈ្មោះ ឆេន ស៊ូលាង និងបុគ្គលិកទាំងអស់របស់ស្ថានទូតចិន ក៏បានចូលរួមដែរ ។ ហ៊ូ នឹម ថ្លែងសុន្ទរកថាទទួលអំណរភ្ញៀវ យ៉ាងខ្លី បន្ទាប់មកឯកអគ្គរដ្ឋទូតចិន ឆេន ស៊ូលាង ក៏ឡើង ថ្លែងនូវមិត្តភាពសាមគ្គីពីរ-បីម៉ាត់ ទើបចាប់ផ្តើមការជប់លៀង អាហារ និងមានការសម្តែងសិល្បៈកម្សាន្តច្រៀងរាំសប្បាយ ។ នៅខាងក្រៅរបងកន្លែងធ្វើពិធី គិញប្រហែល៥០-៦០នាក់ ដកករហង់មើលមកខាងក្នុង ។ ស្អែកឡើងថ្ងៃទី៤ ខែតុលា «រដ្ឋាភិបាល» ស្តេច សីហនុ ស្រែកជេរសមាគមមិត្តភាពខ្មែរ-ចិនថា ទី១-គាត់ប្រកាសបិទហើយម៉េចនៅបន្តសកម្មភាពទៀត ទី២-បើអស់សមាគមហើយ ហ៊ូ នឹម នៅថ្លែងសុន្ទរកថាពី សមាគមអីទៀត ទី៣-ទូតចិន សម្តែងមិត្តភាព និងសាមគ្គីភាព យ៉ាងនេះគឺចូលក្នុងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជាផង ។

ចាប់តាំងពីថ្ងៃនោះមក កោក ឆាយ លែងហ៊ានចេញទៅណាផ្ដេសផ្ដាសទៀតហើយ ។

ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៦៧ វិទ្យុប្រកាសថា ហ៊ូ នឹម បានបាត់ខ្លួនពីផ្ទះ ។ ហើយនៅថ្ងៃទី១០ កោក ឆាយ ត្រូវប៉ូលិសចាប់ដាក់គុក ។ ដើមខែ៤ ឆ្នាំ១៩៦៨ ក្រោយជាប់គុកបាន៧ខែ កោក ឆាយ, ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត ។ មួយខែក្រោយមក កោក ឆាយ ត្រូវបាន «រដ្ឋាភិបាល» ស្ដេច សីហនុ បន្ថយទោសមកនៅត្រឹមជាប់គុកអស់មួយជីវិតវិញ ។ នៅក្នុងគុក កោក ឆាយ បានទំនាក់ទំនងជាមួយឈ្មោះ នន សួន អ្នកទោសដូចគ្នា តែទទួលភារៈជាចុងភៅជាខ្សែរយៈរបស់ គី សៀនហូ ដែរ ។ ក្រៅពីធ្វើជាចុងភៅ នន សួន ធ្វើជាជាងឈើនៅ បរិវេណគុកខាងក្រៅ (ក្នុងវង្វង់របងជាន់ទី១) ដើម្បីអាចទំនាក់ទំនងជាមួយសាច់ញាតិក្រុមគ្រួសាររបស់គាត់ ហើយតាមរយៈវិធីនេះទើបគាត់អាចទំនាក់ទំនងរៀបចំបណ្ដាញខ្សែបក្សនៅទីក្រុងភ្នំពេញ និងជនបទបានឡើងវិញ ។

ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៦៩ «រដ្ឋាភិបាល» ស្ដេច សីហនុ ប្រកាសដោះលែង កោក ឆាយ ឲ្យមានសេរីភាពវិញ តែរហូតដល់ខែ២ ឆ្នាំ១៩៧០ ទើបគាត់បានរួចចេញពីគុក ។ ទោះជារួចពីគុកហើយក៏ដោយតែ កោក ឆាយ នៅតែត្រូវគិញតាមដានរហូតដល់ចុងខែ២ទើបឈប់ ។ ក្នុងដើមខែ៣ កោក ឆាយ បានជួប គី សៀនហូ ហើយបានដឹងថា វ៉ាន់ ទិព្វសុវណ្ណ ក៏ត្រូវចាប់ខ្លួនក្រោយគាត់តែបន្តិច ឥឡូវនេះ (ឆ្នាំ១៩៧០) បានស្លាប់បាត់ទៅហើយ ។ កោក ឆាយ បានទៅសុំធ្វើការងារជាមួយ ង៉ុយ កាន់ ដែលត្រូវជាសាច់ញាតិខាងភរិយារបស់គាត់ (នៅក្នុងចម្លើយសារភាពជាលើកទី៣ កោក ឆាយ និយាយថា ង៉ុយ កាន់ ត្រូវជាសាច់ញាតិជីដូនមួយនឹងម្ដាយរបស់គាត់) ។ ង៉ុយ កាន់ ធ្លាប់រត់ទៅហុងកុងមួយសាហើយ ទើបតែត្រឡប់មកវិញនៅឆ្នាំ១៩៦៩ តំណាលពេលគ្នានឹងសិរិមតៈ វិលចូលស្រុកដែរ ។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារដែលដឹកនាំដោយឧត្ដមសេនីយ៍ លន់ ណុល ដើម្បីផ្ដួលរំលំរដ្ឋាភិបាលសីហនុបានផ្ទុះឡើង ។ ល្ងាចថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧០ កោក ឆាយ បានទទួលការចាត់តាំងពី គី សៀនហូ ឲ្យចេញទៅតំបន់រំដោះ ។ កោក ឆាយ ត្រូវព្យាយាមគេចពីការតាមដានរបស់គិញរហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧០ ទើបបានចេញទៅតំបន់រំដោះដោយមានមនុស្សរបស់ តូច គឿន ជាអ្នកនាំផ្លូវទៅតាមច្រកឧដុង្គ សំរោង រហូតទៅដល់ភូមិស្រែអណ្ដូង ក្នុងឃុំពាមខេត្តកំពង់ឆ្នាំង រួចទើបបន្តដំណើរទៅកាន់ភ្នំពីស ។

នៅភ្នំពីស កោក ឆាយ គ្មានការងារអ្វីក្រៅពីស្ដាប់ដំណឹងតាមវិទ្យុតែប៉ុណ្ណោះ ។ រហូតដល់ចុងខែ១២ ទើបមន្ទីរភាគផ្លាស់មកបោះទីតាំងនៅម្នុំអមលាំងវិញ ។ ដើមខែមករា ឆ្នាំ១៩៧៤ កោក ឆាយ ដើរបំពេញបេសកកម្មជាមួយលេខាភាគនៅតំបន់កំពង់ស្ពឺ តាកែវ និងកំពត ដោយដើរធ្វើមិទ្ទីងនៅតាមវត្តនិងភូមិ



អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងស-២១






នានាដល់ខែ៦ ឆ្នាំ ១៩៧៨ ទើបត្រឡប់មកអមលាំងវិញបាន ចូលជាសមាជិកអង្គការបដិវត្តន៍ក្រោម ការជ្រោមជ្រែងរបស់លេខាភូមិភាគ ។

នៅផ្នែកខាងមុខនៃឯកសារចម្លើយសារភាពលើកទីមួយ របស់ ភោគ ឆាយ មានចំណារដែលទំនងជាចំណាររបស់ ឌុច ថា «**អា.ហ៎ ជ.អ.ក ហើយ, ៣០,៣,៧៧**» [**អានហើយ និងជូនអង្គការហើយ**] ។

នៅផ្នែកទីពីរនៃចម្លើយសារភាព មានចំណារបន្ថែមថា «**អានហើយ, ១) វានៅក្រឡិចក្រឡុចចង់សម្រាល ។ វាលែងនិយាយពីអាសីរីមតៈ និងអានាយទុនឈ្មោះនុយកាន់ហើយ ។ ២) តែយើងច្បាស់ថា សេ.អ៊ី.អា តាម វ៉ាន់ ទិព្វសុវណ្ណ ពួកបញ្ញាជនដូចជា ហ៊ូ យន់, ហ៊ូ នឹម, ទីវ អុល, ប៉ុក ដឹសកុមារ, រស់ ជេដ្ឋរ, ព្រំ សំអារ, សូ ណែម ។ល។ យកផ្លាក «អ្នកចំរើន» ១) បង្កើតជាបក្សថ្មីមួយនៅក្រុងភ្នំពេញរួចពង្រីកទូទាំងប្រទេស ។ ២) មួយចំនួន ធ្វើជាចូលព្រៃបក្ខប់ ។ ៣) បើតាមវានិយាយ វ៉ាន់ ទិព្វសុវណ្ណ ជាមនុស្សគន្លឹះកំណត់ថ្នាក់លើ ។ សេ.អ៊ី.អាទេ?**» ។ នៅផ្នែកខាងក្នុងនៃចម្លើយសារភាពមានគូសបន្ទាត់ពីក្រោម ឬគូសស៊ុមព័ទ្ធជុំវិញឈ្មោះមួយចំនួនដូចជា ហ៊ូ នឹម, ហ៊ូ យន់, ទូន សុខជល្លា, ឈុន សុខផ្ទួន, ម៉ៅ រុន, ម៉ៃ សាខន, គី សៀនហូ, ឃុត,នុយកាន់,សិរីមតៈ តូច ភឿន ដោយមានចំណារដែលជាអក្សររបស់ ឌុច ថា «**សេ.អ៊ី.អា ទាំងអស់តែគ្នា**» «**អានេះក៏សេ.អ៊ី.អា**» «**សេ.អ៊ី.អា វាដឹកទាំងអស់**» «**សេ.អ៊ីអា អន្ទង ទាំងអស់**» «**សេ.អ៊ីអា ទៀត**» ។ ទន្ទឹមនឹងនោះ មានគូសបន្ទាត់ក្រោមឃ្លាភ្ជាប់ដោយចំណារមួយចំនួនដូចជាៈ «អត្ថបទសរសើរ អាណុល (លន់ណុល)» «ច្បាស់» «សេ.អ៊ី.អា ភ្ជាប់នឹងខ្សែបដិវត្តន៍ តាមរយៈ តូច ភឿន» «ខុបាយកល សេ.អ៊ី.អា» ។ **សាន់ កល្យាណ**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# ការរៀបចំឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា



កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ដែលចាប់កំណើតនៅឆ្នាំ១៩៩៥ បានចាប់ផ្តើមកិច្ចការរបស់ខ្លួន ដោយស្វែងរកទាំងឯកសារដែលត្រូវបានស្គាល់រួចមកហើយនិង ឯកសារផ្សេងៗដែលមិនដែលបានជួបប្រទះពីមុនមក ។ កម្មវិធីនេះ បានប្រឈមមុខដោះស្រាយបញ្ចូលឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ទៅ ក្នុងប្រព័ន្ធទិន្នន័យជាច្រើនប្រភេទទៅតាមប្រភេទទិន្នន័យឯកសារ ដែលប្រមូលបានរួមមាន ឯកសារជាក្រដាស ជារូបថត និងហ្វីល កសិណសាក្សីផ្ទាល់មាត់ ទីតាំងភូមិសាស្ត្រ រូបថត (តាមជនបទ ដាច់ស្រយាល) ដែលមានច្រើនភាសា (សំខាន់ជាភាសាខ្មែរ បារាំង និងអង់គ្លេស និងភាសាផ្សេងៗទៀតដូចជា វៀតណាម ថៃ ចិន រុស្ស៊ី) ។ ទិន្នន័យឯកសារទាំងនេះតម្កល់នៅក្នុងទីតាំងផ្សេងៗ ជាច្រើនដូចជាប្រទេសកម្ពុជា វៀតណាម សហរដ្ឋអាមេរិក អូស្ត្រាលីនិងប្រទេសផ្សេងៗទៀត ដោយមានក្រុមដែលមាន សមាជិកចំនួនប្រមាណ៥០ នៅក្នុងការិយាល័យ៣ ធ្វើការនៅក្រុង ភ្នំពេញ ក្រុងញូហេវិនសហរដ្ឋអាមេរិក និងក្រុងស៊ីដនី ប្រទេស អូស្ត្រាលី ។

បទដ្ឋានអន្តរជាតិដែលមានរួចមកហើយ (ដូចជាទម្រង់ កាតាឡុកដែលអាចអានដោយប្រព័ន្ធកុំព្យូទ័រ និងលេខកូដសិទ្ធិ មនុស្ស) ត្រូវតែបានអនុវត្តនិងពង្រីកបន្តទៅទៀតដើម្បីដោះស្រាយ ជាមួយទិន្នន័យដ៏ច្រើនលើសលប់ខុសពីធម្មតានេះ ហើយពត៌មាន នៅក្នុងប្រព័ន្ធកុំព្យូទ័រត្រូវបានជំរុញលើកកម្ពស់ប្រសិទ្ធភាពដើម្បី ដោះស្រាយកិច្ចការថ្មីៗ និងកិច្ចការដ៏លំបាកៗផ្សេងៗទៀត (ដូចជាការបង្ហាញអក្សរខ្មែរនៅលើអេក្រង់ ការភ្ជាប់ឯកសារ ជាមួយនឹងឯកសាររូបភាពផ្សេងៗដែលពាក់ព័ន្ធនឹងឯកសារនោះ ព្រមទាំងបញ្ចូលឯកសារ និងរូបភាពទាំងអស់នេះទៅក្នុងប្រព័ន្ធ អ៊ីនធ័រណែត) ។

ក្រៅពីការសម្រេចគោលដៅនៃកិច្ចការសិក្សាស្រាវជ្រាវ នេះយើងត្រូវការយកចិត្តទុកដាក់ខ្ពស់ចំពោះទិន្នន័យទាំងអស់ ទាំងលើបញ្ហារក្សាភាពដើមនិងបញ្ហាសន្តិសុខនេះ ក៏ដោយសារ តែមានការកើនឡើងយ៉ាងខ្លាំងនូវភាពចាំបាច់ក្នុងការប្រើប្រាស់ ឯកសារទាំងនេះជាភ័ស្តុតាងក្នុងការជំនុំ ជម្រះក្តីនាពេលអនាគត ។ ដោយមិនចាំ បាច់និយាយដល់ការផ្សព្វផ្សាយយ៉ាង សន្ធឹកសន្ធាប់តាមបណ្តាញសារពត៌មានឥត ដាច់ ការចាប់អារម្មណ៍ដ៏ធំខាងនយោបាយ លើបញ្ហានោះ វត្តមាននិងការគំរាមកំហែង របស់ពួកខ្មែរក្រហមជាពិសេសនៅដើមឆ្នាំ នៃកិច្ចការសិក្សាស្រាវជ្រាវបានទាមទាឲ្យមាន ការប្រុងប្រយ័ត្នជានិច្ចចំពោះបញ្ហាសន្តិសុខ ទាំងបុគ្គលិកនិងការថែរក្សាឯកសារ ។ មិន តែប៉ុណ្ណោះតម្រូវឲ្យមានការផ្សព្វផ្សាយ កម្រិតខ្ពស់និងការគិតគូរយ៉ាងប្រយ័ត្ន ប្រយែងដល់ភាពងាយប្រេះស្រាំក្នុងការ បញ្ចេញផ្សាយនូវលទ្ធផលស្រាវជ្រាវជា សាធារណៈ ជាពិសេសការគោរពដល់ការ ចងចាំដល់ជនរងគ្រោះដែលបានសម្លាប់ និងសិទ្ធិឯកជនក៏ដូចជាភាពថ្លៃថ្នូរនៃជន ដែលនៅរស់រានមានជីវិតពីរបបប្រល័យ ពូជសាសន៍ខ្មែរក្រហម ។

### ទិន្នន័យប្រព័ន្ធកុំព្យូទ័រស្តីអំពី ខគ្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជា ហៅកាត់ថា ស៊ីជីឌីប៊ី (CGDB)

យើងបានបង្កើតទិន្នន័យធំមួយ ហៅថាទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រស្តីអំពីខគ្រិដ្ឋកម្មប្រល័យពូជ សាសន៍នៅកម្ពុជា (ស៊ីជីឌីប៊ី) នៅក្នុងនោះយើងរៀបចំជា គន្ថនិទ្ទេសនៃប្រវត្តិរូប ភូមិសាស្ត្រ និងឯកសារ រូបថតផ្សេងៗ ។ ប្រព័ន្ធទិន្នន័យក្នុងកុំព្យូទ័រនេះរួមមានប្រព័ន្ធគន្ថនិទ្ទេស (CBIB) ប្រព័ន្ធទិន្នន័យប្រវត្តិរូប (CBIO) ប្រព័ន្ធទិន្នន័យភូមិសាស្ត្រ (រណ្តៅសាកសព) (CGEO) និងប្រព័ន្ធទិន្នន័យរូបភាព (CIMG) ។

### ប្រព័ន្ធទិន្នន័យគន្ថនិទេស ហៅកាត់ថា ស៊ីប៊ីប (CBIB)



បណ្ណសារដ្ឋានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងក្នុងទសវត្សរ៍ឆ្នាំ៨០

នៅពេលចាប់ផ្តើមប្រព័ន្ធទិន្នន័យនេះនៅខែមករា ឆ្នាំ ១៩៩៧ ប្រព័ន្ធទិន្នន័យនេះមានឯកសារចំនួន២០០០ ដែលរួមមានពត៌មានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យជាច្រើន ។ ហើយនៅខែតុលា ឆ្នាំ១៩៩៩ ឯកសារក្នុងប្រព័ន្ធទិន្នន័យនេះបានកើនឡើងទៅដល់ជាង៣៤០០ឯកសារដោយមិនរួមបញ្ចូលទាំងឯកសាររាប់ពាន់ ដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំឯកសារ ។ ឯកសារដែលត្រូវបានប្រមែប្រមូលនៅក្នុងទីក្រុងភ្នំពេញដោយមជ្ឈមណ្ឌលឯកសារកម្ពុជាចាប់តាំងពីការចាប់ផ្តើមការងាររបស់កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជាបានប្រែក្លាយទៅជាឯកសារមានប្រយោជន៍យ៉ាងខ្លាំង ហើយការប្រមែប្រមូលចេះតែមានដំណើរទៅមុខ ។ យើងកំពុងតែជួបប្រទះឯកសារជាច្រើននិងសំខាន់ៗជាងអ្វីដែលយើងធ្លាប់បានគិតទុកពីមុន ។ ឯកសារទាំងអស់នេះរួមមានពត៌មានជាច្រើនដូចជាចម្លើយសារភាព រូបថត សៀវភៅកំណត់ហេតុពីមន្ទីរ

ស-២១ និងរបាយការណ៍ផ្ទាល់ខ្លួនមកពីគុកទួលស្លែងដែលស្ថិតនៅក្នុងក្រុងភ្នំពេញ ក៏ដូចជាមកពីអង្គការសន្តិសុខរបស់ខ្មែរក្រហមនៅតាមកន្លែងផ្សេងៗទៀត ។

## ក) ឯកសារនៃតុលាការប្រជាជនបដិវត្តន៍កម្ពុជា

ឯកសារប្រភេទទី១ដែលនឹងត្រូវរាប់បញ្ចូលគឺឯកសារតុលាការប្រជាជនបដិវត្តន៍កម្ពុជាធ្វើឡើងនៅខែសីហា ឆ្នាំ១៩៧៩ ជាពេលដែលរដ្ឋាភិបាលកម្ពុជាធ្វើការកាត់ទោសកំបាំងមុខប្រហារជីវិត ប៉ុល ពត និង អៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ឯកសារនេះត្រូវបានតម្កល់ទុកនៅឯបណ្ណសារដ្ឋានជាតិកម្ពុជាមួយច្បាប់ក្នុងសភាពទ្រុឌទ្រោមគួរឲ្យសោកស្តាយ ។ នៅឆ្នាំ១៩៩៥ ខ្ញុំបានទទួលការអនុញ្ញាតយកឯកសារមួយច្បាប់ត្រឡប់ទៅប្រទេសអូស្ត្រាលី ហើយដោយមានអំណោយឧបត្ថម្ភពីក្រុមប្រឹក្សាសិក្សាស្រាវជ្រាវរបស់អូស្ត្រាលី ឯកសារទាំងអស់នោះត្រូវបានធ្វើកាតាឡុក ហើយភាសាផ្សេងៗដែលប្រើប្រាស់នៅក្នុងតុលាការ (ខ្មែរ បារាំង និងអង់គ្លេស) គឺមានការទាក់ទងគ្នានិងត្រូវបានភ្ជាប់ជាមួយនឹងរូបភាពឯកសារដែលស្កេន (Scan) ហើយ ។

## ខ) ឯកសាររណសិរ្ស

នៅឆ្នាំ១៩៩៥ យើងទទួលបាននូវជម្រើសឯកសារដែលត្រូវបានដាក់ឈ្មោះថា «ឯកសាររាប់លាន» ពីរណសិរ្សកសាងការពារមាតុភូមិកម្ពុជា ។ ក៏ប៉ុន្តែឯកសារទាំងអស់រួមមានតែជាង១ម៉ឺនប៉ុណ្ណោះដែលមានហត្ថលេខា ឬស្នាមមេដៃនៃប្រជាជនប្រហែលជាជាងមួយលាននាក់ដែលបានធ្វើញត្តិ ។ នៅឆ្នាំ១៩៨២-៨៣ គឺក្រោយពីតុលាការប្រជាជនបដិវត្តន៍កម្ពុជាមករដ្ឋាភិបាលបានបង្កើតនូវគណៈកម្មការស្រាវជ្រាវមួយឲ្យចុះតាមខេត្ត ស្រុក ភូមិ ទូទាំងប្រទេសដើម្បីស្វែងរកភ័ស្តុតាងឧក្រិដ្ឋកម្មនានាដែលកើតឡើងក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ។ ក្រៅពីនេះ គណៈកម្មការនេះនៅបានស្នើឲ្យប្រជាជនធ្វើញត្តិទាំងនេះគាំទ្រដល់សាលក្រមរបស់តុលាការកាត់ទោសពួកខ្មែរក្រហមព្រមទាំងបានសុំឲ្យអង្គការសហប្រជាជាតិផ្តល់អសនៈដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីតំណាងឲ្យប្រជាជនកម្ពុជានិងដេញពួកខ្មែរក្រហមដែលកំពុងតែអង្គុយនៅលើអសនៈនោះទោះបីជាខ្លួនលែងកាន់អំណាចតាំងពីឆ្នាំ១៩៧៩ ហើយក៏ដោយ ។ ឯកសាររណសិរ្សវាយទទួលរងការខូចខាតណាស់ហើយ ធ្លាប់ត្រូវបានទុករាយប៉ាយនៅក្រៅប្រអប់តាំងពីឆ្នាំ១៩៨៣មកម្ល៉េះ ។ យើងគិតថា ញត្តិទាំងអស់នេះមិនដែលធ្លាប់ត្រូវបានប្រគល់ជូនដល់ដៃអង្គការសហប្រជាជាតិឡើយ ហើយមកដល់ឥឡូវមិនទាន់ត្រូវបានធ្វើវិភាគឬសង្ខេបនៅឡើយដែរ ។ ភាគច្រើននៃឯកសារទាំងនោះហាក់ដូចជាមានលក្ខណៈជាឯកសារប្រហាក់ប្រហែលគ្នាទូទៅ ឬញត្តិអំពាវនាវឲ្យអង្គការសហប្រជាជាតិជួយចាត់វិធានការ ។ ក្នុងឯកសារភាគច្រើនមាននិយាយថា «**នៅក្នុងភូមិយើងមានមនុស្សច្រើនណាស់ត្រូវបានគេសម្លាប់ ហើយវត្តអារាមនិងសាលារៀនត្រូវបានដុតបំផ្លាញចោលអស់**» ការរៀបរាប់បែបនេះមានលក្ខណៈទូទៅ ប៉ុន្តែឯកសារខ្លះទៀតបាននិយាយពីឈ្មោះពិតចំៗកន្លែងនេះកន្លែងនោះដូចជាថា «**នៅក្នុងគ្រួសារខ្ញុំមានសមាជិកស្លាប់នៅថ្ងៃនេះ ថ្ងៃនោះ នៅកន្លែងនេះ កន្លែងនោះ**» ។ ពិនិត្យជារួមឃើញថាឯកសារទាំងអស់មានប្រយោជន៍ និងសារៈសំខាន់ផ្សេងពីគ្នាច្រើនណាស់ហើយជាពិសេសតម្លៃរបស់វាចំពោះតុលាការ ។ នៅពេលណាក៏ដោយក៏ឯកសារទាំងអស់នេះនៅតែមានសារៈប្រយោជន៍ដែលចាំបាច់ត្រូវតែមានការយកចិត្តទុកដាក់យ៉ាងខ្លាំង និងការស្រាវជ្រាវថែមទៀត ។

ឯកសារពេញលេញមួយច្បាប់ៗពីខេត្តសៀមរាបត្រូវបានថតចម្លងដែលជាគំរូមួយសម្រាប់ខេត្តមួយ ដើម្បីបង្ហាញពីសារជាតិពិត និងអាយុកាលរបស់វា ។ ឯកសារមកពីខេត្តផ្សេងៗទៀត ត្រូវបានចាត់ជាប្រភេទផ្សេងៗពីគ្នាតាមស្រុក និងមាតិកាហើយឯកសារដែលគិតថាមានសារៈសំខាន់ជាងគេត្រូវបានថតចម្លងដោយម៉ាស៊ីនកុំព្យូទ័រ ហើយខ្លះទៀតត្រូវបានបកប្រែរួចជាស្រេចក្នុងគោលគំនិតមួយផ្តល់ជាទិន្នន័យដាក់ស្តែង ។

ឯកសារមួយក្នុងចំណោមឯកសារទាំងអស់នៅក្នុងជម្រើសឯកសារនេះគឺតារាងមួយដែលបង្ហាញពីតួលេខមកពីខេត្តនីមួយៗស្តីអំពីចំនួនមនុស្សស្លាប់ ចំនួនអ្នកធ្វើញត្តិ ហើយតារាងនេះក្លាយទៅជាប្រភពមួយនៃឈ្មោះជម្រើសឯកសារ «រាប់លាន» ដោយសារតែវាបង្ហាញថាមានអ្នកធ្វើញត្តិចំនួន១ ១៦៦ ៣០៧ នាក់ បានចុះហត្ថលេខាលើឯកសារទាំងនេះដែលរាយការណ៍ថា

មានមនុស្សស្លាប់ចំនួន ៣ ៣១៨ ០០០នាក់ ។ តារាងតួលេខនេះដែលត្រូវបានចងក្រងឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៨២ ដោយគណៈកម្មការស្រាវជ្រាវ ហើយក្លាយជាប្រភពតួលេខទាក់ទងនឹងមនុស្សស្លាប់ដោយពួកខ្មែរក្រហមក្នុងអំឡុងពេលកាន់អំណាច ។ តួលេខនេះត្រូវបានប្រើជាផ្លូវការដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ តារាងដែលជាប្រភពតួលេខនេះរាយព័ត៌មានតាមទូរលេខ និងឯកសារផ្សេងៗពីអជ្ញាធរខេត្ត ប៉ុន្តែមកដល់ឥឡូវនេះឯកសារទាំងនោះហាក់ដូចជាបាត់ស្រមោលរកពុំឃើញ ។

## គ) ឯកសារទួលស្លែង

សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញដែលជាអតីតសាលារៀនហើយត្រូវបានខ្មែរក្រហមប្រែក្លាយទៅ



ក្រុមអ្នកស្រាវជ្រាវរណ្តៅសាកសពប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៨៣

ជាមណ្ឌលឃុំឃាំងនិងធ្វើទារុណកម្មនោះ បានផ្តល់នូវឯកសារយ៉ាងគ្រាស់ក្រែល ។ នៅដើមទសវត្សរ៍ឆ្នាំ៩០ សកលវិទ្យាល័យ ខណែល សហរដ្ឋអាមេរិក បានដឹកនាំកិច្ចប្រឹងប្រែងមួយក្នុងការថតចម្លងតាមម៉ាស៊ីនមីក្រូហ្វីលនូវឯកសារចម្លើយសារភាពដែលតម្កល់ទុកនៅទួលស្លែង ប៉ុន្តែក្រៅពីឯកសារដែលបានចម្លងទាំងនោះនៅមានឯកសារសំខាន់ៗដ៏សន្ធឹកសន្ធាប់ដទៃទៀតដែលត្រូវបានរកឃើញថ្មីៗកន្លងទៅនេះ ហើយឯកសាររកឃើញថ្មីៗទាំងអស់នោះឥឡូវនេះត្រូវបានបញ្ចូលទៅក្នុងទិន្នន័យគន្ធនិទ្ទេស (ឯកសារផ្សេងៗនិងសៀវភៅកំណត់ហេតុ) ខាងលើនេះ ។ ឯកសារនិងសៀវភៅកំណត់ហេតុទាំងអស់នេះត្រូវបានរក្សាទុកដោយបុគ្គលិកគុកទួលស្លែង ។

## ឃ) ឯកសារសន្តិបាល

នៅក្នុងឆ្នាំ១៩៩៦-៩៧ ជម្រើសឯកសារដែលប្រហែលជាសំខាន់បំផុតប្រមាណជាង១សែនទំព័រ មានប្រភពចេញមកពីសន្តិបាល ឬមន្ទីរសន្តិសុខរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រវត្តិរូបជាង១ម៉ឺន និងចម្លើយសារភាពជាង១ម៉ឺន១ពាន់សំបុត្រ ព្រមទាំងឯកសារផ្សេងៗទៀត ឥឡូវនេះត្រូវបានកំពុងធ្វើកាតាឡុក ឬចាត់ជាក្រុមក្នុងបញ្ជីសង្ខេប និងចម្លងនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយថែមទាំងកំពុងត្រូវបានថតចម្លងដោយម៉ាស៊ីនថតមីក្រូហ្វីលដើម្បីថែរក្សាតាមរយៈក្រុមការងារមួយក្រោមការដឹកនាំការងាររបស់បណ្ណាល័យនៃសកលវិទ្យាល័យយ៉េល ។

ទីតាំងឯកសារជាច្រើនកំពុងត្រូវបានរកឃើញនៅក្រៅប្រទេសកម្ពុជា ហើយកំពុងត្រូវបានព្យាយាមយកមកបញ្ចូលទៅក្នុងទិន្នន័យកុំព្យូទ័រ ។ ឯកសារទាំងនោះជាឯកសារដើម និងឯកសារជាសំណេរដូចជាអត្ថបទទិនានុប្បវត្តិ សៀវភៅពុម្ព ព្រមទាំងហ្វីលខ្សែភាពយន្ត ។ ឯកសារដែលមានតម្លៃជាងគេបំផុតដែលជាឯកសារដើមប្រមូលដោយអ្នកសិក្សាជាន់ខ្ពស់ក៏កំពុងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យដែរ ដូចជាឯកសារប្រវត្តិរូបផ្ទាល់ខ្លួនប្រតិចារឹកនៃបទសម្ភាសន៍ ជម្រើសរូបថតខ្សែអាត់ ។ល ។ ជាពិសេសឯកសារដែលប្រវត្តិវិទូ ប៊ែន ឃៀនិន បានប្រមែប្រមូលជាច្រើនឆ្នាំមករួមទាំងប្រតិចារឹក និងកំណត់ហេតុប្រចាំថ្ងៃមកពីក្រសួងការបរទេសក្រោមការទទួលខុសត្រូវរបស់ អៀង សារី ហៅ វ៉ាន់ ដែលកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជាបានចេញផ្សាយទាំងស្រុងរួចមកហើយតាមរយៈប្រព័ន្ធផ្សព្វផ្សាយពិភពលោក (អ៊ីនធ័រណែត) ជាភាសាខ្មែរ និងភាសា អង់គ្លេស ។

(នៅមានត) ហេរ៉ឡែន ហ្វាទីស

**(តពីលេខមុន) ការរក្សាការសម្ងាត់នៅក្នុងមន្ទីរស-២១**

ពួកមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានផ្តល់អាទិភាពខ្ពស់បំផុតដល់ការងាររមន្ទីរស-២១ក្នុងការការពារក្បាលម៉ាស៊ីនមជ្ឈិមបក្សរបស់ខ្លួន ។ អនុលេខាធិការបក្សកុម្មុយនិស្តកម្ពុជា នួន ជា (បងធំទី២) បាននិយាយពន្យល់គណៈប្រតិភូជនជាតិដាណឺម៉ាកមួយក្រុម ដែលពេញចិត្តនឹងកម្ពុជាប្រជាធិបតេយ្យ ដែលបានមកបំពេញទស្សនកិច្ចនៅខែកក្កដា ឆ្នាំ១៩៧៨ ថា **«យើងត្រូវតែការពារក្បាលម៉ាស៊ីនដឹកនាំឲ្យបានទោះជាត្រូវលះបង់អ្វីក៏ដោយ ។ ប្រសិនបើយើងបាត់បង់សមាជិកតែនៅសល់អ្នកដឹកនាំ យើងអាចបន្តយកជ័យជម្នះបាន,,,,,,,។ ការបាត់បង់សមាជិក ២០០-៣០០នាក់ មិនអាចប្រៀបនឹងការបាត់បង់មេដឹកនាំ ២-៣នាក់បានទេ ។ យើងសុខចិត្តបាត់បង់សមាជិក២០០-៣០០នាក់ តែយើងមិនឲ្យបាត់បង់មេដឹកនាំ២-៣នាក់ឡើយ ។ បើពុំដូច្នេះទេបក្សនឹងគ្មានអ្នកដឹកនាំ និងពុំអាចដឹកនាំការប្រយុទ្ធបានឡើយ**» ។ នាដើមឆ្នាំ១៩៧៨ ព្រឹត្តិបត្រផ្សព្វផ្សាយទ្រឹស្តីរបស់បក្ស «ទង់បដិវត្តន៍» ក៏បានបង្ហាញអំពីគោលជំហរដូចគ្នានេះដែរ ដោយបានសរសេរក្នុងបទវិចារណកថារបស់ខ្លួនថា «**អន្តរាយរបស់មជ្ឈិមបក្សជាអន្តរាយធំណាស់,,,,។ យើងត្រូវការពារក្បាលម៉ាស៊ីនដឹកនាំឲ្យបានជាដាច់ខាត ។ បើសិនយើងអាចការពារបាន គឺយើងអាចការពារបានអ្វីៗទាំងអស់**» ។

អត្ថិភាពនៃមន្ទីរស-២១ ទីតាំងមជ្ឈិមបក្ស និងអត្តសញ្ញាណនៃអ្នកធ្វើការនៅក្នុងនោះ ត្រូវបានរបបនេះបិទបាំងយ៉ាងជិតឈឹងក្នុងអំឡុងពេលនោះ ។ ក្នុងពេលពិភាក្សាជាមួយប្រតិភូជនជាតិដាណឺម៉ាក នួន ជា បានបញ្ជាក់ថា «**កិច្ចការសម្ងាត់គឺសំខាន់ណាស់ ។ យើងលែងប្រើពាក្យ «ស្របច្បាប់» និង «មិនស្របច្បាប់» ទៀតហើយ ។ យើងប្រើពាក្យ «សម្ងាត់» និង «ចំហ» ជំនួសវិញ ។ កិច្ចការសម្ងាត់មានសារៈសំខាន់ចំពោះគ្រប់អ្វីៗទាំងអស់ដែលយើងធ្វើ,,,។ មានតែការសម្ងាត់ទេដែលធ្វើឲ្យយើងអាចគ្រប់គ្រងស្ថានការណ៍បាននិងយកឈ្នះសត្រូវដែលមិនដឹងថាយើងជានរណាបាន**» ។ ក្នុងមន្ទីរស-២១ សម្ងាត់គឺសំខាន់ជានិច្ច ។ នាពាក់កណ្តាលឆ្នាំ១៩៧៦ មានអ្នកទោសម្នាក់រៀបចំគម្រោងការលួចចេញពីមន្ទីរស-២១ ។ ឯកសារសិក្សាដែលបានធ្វើឡើងនៅក្នុងគុកនោះបានពិពណ៌នាព្រឹត្តិការណ៍នេះដោយប្រកាសអាសន្នថា «ការសម្ងាត់ត្រូវបានគេទម្លាយ ហើយការសម្ងាត់ដែលយើងបានបិទបាំងក្នុងរយៈពេល៣-៤ខែចុងក្រោយនេះត្រូវបានគេដឹងឮ ។ នៅពេលដែលគ្មានការសម្ងាត់ សន្តិបាលអាចនឹងរលាយបាត់រូបរាង ព្រោះពាក្យនេះបាត់អស់នូវអត្ថន័យរបស់វាហើយ...។ ប្រសិនបើអ្នកទោសរត់រួច ពួកគេមុខជានឹងនិយាយអំពីការសារភាពរបស់ខ្លួនប្រាប់អ្នកដទៃ ។ ការសម្ងាត់របស់សន្តិបាលអាចត្រូវបានគេទម្លាយត្រង់ចំណុចដែលមិនគួរនឹងធ្លាយ» ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី១: ការរកឃើញមន្ទីរ ស-២១**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ការសម្ងាត់ត្រូវបានរក្សាក្នុងមន្ទីរស-២១ ដោយការពារកុំឲ្យអ្នកខាងក្រៅមកជិត ការបណ្តេញអ្នករស់នៅជិតនោះចេញ ការកំហិត ការចែកចាយឯកសារដែលបានចងក្រង ការដុតបំផ្លាញក្រដាសឯកសារជំនួសឲ្យការគ្រាន់តែគូសវាត់វាចោល ការបិទមុខអ្នកទោសនៅពេលនាំជននោះពីកន្លែងមួយទៅកន្លែងមួយ និងការហាមឃាត់ការទាក់ទងគ្នារវាងក្រុមអ្នកសួរចម្លើយ និងក្រុមធ្វើឯកសារ និងការទាក់ទងរវាងក្រុមទាំង២នេះជាមួយបុគ្គលិកដែលមានសិទ្ធិតូចតាច ។ អ្នកយាមត្រូវបានហាមឃាត់មិនឲ្យជជែកជាមួយអ្នកទោស ហើយអ្នកទោសត្រូវបានហាមឃាត់មិនឲ្យជជែកគ្នាឡើយ ។ អ្នកទោសដែលមានឋានៈខ្ពស់ត្រូវបានឃុំនិងសួរចម្លើយ

ក្នុងអគារដោយឡែក ។ ការសួរចម្លើយស្ទើរតែទាំងអស់ត្រូវបាន ធ្វើឡើងនៅអគារខាងកើត ព្រោះជាកន្លែងដែលអ្នកទោសនិង បុគ្គលិកគុកមិនអាចស្តាប់ឮ ។ ឯកសារនៅមន្ទីរស-២១ មួយចុះខែ កញ្ញា ឆ្នាំ១៩៧៦ ដែលមានបញ្ជីឈ្មោះអ្នកយាមយប់និងថ្ងៃ បានធ្វើការកត់សម្គាល់ថា អ្នកយាមមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុង បន្ទប់សួរចម្លើយតាមអ្នកសួរចម្លើយ ឬ «បើកបង្អួចមើលខ្មាំង» ដែលកំពុងតែត្រូវបានសួរចម្លើយ ។ រឿងដែលឃោរឃៅបំផុត នោះគឺគេរក្សាការសម្ងាត់របស់មន្ទីរស-២១ ដោយការសម្លាប់ អ្នកទោសស្ទើរតែទាំងអស់ ។

មានតែបុគ្គលិក ឬអ្នកទោសជាឥស្សរជនមួយចំនួនតូច និងកម្មាភិបាលទទួលបន្ទុកកិច្ចការសន្តិបាលប្រចាំតំបន់និងភូមិភាគ ប៉ុណ្ណោះ ដែលដឹងពីអត្ថិភាពមន្ទីរស-២១ ។ តាមរយៈចំណារ ខ្លីៗ ទៅកាន់កម្មាភិបាលក្រោមបង្គាប់ ប៉ុល ពត, នួន ជា, សុន សេន និងតាម៉ុក (នៅឆ្នាំ១៩៧៨ មានឈ្មោះថា បងទី១ រហូតដល់បងទី៤) ចាត់ទុកអ្នកដែលកំពុងត្រូវបានសួរចម្លើយ និងអ្នកដែលឆ្លើយសារភាពថា បានប្រព្រឹត្តបទល្មើសប្រឆាំង បដិវត្តន៍ថាជាខ្មាំងទីមួយ ។ មេដឹកនាំទាំង៤ ពុំដែលនិយាយដល់ មន្ទីរស-២១ ឬសន្តិបាល ដោយចំឈ្មោះឡើយ ។

គ្មានឯកសារភ័ស្តុតាងដែលនៅសេសសល់ណាមួយអាច ប្រាប់យើងថា សន្តិបាលត្រូវបានបង្កើតឡើងជាផ្លូវការនៅពេលណា ដោយហេតុអ្វី ដោយអ្នកណា និងក្រោមមាគ៌ាដឹកនាំបែបណា នោះទេ ។ បុព្វអង្គភាពនៃមន្ទីរស-២១ មានក្នុងជួរកងទ័ពខ្មែរ ក្រហមក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៃប្រទេសកម្ពុជា (ចន្លោះ ឆ្នាំ១៩៧០-៧៥) ។ បុព្វអង្គភាពផ្ទាល់នៃមន្ទីរស-២១ ប្រហែល ជាប្រតិបត្តិការក្នុងតំបន់ ២៥ ខាងជើងរដ្ឋធានីពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ។ មនុស្ស២នាក់ដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹង ប្រតិបត្តិការនេះនាសម័យនោះគឺ សុន សេន (ហៅ បង៨៩ ហៅខៀវ កើតឆ្នាំ១៩៣០ ។ សុន សេន ត្រូវបាន ប៉ុល ពត បញ្ជាទាហានរបស់ខ្លួនឲ្យសម្លាប់ចោលនៅក្នុងឆ្នាំ១៩៩៧) និងអតីត គ្រូបង្រៀនដែលជាកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ទទួលបន្ទុក កិច្ចការសន្តិសុខឈ្មោះ កាំង ហ្គិចអៀវ (ហៅ ឌុច កើតក្នុងអំឡុង ឆ្នាំ១៩៤២) ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុន សេន ជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារប្រទេស និងសន្តិសុខជាតិ ។ សន្តិបាលជាការទទួលខុសត្រូវរបស់គាត់មួយដែរ ។ ចំណែក ឌុច វិញជាមេបញ្ជាការមន្ទីរស-២១ផ្ទាល់ និងជាអ្នករាយការណ៍ជូន សុន សេន ។

## បុគ្គលិកនៅមន្ទីរស-២១



មន្ទីរស-២១មានអង្គភាព ធំៗបីៈ អង្គភាពសួរចម្លើយ អង្គភាព រៀបចំឯកសារ និងអង្គភាពការ ពារ ។ អង្គភាពរងទទួលបន្ទុករូប ថត ប្រតិបត្តិការក្រោមចំណុះអង្គ ភាពឯកសារ ។ អង្គភាពរងដទៃ ទៀត ប្រតិបត្តិការក្រោមចំណុះ អង្គភាពការពារដែលជាអង្គភាពធំជាងគេនៅមន្ទីរស-២១ រួម មានអង្គភាពរងទទួលបន្ទុកយាមអ្នកទោស អង្គភាពរងទទួលបន្ទុក បញ្ជូនអ្នកទោសចូលគុក និងយកទៅសម្លាប់ អង្គភាពរងទទួល បន្ទុកផ្តល់សេវាពេទ្យបឋម និងអង្គភាពរងទទួលបន្ទុកភ័ស្តុភារ ។

សៀវភៅទូរស័ព្ទផ្ទៃក្នុងដែលមាន៤៦ឈ្មោះ ជាមគ្គុទ្ទេសក៍ សំខាន់ក្នុងការទំនាក់ទំនងជាមួយកម្មាភិបាលកំពូលៗ នៅមន្ទីរ ស-២១ ។ សៀវភៅនេះត្រូវបានរៀបចំឡើងមុនខែវិច្ឆិកា ឆ្នាំ ១៩៧៨ គឺមុនពេលអ្នកសួរចម្លើយម្នាក់ដែលមានឈ្មោះក្នុង សៀវភៅនោះគឺឈ្មោះ ជា ម៉ៃ ត្រូវបានចាប់ខ្លួន ។ សៀវភៅ នេះមានឈ្មោះកម្មាភិបាលនៅក្នុងផ្នែកក្តៅនៃអង្គភាពសួរចម្លើយ ចំនួន២៤នាក់ កម្មាភិបាលនៅក្នុងអង្គភាពឯកសារចំនួន៤នាក់ កម្មាភិបាលនៅក្នុងផ្នែកផ្សេង (រដ្ឋបាល) ចំនួន៥នាក់និងកម្មា-ភិបាល នៅក្នុងក្រុមពុំមានឈ្មោះដែលប្រហែលជាអ្នកសួរចម្លើយ ដែរចំនួន ៦ នាក់ ។

ក្នុងសៀវភៅទូរស័ព្ទ ផររដែលនៅពីមុខឈ្មោះនីមួយៗ មានលក្ខណៈស្របនឹង «ប្រព័ន្ធពលំដាប់ថ្នាក់» ។ «ប្រព័ន្ធពលំដាប់ ថ្នាក់» ជាប្រព័ន្ធមួយដែលគេប្រើក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ តាមប្រព័ន្ធនេះសមាជិកបក្សឡើងឋានៈជាបន្តបន្ទាប់ ពីសមាជិក សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជាទៅជាសមាជិកត្រៀម និងពីសមាជិក ត្រៀមទៅជាសមាជិកពេញសិទ្ធិ ។ ឈ្មោះនៅក្នុងសៀវភៅទូរស័ព្ទ

ត្រូវបានតម្រៀបទៅតាមវ័យ ។ ដំបូងជាឈ្មោះពេញចំនួន៨ ឈ្មោះដែលពុំមានដាក់ឋានៈពីមុខ ។ បន្ទាប់មកជាឈ្មោះចំនួន១០ ដែលមានដាក់រហស្សនាម «បង» ពីមុខ ។ រីឯប្រភេទចុងក្រោយ គឺសម្រាប់អ្នកដែលមានអំណាចធំជាងគេបំផុត ។ ទោះជា ឌុច មានអាយុត្រឹមតែជាង៣០ឆ្នាំក្តី ឯកសារមួយចំនួនបានផ្តល់នូវការគោរពចំពោះគាត់ខ្លាំងណាស់ដោយហៅគាត់ថា «តាឌុច» ។

ដោយបានរំដោះផុតពី «វណ្ណៈជិះជាន់» នាអតីតកាល សមាជិកបក្សកុម្មុយនិស្តកម្ពុជា និងបុគ្គលិកក្នុងគុក ត្រូវបានដាក់ឲ្យគោរពតាមបទបញ្ញត្តិ ដែលការគោរពមានភាពសាំញ៉ាំទៅតាមឋានានុក្រម និងពិបាកយល់ដូចបទបញ្ញត្តិដែលយើងបានជួបប្រទះក្នុងសាលានៅថ្ងៃដំបូង ឬក្នុងពេលដែលទើបបួសជាព្រះសង្ឃ ។ នេះជាការប្រដូចដ៏ស័ក្តិសម ព្រោះ ឌុច និងសហការីរបស់គាត់ក្នុងអង្គភាពសួរចម្លើយ ធ្លាប់ធ្វើគ្រូបង្រៀនជាច្រើនឆ្នាំ ហើយបុគ្គលិកក្នុងគុកនេះស្ទើរតែទាំងអស់ជាក្មេងប្រុសជំទង់ដែលក្នុងសម័យមុនបដិវត្តន៍វ័យនេះជាវ័យដែលត្រូវបួសជាសង្ឃ ។ លើសពីនេះទៅទៀត អ្នកមើលការខុសត្រូវគុកនេះត្រូវបានចាត់ទុកថាជាអាណាព្យាបាល ដែលបុគ្គលិកទាំងអស់ត្រូវគោរពស្តាប់បង្គាប់ដោយឥតតវ៉ាដូចព្រះសង្ឃក្នុងពុទ្ធសាសនាដែរ ។ វិន័យរបស់មន្ទីរស-២១ គឺយកការទន្ទេញបទបញ្ញត្តិទាំងឡាយជាមូលដ្ឋាន ។ វិន័យនេះនាំឲ្យមានការគោរពដ៏ខ្ពង់ខ្ពស់និងការស្តាប់បង្គាប់ដោយឥតតវ៉ាចំពោះរដ្ឋអំណាច ។

ឋានានុក្រមនៃឈ្មោះក្នុងសៀវភៅទូរស័ព្ទបង្ហាញឲ្យឃើញថា ឌុច និងកម្មាភិបាលជិតរបស់គាត់ទាំងប៉ុន្មាន ពុំមានបំណង ឬថាពុំមានលទ្ធភាពក្នុងការទាត់ចោលនូវការចាត់ថ្នាក់ និងការគោរពរបស់សង្គមខ្មែរមុនបដិវត្តន៍ដែលបដិវត្តន៍បានសន្យាថាបំផ្លាញចោលនោះទេ ។ ថ្នាក់ក្រោមពួកនេះក៏ពុំមានបំណងឲ្យរឿងបែបនេះកើតឡើងដែរ ។ អតីតអ្នកយាមម្នាក់ឈ្មោះ កុក ស្រស់ បាននិយាយថា «ឌុច បានប្រាប់ខ្ញុំថាខ្ញុំធ្វើការងារល្អ ។ ខ្ញុំក៏មានអារម្មណ៍ថាគាត់ចូលចិត្តខ្ញុំ និងជឿជាក់យ៉ាងប្រាកដថាខ្ញុំនឹងមានជីវិតរស់នៅតទៅទៀត ព្រោះខ្ញុំត្រូវបានថ្នាក់លើសរសើរ» ។

យើងអាចធ្វើការពិនិត្យមើលអំពីការរស់នៅនិងអត្តចរិតដែលមានការគាបសង្កត់ផ្លូវចិត្តពីឋានានុក្រមរបស់ សុន សេន និង ឌុច មុនពេលដែលអ្នកទាំងពីរក្លាយជាអ្នកកាន់កាប់អង្គភាពផ្សេងៗក្នុងគុក ។

## សុន សេន



ក្នុងឆ្នាំ១៩៧៥ សុន សេន ជាបុរសម្នាក់រាងស្គម ពាក់វ៉ែនតាម្ញ៉ូប នៅក្នុងចំណាស់សែថ្វាយ ។ ដូចជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ អៀង សារី ដែរ សុន សេន កើតនៅក្នុងសហគមន៍កម្ពុជានៅក្នុងទឹកដីវៀតណាមខាងត្បូងដែលនៅទីនោះឪពុកម្តាយរបស់ សុន សេន ជាម្ចាស់ដីដែលមានជីវភាពរុងរឿង ។ បន្ទាប់ពីផ្លាស់មកនៅទីក្រុងភ្នំពេញតាំងពីនៅវ័យកុមារ សុន សេន បានធ្វើឲ្យគ្រប់គ្នាចាប់អារម្មណ៍គាត់ដោយសារទេពកោសល្យក្នុងការរៀនសូត្ររបស់គាត់ ។ សុន សេន បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងនៅក្នុងឆ្នាំ១៩៥០ គឺមិនយូរប៉ុន្មាន បន្ទាប់ពី សាឡុត ស (ដែលក្រោយមកគេស្គាល់ថាជា ប៉ុល ពត) បានទទួលរង្វាន់អាហារូបករណ៍ដូចគ្នានេះ ។ ជានិស្សិតសិក្សាអំពីទស្សនវិទ្យា និងប្រវត្តិវិទ្យានៅទីក្រុងប៉ារីស សុន សេន បានចូលរួមនៅក្នុងបក្សកុម្មុយនិស្តបារាំង រួមជាមួយ សាឡុត ស, អៀង សារី និងនិស្សិតខ្មែរជាច្រើនទៀត ។ នៅពេលត្រឡប់មកកាន់មាតុភូមិនៅក្នុងឆ្នាំ១៩៥៦ សុន សេន បានចាប់ផ្តើមអាជីពជាគ្រូបង្រៀន ហើយបានចូលរួមចំណែកនៅក្នុងចលនាកុម្មុយនិស្តកម្ពុជាសម្ងាត់ ។ នៅក្នុងដើមទសវត្សរ៍ឆ្នាំ៦០ សុន សេន បានក្លាយទៅជានាយកសិក្សាធិការនៃវិទ្យាស្ថានគរុកោសល្យ ដែលជាផ្នែកមួយនៃសាកលវិទ្យាល័យភ្នំពេញ ។ សុន សេន ត្រូវបានបណ្តេញចេញពីមុខតំណែងនេះនៅឆ្នាំ១៩៦២ ដោយសារគាត់មានទស្សនៈប្រឆាំងនឹងស្តេច សីហនុ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យបន្តមុខវិជ្ជាបង្រៀនតទៅទៀត ។

ក្នុងឆ្នាំ១៩៦៣ បន្ទាប់ពី សាឡុត ស ត្រូវបានតែងតាំងជាលេខាបក្សកុម្មុយនិស្តដែលត្រូវបានរៀបចំឡើងវិញ សុន សេន បានចូលរួមជាមួយនឹង សាឡុត ស ជាសមាជិកគណៈកម្មាធិការ

មជ្ឈិមដែលទើបតែត្រូវបានរុះរើរៀបចំសាជាថ្មី និងនៅលាក់មុខនៅឡើយ ។ ក្នុងឆ្នាំ១៩៦៤ សុន សេន ត្រូវបានបំពាក់បំប៉នសតិអារម្មណ៍ឲ្យចេញពីរាជធានីដោយលាក់ខ្លួននៅក្នុងឃ្លុបខាងក្រោយនៃរថយន្តរបស់អ្នកការទូតចិនមួយរូប ហើយបានចូលរួមជាមួយ សាឡុត ស និងសមាជិកកុម្មុយនិស្តមួយចំនួនតូចនៅក្នុងមូលដ្ឋានយោធាកុម្មុយនិស្តវៀតណាមដែលត្រូវបានស្គាល់ថាជា «មន្ទីរ១០០» ។ មន្ទីរនេះរើចុះរើឡើងឆ្លងកាត់តាមព្រំដែនកម្ពុជា-វៀតណាមអាស្រ័យទៅតាមសភាពការណ៍សង្គ្រាមនៅវៀតណាម ។

រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ទើប សុន សេន បានត្រឡប់មកភ្នំពេញវិញ ។ ក្នុងរយៈពេល១២ឆ្នាំ នៅក្នុងព្រៃម៉ាកគី សុន សេន បានចងមិត្តភាពជាមួយនឹងបុរសស្ត្រីដែលក្រោយមកអាចនឹងក្លាយជាសមាសភាពមជ្ឈិមបក្ស ហើយភាគច្រើននៃអ្នកទាំងនោះគឺជាមនុស្សដែល សុន សេន ធ្លាប់បានស្គាល់នៅឯប្រទេសបារាំង ។ នៅពេលដែលការតស៊ូប្រដាប់អាវុធប្រឆាំង សម្តេច សីហនុ បានផ្ទុះឡើងនៅក្នុងឆ្នាំ១៩៦៨ សុន សេន បានក្លាយទៅជាមេបញ្ជាការក្នុងសមរភូមិប្រយុទ្ធ ។ ក្រោយមកបន្តិច សុន សេន ក៏បានបង្ហាញអំពីទេពកោសល្យដ៏ពូកែរបស់គាត់នៅក្នុងការធ្វើសឹកសង្គ្រាមយោធានៅក្នុងសមរភូមិ ។ នៅត្រឹមដើមឆ្នាំ១៩៧២ សុន សេន បានក្លាយជាប្រធានអគ្គសេនាធិការ ។ សហសេវិករបស់ សុន សេន នៅក្នុងបក្សជួនកាលយល់ថា គាត់ជាមនុស្សដាច់ខាតនិងមានទស្សនៈដូចពួក «អនុធន» ក៏ប៉ុន្តែនៅក្នុងខែសីហា ឆ្នាំ១៩៧៥ សុន សេន ត្រូវបានប្រគល់ការទទួលខុសត្រូវចំពោះកិច្ចការការពារនិងសន្តិសុខរបស់ប្រទេសកម្ពុជាទាំងមូល ។

ការទទួលខុសត្រូវថ្មីរបស់ សុន សេន រួមមានសន្តិបាល ។ សុន សេន ត្រួតពិនិត្យដំណើរការនានានៅក្នុងសន្តិបាលយ៉ាងជិតដិតបំផុត ។ សុន សេន បានអាន និងចារលើចម្លើយសារភាពជាច្រើនដែលធ្វើឡើងនៅក្នុងមន្ទីរស-២១ ហើយបានរៀបចំវគ្គសិក្សាសម្រាប់កម្មាភិបាលមន្ទីរស-២១ ដែលក្នុងនោះ សុន សេន បានពិភាក្សាពីគោលដៅនៃមន្ទីរស-២១ អំពីការសួរចម្លើយនិងការប្រើប្រាស់មធ្យោបាយធ្វើទារុណកម្ម ។ ចេញពីវគ្គសិក្សាទាំងនោះមានសៀវភៅកំណត់ហេតុចំនួន៣ដែលរៀបរៀងដោយកម្មាភិបាលនៅមន្ទីរស-២១ ត្រូវបានរកឃើញនិងបន្សល់ទុកដល់សព្វថ្ងៃ ។ សៀវភៅកំណត់ហេតុទាំង៣នោះបានបង្ហាញថា ចំណាប់អារម្មណ៍របស់ សុន សេន អំពីបញ្ហាប្រវត្តិសាស្ត្រដែលត្រូវបានបណ្តុះនៅក្នុងចិត្តគំនិតរបស់គាត់កាលពីគាត់ទៅប្រទេសបារាំងនៅតែបន្តរហូតដល់ពេលដែលគាត់ក្លាយជាមន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាកម្ពុជាប្រជាធិបតេយ្យ ។ មិនខុសពីប្រជាជនកម្ពុជាជាច្រើនដែលបានកើតនៅប្រទេសវៀតណាម សុន សេន ហាក់ដូចជាឆាប់មានទស្សនៈប្រឆាំងនឹងវៀតណាមយ៉ាងមុតស្រួច ។ ឯកសារជាច្រើនដែលមានឫសគល់ចេញពីមន្ទីរស-២១ ដែលផ្ញើទៅកាន់មជ្ឈិមបក្ស ត្រូវបានឆ្លងកាត់ដៃ សុន សេន ហើយកំណត់ហេតុរាប់សិបទៀត ដែលចារទៅឲ្យ សុន សេន និងធ្វើឡើងដោយ ឌុច ត្រូវបានបន្សល់ទុកដល់សព្វថ្ងៃនេះការឆ្លើយតបរបស់ សុន សេន ជាច្រើនក៏បានបន្សល់ទុកមកដល់ពេលនេះដែរ ។ឯកសារទាំងនេះបានបង្ហាញយ៉ាងលម្អិតអំពីការចាប់អារម្មណ៍ដែលជិតជាប់នៅក្នុងផ្នត់គំនិតនិងភាពជ្រុលនិយមនៃបដិវត្តន៍ដែលកំពុងមានសន្ទុះយ៉ាងខ្លាំង ។ យុន យ៉ាត ហៅសមមិត្ត អាត ដែលជាប្រពន្ធរបស់ សុន សេន ដែលជាអតីតគ្រូបង្រៀនម្នាក់ដែរបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹង សុន សេន ហើយធ្លាប់បានពិនិត្យចម្លើយសារភាពមួយចំនួនក្នុងចំណោមចម្លើយសារភាពទាំងនោះ ។ នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ សុន សេន បានប្រឹងប្រែងធ្វើការយ៉ាងខ្លាំងដើម្បីកៀងគរអង្គភាពដែលមានមូលដ្ឋាននៅតាមតំបន់នានាដែលទើបបានឈ្នះសង្គ្រាមស៊ីវិលដាក់បញ្ចូលទៅក្នុងកងទ័ពជាតិមួយ ។ នៅក្នុងឆ្នាំ១៩៧៧-៧៨ សុន សេន ទទួលខុសត្រូវក្នុងការប្រយុទ្ធជាមួយប្រទេសវៀតណាម ហើយគ្រប់គ្រងលើយុទ្ធនាការធ្វើបន្សុទ្ធកម្មនៃកម្មាភិបាលដែល «មិនស្មោះត្រង់» នៅភូមិភាគបូព៌ា ។ នៅក្នុងប៉ុន្មានខែចុងក្រោយមុនរបបនេះត្រូវបានផ្តួលរំលំ គឺនៅពេលដែលសង្គ្រាមបានធ្លាក់ដល់សភាពដុនដាបយ៉ាងខ្លាំង សុន សេន ខ្លួនឯងបានធ្លាក់នៅក្រោមការសង្ស័យប្រសិនបើការលុកលុយដោយទ័ពវៀតណាមត្រូវបានពន្យារពេលម៉្លេះសមពេលនោះ សុន សេន ប្រហែលជាត្រូវបានជម្រុះចោលដោយ «បង១ខាងលើ» និងដោយស្ថាប័នដែលគ្មានវិប្បដិសារី

របស់គាត់បាត់ទៅហើយ ក៏ប៉ុន្តែ សុន សេន រក្សាគុណភាពរបស់គាត់ឲ្យនៅនឹងនរបាន ហើយនៅក្នុងឆ្នាំ១៩៧៩ បានបន្តមុខនាទីជាមេបញ្ជាការនៃកងកម្លាំងយោធាខ្មែរក្រហមបន្ទាប់ពីចលនានេះត្រូវបានទទួលបរាជ័យ ។ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅក្នុងឆ្នាំ១៩៩១ សុន សេន បានបង្ហាញមុខជា «តំណាងផ្លូវការ» នៃចលនាខ្មែរក្រហម ក៏ប៉ុន្តែនៅពេលដែលថ្នាក់លើរបស់គាត់សម្រេចធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ សុន សេន ក៏បាត់ស្រមោលពីក្រសែភ្នែកសាធារណៈ ។ សុន សេន ពុំដែលបានទទួលឋានៈជារដ្ឋមន្ត្រីក្រសួងការពារជាតិដូចពីមុននោះទេ ។ នៅក្នុងករណីដ៏សាហាវបំផុតមួយនៃការស្វែងរកយុត្តិធម៌ក្រៅផ្លូវច្បាប់ សុន សេន និងប្រពន្ធរបស់គាត់ យុន យ៉ាត ត្រូវបានប្រហារជីវិតក្រោមបញ្ជារបស់ ប៉ុល ពត នៅក្នុងតំបន់ភាគខាងជើងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៩៧ ដោយចោទប្រកាន់ថាជា «ភ្នាក់ងារចារកម្ម» បម្រើឲ្យរបបភ្នំពេញ ។

## ឌុច

កាំង ហ្គិចអៀវ (ហៅ ឌុច) មេបញ្ជាការមន្ទីរស-២១ ពេញមួយរយៈពេលដែលមន្ទីរនេះដំណើរការ កើតក្នុងអំឡុងឆ្នាំ១៩៤២ នៅក្នុងត្រកូលគ្រួសារខ្មែរកាត់ចិនក្រីក្រមួយនៅក្នុងភូមិកំពង់ចិន «ស្រុកស្ទោង» ខេត្ត កំពង់ធំ ។ ដូចជា សុន សេន ដែរ កាំង ហ្គិចអៀវ បានធ្វើឲ្យគេចាប់អារម្មណ៍ថាជាក្មេងម្នាក់ដែលមានសមត្ថភាពខ្ពស់ផ្នែកបញ្ញា ។ តាមបទសម្ភាសន៍ជាមួយនឹងម្តាយរបស់ កាំង ហ្គិចអៀវ នៅក្នុងឆ្នាំ១៩៨០ គាត់បានប្រាប់ឲ្យដឹងថា ខួរក្បាលកូនប្រុសរបស់គាត់គឺ «ជាប់តែនឹងសៀវភៅជានិច្ច» ។ ដោយមានការជួយជ្រោមជ្រែងពីអ្នកមានឥទ្ធិពលម្នាក់នៅក្នុងស្រុក កាំង ហ្គិចអៀវ បានទទួលអាហារូបករណ៍ទៅសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ ។ នៅក្នុងការប្រឡងបាក់ឌុបទូទាំងប្រទេសនៅក្នុងឆ្នាំ១៩៥៩ កាំង ហ្គិចអៀវ ជាប់លេខ២ ក្នុងមុខវិជ្ជាគណិតវិទ្យា ។ មិត្តរួមថ្នាក់របស់ កាំង ហ្គិចអៀវ ម្នាក់បានរំឭកឡើងវិញថា ក្នុងសម័យនោះ កាំង ហ្គិចអៀវ គឺជាយុវជនវ័យក្មេងដែលប្រកាន់ខ្ជាប់នូវភាពឧស្សាហ៍ដោយពុំមានការចាប់អារម្មណ៍ទៅលើការកម្សាន្តអ្វីផ្សេង ឬក៏ការចាប់អារម្មណ៍លើបញ្ហានយោបាយទាល់តែសោះ ។



ពីរ-បីឆ្នាំបន្ទាប់មកទៀត កាំង ហ្គិចអៀវ ចាប់យកអាជីពជាគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យានៅវិទ្យាល័យខេត្តកំពង់ធំ ។ សិស្សម្នាក់ក្នុងចំណោមអតីតសិស្សរបស់ ឌុច ទាំងអស់ក្រោយមកបានរំឭកថា «ឌុច ត្រូវបានគេទទួលស្គាល់ចំពោះភាពច្បាស់លាស់ក្នុងការបង្រៀនហាក់បីដូចជាគាត់ថតចម្លងនូវអត្ថបទទាំងមូលចេញពីខួរក្បាលរបស់គាត់ដាក់នៅលើក្តារខៀន» ។ សហការីម្នាក់ដែលរួមអាជីពជាគ្រូបង្រៀនផ្នែកជីវវិទ្យានៅឯវិទ្យាល័យនោះគឺជាមនុស្សម្នាក់ដែលមានរូបរាងខ្ពស់ជាងគេដាច់ ឈ្មោះថា ម៉ម ណៃ (ហៅ ចាន់) ។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយមកនៅពេលដែលបុរសទាំងពីរនេះបានក្លាយជាសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា ឌុច បានហៅ ម៉ម ណៃ មកធ្វើជាប្រធានអង្គភាពសួរចម្លើយនៅឯមន្ទីរស-២១ ។ ឌុច និងចាន់ ត្រូវបានដឹងតាមរយៈឯកសារដែលបានបន្សល់ទុកថាជាគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិឈ្លាសវៃម៉ឺងម៉ាត់ និងបានលះបង់ទាំងស្រុងទៅលើការងារ ។ លក្ខណៈទាំងនេះដែលអ្នកទាំងពីរបានពាំនាំជាមួយនឹងខ្លួនទៅបម្រើគោលដៅផ្សេងនៅពេលដែលអ្នកទាំងពីរធ្វើការជាមួយគ្នានៅឯមន្ទីរស-២១ ។

ក្នុងឆ្នាំ១៩៦៤ ឌុច បានទទួលមុខតំណែងនៅវិទ្យាស្ថានគរុកោសល្យបន្ទាប់ពី សុន សេន បានចាកចេញ ។ យោងទៅតាមសម្តីរបស់លោក នេត ប៊ុនអន ដែលជាមិត្តរួមថ្នាក់របស់ ឌុច នៅឯវិទ្យាល័យស៊ីសុវត្ថិយុវជនវ័យក្មេងដែលពូកែខាងគណិតវិទ្យារូបនេះត្រូវបានអូសទាញឆ្ពោះទៅរកលទ្ធិកុម្មុយនិស្តដោយនិស្សិតចិនមួយក្រុមដែលបានមកចូលសិក្សាអក្សរសាស្ត្រខ្មែរនៅឯសាកលវិទ្យាល័យភ្នំពេញ ។ នៅឯសាកលវិទ្យាល័យ ឌុច មានការចាប់អារម្មណ៍និងទទួលការអប់រំនយោបាយដោយបុរសស្ត្រីវ័យក្មេងដែលសម្បូណ៌ទៅដោយទស្សនៈ និងមានការយកចិត្តទុកដាក់ដ៏ស្រួចស្រាល់ទៅលើលទ្ធិកុម្មុយនិស្ត ។ ឌុច មើលឃើញថាបុរសស្ត្រីវ័យក្មេងទាំងនោះនឹងត្រូវដើរតួនាទីដ៏សំខាន់នៅក្នុងទំនាក់ទំនងកម្ពុជាចិននៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនិង

បន្តពីរបបនេះទៅទៀត ។ បន្ទាប់ពីចាកចេញពីវិទ្យាស្ថានគរុកោសល្យ ឌុច បានបន្តបង្រៀនមួយរយៈខ្លីនៅឯវិទ្យាល័យជើងព្រៃនៅក្នុងខេត្តកំពង់ចាម ។ នៅទីនោះគាត់បានណែនាំយ៉ាងហោចណាស់សិស្សម្នាក់ក្នុងចំណោមសិស្សរបស់គាត់ឈ្មោះ គី សុខហ៊ី ឲ្យចូលទៅក្នុងចលនាបដិវត្តន៍ហើយក្រោយមកក៏ត្រូវបានចាប់ខ្លួនដោយកងកម្លាំងប៉ូលិសរបស់ស្តេច សីហនុ ពីបទចោទប្រកាន់ថាជាជនកុម្មុយនិស្ត ។ ឌុច ត្រូវបានដាក់ឃុំដោយពុំមានការជំនុំជម្រះក្តីអស់រយៈពេលជាច្រើនខែដែលជានីតិវិធីធម្មតាមួយសម្រាប់អ្នកទោសនយោបាយក្នុងជំនាន់នោះ ។ ក៏ប៉ុន្តែគាត់រិះរកមធ្យោបាយបានជោគជ័យក្នុងការដោះខ្លួនចេញពីឃុំតាមរយៈការធ្វើអន្តរាគមន៍ពីអ្នកអាណាព្យាបាលរបស់គាត់កាលពីកុមារភាព ។ មិនយូរប៉ុន្មានបន្ទាប់ពីស្តេចសីហនុ ត្រូវបានផ្តួលរំលំពីអំណាច កាំង ហ្គិចអៀវ ហៅ ឌុច បានរត់ចូលព្រៃម៉ាគគី ។

នៅដើមទសវត្សរ៍ឆ្នាំ៧០ កាំង ហ្គិចអៀវ ដែលត្រូវបានស្គាល់ថាជា ឌុច ទទួលខុសត្រូវសន្តិសុខនៅតំបន់៣៣ ភាគខាងជើងនៃក្រុងភ្នំពេញ ។ លោក ហ្វ្រង់ស័រ ប៊ីហ្សូ ដែលជាអ្នកជំនាញផ្នែកជាតិពន្ធុ ត្រូវបានចាប់ខ្លួនដោយពួកទ័ពព្រៃកុម្មុយនិស្តនៅក្នុងតំបន់៣៣នេះក្នុងអំឡុងឆ្នាំ១៩៧០ ។ ឌុច ធ្លាប់បានសួរចម្លើយលោក ហ្វ្រង់ស័រ ម្តងហើយម្តងទៀត សាចុះសាឡើងអស់រយៈពេល២ខែ ដោយចោទប្រកាន់លោក ហ្វ្រង់ស័រ ថាជាភ្នាក់ងារ សេ.អ៊ី.អា ហើយបានបង្ខំឲ្យគាត់សរសេរជីវប្រវត្តិលម្អិតជាច្រើនសាមុនពេលដោះលែង ។ លោក ហ្វ្រង់ស័រ បានរួចចេញមកដោយមានការតក់ស្លុតចំពោះភាពងប់ងល់របស់ ឌុច ។ នៅក្នុងទស្សនៈរបស់លោក ហ្វ្រង់ស័រ «ឌុច ជឿថាជនទាំងឡាយណាដែលមានទស្សនៈផ្សេងគឺជាជនក្បត់ និងជាជនភូតភរ ។ ឌុច ខ្លួនឯងគឺជាអ្នកវាយអ្នកទោសដែលមិនព្រមប្រាប់នូវការពិត» ។

ក្នុងឆ្នាំ១៩៧៣ ឌុច បានផ្លាស់មកតំបន់២៥ ភាគខាងជើងនៃក្រុងភ្នំពេញ ។ ថ្នាក់លើរបស់ ឌុច ឈ្មោះ សុខ ធួក (ហៅ វ៉ន វ៉េត) ជាយុទ្ធជនកុម្មុយនិស្តចាប់តាំងពីទសវត្សរ៍ឆ្នាំ៤០មកម្ល៉េះ ។ សុខ ធួក ត្រូវបានប្រហារជីវិតនៅមន្ទីរ ស-២១ក្នុងឆ្នាំ១៩៧៨ ។ នៅក្នុងឆ្នាំ១៩៧៣ សុន សេន ជាអនុរបស់ សុខ ធួក ទទួលបន្ទុកកិច្ចការយោធា ។ បន្ទាប់ពីការប្រហារជីវិត សុខ ធួក, ឌុច ប្រហែលជាបានទទួលការចាប់អារម្មណ៍ចូលចិត្តយ៉ាងខ្លាំងពីសំណាក់ សុន សេន ។ ក្នុងរយៈកាលបំពេញការងារកន្លងមក ឌុច បានចាប់យកជំនាញនៅក្នុងបញ្ហាសន្តិសុខបានយ៉ាងច្រើន ។ ពុំមានភស្តុតាងបង្ហាញថា ឌុច ធ្លាប់ធ្វើដំណើរទៅបរទេស ឬទទួលការបណ្តុះបណ្តាលណាមួយពីអ្នកជំនាញបរទេសនោះទេ ។ ក្នុងចន្លោះឆ្នាំ១៩៧២ និង១៩៧៣ ឌុច ប្រហែលជាជួយបង្កើតនូវអត្តសញ្ញាណនៃ «ខ្មែរក្បត់» ។ នៅក្នុងចន្លោះពេលនោះកិច្ចប្រតិបត្តិការសម្ងាត់មួយត្រូវបានបង្កើតឡើងដោយពួកខ្មែរក្រហមដើម្បីធ្វើបន្សុទ្ធកម្មក្រុមដែលហៅថាខ្មែរហាណូយ (ខ្មែរដែលមកពីភាគខាងត្បូងនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧០ បន្ទាប់ពីការនិរទេសខ្លួនឯងទៅកាន់វៀតណាមខាងជើងអស់រយៈពេលជាច្រើនឆ្នាំក្នុងរូបភាពទៅជួយបដិវត្តន៍) ។ សមាជិកខ្មែរក្រុមនេះរាប់រយនាក់ ត្រូវបានចាប់ខ្លួនជាសម្ងាត់និងយកទៅសម្លាប់ចោលក្នុងឆ្នាំ១៩៧៣ បន្ទាប់ពីវៀតណាមបានដកទ័ពរបស់ខ្លួនទាំងស្រុងចេញពីកម្ពុជា ។ សមាជិកនៅសេសសល់ពីរ-បីនាក់ទទួលជោគជ័យក្នុងការគេចខ្លួនទៅប្រទេសវៀតណាមបន្ទាប់ពីការឃុំឃាំង ហើយសមាជិកដទៃទៀតត្រូវបានចាប់ខ្លួនបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ។ សមាជិកភាគច្រើននៃក្រុមនេះត្រូវបានចាប់ខ្លួននៅក្នុងភូមិភាគពិសេស ។ ភាពដាច់ខាត និងភាពគ្មានមេត្តានៃយុទ្ធនាការធ្វើបន្សុទ្ធកម្មនេះប្រហែលជាមានការជំពាក់គុណស្រ័យចំពោះរបៀបរដ្ឋបាលដ៏លេចធ្លោរបស់ ឌុច ។ តាមពិតយុទ្ធនាការនេះគឺមានភាពខ្លាំងក្លាលើសលប់ជាងអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ទៅទៀត ។ **(នៅមានត)**

## ពាក្យស្លោកខ្មែរក្រហម

- **តម្កល់ឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពដែនដីនិងកិត្តិយសជាតិឱ្យខ្ពង់ខ្ពស់ជាងអ្វីៗទាំងអស់។**
- **ពង្រឹងបន្ថែមស្នេហាជាតិ ពង្រឹងបដិវត្តន៍ និងមោទនភាពបដិវត្តន៍ចំពោះជាតិខ្លួន ប្រជាជន កងទ័ពបដិវត្តន៍ និងបក្សខ្លួនឱ្យរឹងដូចដែកជាប់ជានិច្ច។**

(ដកស្រង់ចេញពីសៀវភៅខ្មែរក្រហម លេខ០៧៦កណហ)

# ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ

គណៈកម្មការស្វែងរកការពិត



ប្រជាជនគាស់រណ្តៅសាកសពក្នុងទសវត្សរ៍ឆ្នាំ៨០

ថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៩៩ ជាខួបលើកទី២០ នៃការរលំរលាយនៃរបប ប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានសម្លាប់ប្រជាជន កម្ពុជាដែលត្រូវបានប៉ាន់ ប្រមាណថាមានចំនួន១ភាគ៣ នៃប្រជាជនទាំងអស់ ក្នុងរយៈ ពេលកាន់អំណាចមិនដល់៤ ឆ្នាំរបស់ខ្លួន ។ ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះអំពើឃោរឃៅរបស់ពួកខ្មែរក្រហមពុំ ទាន់ត្រូវបានយកមកពិនិត្យផ្តន្ទាទោសដោយអាជ្ញាធរមិនលម្អៀង ណាមួយនៅឡើយទេ ហើយនយោបាយរបស់កម្ពុជានៅតែមាន សភាពរការីកូសនិងបង្អាក់ដល់ការអភិវឌ្ឍសង្គមស៊ីវិលកម្ពុជាដោយ សន្តិភាព ។ ហេតុការណ៍ទាំងពីរនេះត្រូវបានអះអាងថា មានការ ទាក់ទងគ្នាគឺប្រជាជនកម្ពុជាពុំអាចរស់នៅក្នុងសង្គមមួយដែលមាន សន្តិភាពបានទេ បើរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិមិន កែលម្អនយោបាយរបស់ខ្លួន ដើម្បីជួសជុលនូវការខូចខាតទាំង អម្បាលម៉ានដែលបង្កឡើងដោយពួកខ្មែរក្រហម ។

ដើម្បីឲ្យសង្គមកម្ពុជាបានសះស្បើយ ការពិតដ៏ពេញលេញ មួយចំពោះអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហមត្រូវតែបាន យកមកពិនិត្យនិងផ្សព្វផ្សាយជាប្រយោជន៍ដើម្បីបង្កើតនូវ ប្រវត្តិសាស្ត្រមួយដែលប្រជាជនកម្ពុជា អាចបង្រៀនដល់កូនចៅ របស់ខ្លួនបាន ។ ទោះបីជាមានមានភ័ស្តុតាងដ៏សន្ធឹកសន្ធាប់ក្នុង ការចោទប្រកាន់សមាជិកនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើន ក៏ដោយ ក៏តុលាការអន្តរជាតិសម្រាប់កម្ពុជានាពេលខាងមុខ ដើម្បី ឲ្យមានប្រសិទ្ធភាពបំផុតត្រូវផ្តោតការចោទប្រកាន់តែចំពោះមេ ដឹកនាំជាន់ខ្ពស់នៃរបបនេះ ។ ការកំហិតខាងផ្នែករចនាសម្ព័ន្ធអាច ធ្វើឲ្យតុលាការពុំអាចដោះស្រាយបញ្ហាស្មុគស្មាញនៃឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍នៅកម្ពុជា បានពេញលេញ ដូច្នេះត្រូវ ការបង្កើតឲ្យមានគណៈកម្មការ ស្វែងរកការពិត ឬស្ថាប័ន ស៊ើបអង្កេតមួយបន្ថែមផ្សេង ទៀត ។ ដើម្បីធ្វើដំណើរឆ្ពោះ ទៅមុខកម្ពុជាត្រូវបង្កើតនូវ រូបភាពមួយដ៏ច្បាស់លាស់នៃ អតីតកាលរបស់ខ្លួនដើម្បីឲ្យ ប្រជាជនកម្ពុជាគ្រប់រូបរួម ចំណែកក្នុងការលើកកម្ពស់អនាគតរបស់ខ្លួន ។

អត្ថបទនេះធ្វើការពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់លើ លទ្ធផលនៃការស្ទង់មតិប្រជាជនកម្ពុជាដែលអ្នកនិពន្ធបានដឹកនាំ ធ្វើនាខែមិថុនា ឆ្នាំ១៩៩៧ (ក្រោមការជួយឧបត្ថម្ភពីសំណាក់ មជ្ឈមណ្ឌលឯកសារកម្ពុជា) ។ ដោយផ្អែកលើមូលដ្ឋាននៃការ សម្ភាសទាំងនេះ និងការយកទស្សនៈព្រះពុទ្ធសាសនាស្តីអំពី យុត្តិធម៌និងការផ្សះផ្សា អត្ថបទនេះបានជូនយោបល់ឲ្យមាន តុលាការសម្រាប់មេដឹកនាំកំពូលៗ និងគណៈកម្មការស្វែងរកការ ពិតមួយសម្រាប់សមាជិកខ្មែរក្រហមដែលមានឋានៈតូចតាចជាង នេះ ។ ការសិក្សានេះត្រូវបានស្នើឡើងដើម្បីកំណត់ថា តើទម្រង់ នៃការទទួលខុសត្រូវតាមផ្លូវច្បាប់ណាមួយដែលស័ក្តិសមសម្រាប់ ប្រជាជនកម្ពុជាក្នុងការដោះស្រាយឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម ។ ដើម្បីដឹងបានថាទម្រង់ណាមួយដែលអាចឆ្លើយតបទៅនឹងសេចក្តី ត្រូវការ និងកង្វល់របស់ប្រជាជនកម្ពុជាបំផុត អ្នកនិពន្ធបាន សម្ភាសប្រជាជនកម្ពុជា២៥នាក់ ដែលមានឋានៈសេដ្ឋកិច្ចសង្គម ផ្សេងៗគ្នាជុំវិញប្រធានបទថាតើពួកខ្មែរក្រហមគួរផ្តន្ទាទោសឬទេ ហើយបើផ្តន្ទាទោស គួរផ្តន្ទាទោសបែបណា ។

ដំបូងអត្ថបទនេះផ្តល់នូវប្រវត្តិសាស្ត្រសង្ខេបនៃនយោបាយ កម្ពុជាដែលបានកើតឡើងថ្មីៗនេះ ។ បន្ទាប់មកលើកយកមក

បង្ហាញដោយខ្លីៗអំពីប្រព័ន្ធនៃការទទួលខុសត្រូវផ្សេងៗដែលត្រូវបានអនុម័តយកដើម្បីដោះស្រាយស្ថានភាពនៃអំពើដ៏ច្រើនឥតគណនាក្នុងអតីតកាល ។ បន្ទាប់មកធ្វើការពិនិត្យលើប្រធានបទដែលផុសចេញពីការសម្ភាស ។ ប្រធានបទដែលកើតមានជាថ្មីដោយការលើកឡើងរបស់អ្នកដែលត្រូវបានសម្ភាសអាចផ្តល់នូវការយល់ដឹងជ្រៅជ្រះប្រកបដោយគុណភាពអំពីទស្សនៈរបស់ប្រជាជនកម្ពុជា ។ ដោយការយកកត្តាទាំងអស់នេះមកពិនិត្យពិចារណា អ្នកនិពន្ធបានបង្ហាញនូវការណែនាំអំពីទម្រង់ដែលគណៈកម្មការស្វែងរកការពិតកម្ពុជាគួរតែទទួលយក ។

ការទទូចរបស់រដ្ឋាភិបាលកម្ពុជាសុំឲ្យមានតុលាការក្នុងស្រុកដែលអាចយល់បានថាជាលទ្ធផលនៃគំនិតអធិបតេយ្យភាពនិយមគឺទង្វើមួយដែលពុំបានគិតគូរឲ្យបានវែងឆ្ងាយ ។ បើផ្អែកលើស្ថានភាពតុលាការកម្ពុជានាពេលបច្ចុប្បន្ន ការចូលរួមអន្តរាគមន៍ពីអន្តរជាតិជាការចាំបាច់ក្នុងការធានាឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដ៏សមស្របមួយ ។ ករណីនៃការចោទប្រកាន់របស់មេដឹកនាំដែលបានបញ្ជាឲ្យមានអំពើប្រល័យពូជសាសន៍ត្រូវបានបញ្ជាក់យ៉ាងល្អិតល្អន់ និងគួរឲ្យជឿជាក់ ប៉ុន្តែទោះជាយ៉ាងនេះក្តី បញ្ហាថាតើគួរចាត់វិធានការយ៉ាងដូចម្តេចចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយសមាជិកខ្មែរក្រហមថ្នាក់ក្រោមនៅពុំទាន់បានដោះស្រាយនៅឡើយទេ ។ ការធ្វើបណ្តឹងតាមផ្លូវច្បាប់ទៅលើបុគ្គលម្នាក់ ជាការពុំអាចធ្វើទៅបានហើយក៏ពុំសមស្របសម្រាប់កម្មាភិបាលរាប់ពាន់នាក់ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដែរ ។ ការកត់សម្គាល់តាមផ្លូវច្បាប់ទាំងនេះក៏ពុំអាចបង្កើតឡើងការចងចាំជាប្រវត្តិសាស្ត្រមួយឲ្យបានពិតប្រាកដនិងគ្រប់គ្រាន់សម្រាប់ប្រជាជនកម្ពុជាដែរ ។ បន្ទាប់ពីសង្គ្រាមអស់រយៈពេលជិត២០ឆ្នាំ ប្រទេសកម្ពុជាប្រឈមមុខនឹងផ្លូវមួយដ៏វែងឆ្ងាយដើម្បីត្រឡប់ទៅរកសភាពជាសះស្បើយដូចដើមវិញ ។ គណៈកម្មការស្វែងរកការពិត ជាផ្នែកដ៏សំខាន់ជាអាយុជីវិតនៃដំណើរការឲ្យមានការផ្សះផ្សាពិតប្រាកដមួយ ។ **(នៅមានត)** **ចាយ៉ា រ៉ាមជី**



អ្នកស្រុកជួបជុំគ្នាពិភាក្សាអំពីអំពើព្រៃផ្សៃរបស់ពួកខ្មែរក្រហម

# គ្រោះថ្នាក់នៃអព្យាក្រឹតភាព
# ការបែកបាក់ធំនាក់ធំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិក ឆ្នាំ១៩៦៥

**(តចប់)** នៅពេលដែលវៀតណាមខាងត្បូងយល់ស្រប បន្ទាប់ពីអតីតរដ្ឋមន្ត្រីការបរទេសអង់គ្លេស ហ្ព៉ាតុិន វ៉ូឃើរ ដាក់ការគាបសង្កត់ (នាយករដ្ឋមន្ត្រី ដានហួយ) ក្វាត់ យ៉ាងខ្លាំង ហើយនាយករដ្ឋមន្ត្រីថៃ សារិត ថាណារ៉ាត់ យល់ព្រមថា ថៃអាចសុខចិត្តចំពោះសន្និសីទកម្ពុជា ប្រសិនបើសហរដ្ឋអាមេរិកយល់ថាវាជាការសំខាន់ គ្រប់គ្នាហាក់ដូចជាប្រុងប្រៀបរង់ចាំការប្រកាសទទួលយកសន្និសីទដោយសហរដ្ឋអាមេរិកជាប្រទេសចុងក្រោយ ។ ប៉ុន្តែនៅថ្ងៃ២៤ ខែមេសា ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅវៀតណាមខាងត្បូង ថៃល័រ បានស្នើសុំឲ្យមានការពន្យារពេល៤៨ម៉ោង ដូច្នេះនាយករដ្ឋមន្ត្រីវៀតណាម ដាន ហួយក្វាត់ មានពេលសម្រាប់អូសទាញសមាជិករដ្ឋាភិបាលរបស់គាត់រួមទាំងយោធាផងឲ្យឯកភាពនេះជាការចាំបាច់ក្នុងការផ្តល់សេចក្តីយល់ព្រមចំពោះសន្និសីទនេះ ។ លោកនាយករដ្ឋមន្ត្រី ដានហួយក្វាត់ ពុំមានពេលដល់៤៨ម៉ោងទេ ព្រោះនៅថ្ងៃ២៥ ខែមេសា លោក រ៉ាស់ រដ្ឋមន្ត្រីការបរទេសអាមេរិកបានប្រកាសថា សហរដ្ឋអាមេរិកនឹងចូលរួមដោយរីករាយក្នុងសន្និសីទស្តីពីកម្ពុជា ប្រសិនបើខ្លួនត្រូវបានកោះអញ្ជើញ ។ លោក អេវើល ហារីមែន នឹងតំណាងឲ្យសហរដ្ឋអាមេរិកក្នុងសន្និសីទនេះ ។ ហេតុអ្វីបានជាសហរដ្ឋអាមេរិកគាំទ្រសន្និសីទយ៉ាងពេញទំហឹងនៅពេលនោះបន្ទាប់ពីការរារែកជាច្រើនសប្តាហ៍របស់ខ្លួន? ហេតុផលរបស់វាជាប់ពាក់ព័ន្ធជាមួយទ្រង់ សីហនុ ។ នៅថ្ងៃទី២៣ ខែមេសា ក្នុងសុន្ទរកថាសម្ពោធមហាវិថីសហភាពសូវៀតក្នុងក្រុងភ្នំពេញ ទ្រង់បានថ្លែងថា សហរដ្ឋអាមេរិកពិចារណាចូលរួមក្នុងសន្និសីទ ដោយសារមូលហេតុតែមួយគត់ គឺថាសន្និសីទនេះអាចនាំឲ្យមានការរីកចម្រើនអំពីបញ្ហាវៀតណាម ។ ទ្រង់បានទទូចបញ្ជាក់ថែមទៀតថា សន្និសីទណាមួយដែលនឹងធ្វើឡើង នឹងលើកមកពិភាក្សាតែបញ្ហាកម្ពុជាប៉ុណ្ណោះ ។ ភាពរីករវកាន់តែខ្លាំងក្លាថែមទៀតនៅពេលដែលទ្រង់ សីហនុ បានអះអាងនៅថ្ងៃបន្ទាប់នាពិធីបើកហាងលក់ម្ហូបអាហារថ្មីមួយថា ឥឡូវទ្រង់មិនចង់ឲ្យថៃ វៀតណាមខាងត្បូង ឬសហរដ្ឋអាមេរិកចូលរួមក្នុងសន្និសីទស្តីអំពីបញ្ហាកម្ពុជាទេ ។ ទ្រង់បញ្ជាក់ថា ទ្រង់ហាក់ដូចជាធុញទ្រាន់នឹងការបន្ទាក់រាំងស្ទះរបស់អាមេរិក ។ ទ្រង់បានថ្លែងយ៉ាងត្រង់ៗទៀតថា សហរដ្ឋអាមេរិក «មិនយល់ព្រម» ក៏មិននិយាយ «យល់ព្រម» ក៏មិននិយាយ ។ ទ្រង់ សីហនុ ហាក់ដូចជាចង់មានបន្ទូលថា ទ្រង់មិនចង់ឲ្យមានសន្និសីទនេះតែម្តងទៀតផង ។ ទ្រង់ សីហនុ បានប្រាប់អ្នកស្តាប់ថា «ថ្ងៃនេះយើងចាប់អារម្មណ៍ចំពោះសន្និសីទតិចជាងពេលដែលយើងស្នើសុំ ហើយក្នុងខណៈនោះពួកអង់គ្លេសាក់សុងរារាំងយើង» ។ «វាហួសពេលដែលត្រូវរៀបចំសន្និសីទដើម្បីប្រាប់ការពិតហើយ ...ពីព្រោះអ្វីៗបានវិវត្តន៍តាមរបៀបមួយដែលថាវាពុំសំខាន់ដែលត្រូវកោះប្រជុំសន្និសីទនេះទៀតទេ» ។

ការកត់សម្គាល់ផ្ទុយស្រឡះពីពេលមុនរបស់ទ្រង់ សីហនុ បានជំរុញឲ្យមានប្រតិកម្មពីសហរដ្ឋអាមេរិក ។ រដ្ឋមន្ត្រីការបរទេសអាមេរិក រ៉ាស់ បានពន្យល់អ្នកការទូតអាមេរិកប្រចាំក្រុងបាងកកនិងវៀងច័ន្ទដូចខាងក្រោមនេះ÷

«នាថ្ងៃអាទិត្យ យើងបានជួបប្រទះនឹងហេតុការណ៍មួយគឺការបោះពុម្ពផ្សាយចំណាប់អារម្មណ៍របស់ទ្រង់ សីហនុ...ហ្ព៉ាតុិន វ៉ូឃើរ កំពុងរៀបចំខ្លួនចេញពីក្រុងសាយហ្គន (ហូជីមិញ) មកកាន់ទីក្រុងភ្នំពេញ ។ តាមរយៈការប្រកាសអំពីការយល់ព្រមរបស់អាមេរិកនិងវៀតណាមជាមុន វាហាក់ដូចជាមានហេតុផលខ្លះអាចឲ្យយើងសង្ឃឹមថាយើងអាចបង្ការការឆ្លើយតបជាផ្លូវការរបស់កម្ពុជាចំពោះ ហ្ព៉ាតុិន វ៉ូឃើរ ថា ការចូលរួមរបស់អាមេរិកនិងវៀតណាមក្នុងសន្និសីទគឺមិនអាចទទួលយកបាន ។ ការប្រកាសត្រូវបានគិតថាអាចបង្ការនូវសំណើរបស់រដ្ឋាភិបាលកម្ពុជាដែលសុំឲ្យមានតំណាងរបស់វណសិរ្សរំដោះ ។ ចំពោះយើង កត្តាទាំងនេះហាក់ដូចជាបញ្ជាក់ពីភាពត្រឹមត្រូវនៃការប្រថុយប្រថានដែលថាផ្ទុយទៅវិញការប្រកាសអាចទទួលបាននូវការអះអាងជាផ្លូវការ

ក៏ដូចជាផលមិនល្អ ដែលហាក់ដូចជាការបារម្ភហួសហេតុអំពីសន្និសីទ»។

បន្ទាប់ពីថ្ងៃដែល រ៉ាស់ ប្រកាសថាសហរដ្ឋអាមេរិកមានបំណងបញ្ជូនគណៈប្រតិភូចូលរួមក្នុងសន្និសីទ ប្រជាជនកម្ពុជាក៏បានវាយប្រហារស្ថានទូតអាមេរិក ។ ជាការគួរឲ្យភ្ញាក់ផ្អើល បាតុកម្មពុំបានធ្វើឲ្យមានការរួញរាដល់ការចាប់អារម្មណ៍របស់អាមេរិកចំពោះសន្និសីទឡើយ ។ ច្រើនសប្តាហ៍បន្ទាប់មក សហរដ្ឋអាមេរិកដែលសន្មតថាបាតុកម្មពុំមានការទាក់ទងដល់សន្និសីទ បានបន្តយ៉ាងសកម្មធ្វើការស្ទង់មើលភាពអាចកើតមាននៃសន្និសីទ ។ ការយល់ឃើញរបស់អាមេរិកអាចពិតប្រាកដ ។ នៅថ្ងៃទី៣០ ខែមេសា គណៈរដ្ឋមន្ត្រីកម្ពុជាត្រូវបានដឹងថាបានបោះឆ្នោតជាឯកច្ឆន្ទគាំទ្រការចូលរួមសន្និសីទក្រុងហ្សឺណែវ ទោះជាពេលនោះទ្រង់ សីហនុ ស្ថិតនៅក្រៅស្រុកហើយអាចបដិសេធរឿងនេះនៅពេលត្រឡប់មកវិញក្តី ។ នៅថ្ងៃដដែលនោះដែរ រ៉ាស់ បានប្រាប់ឯកអគ្គរដ្ឋទូតសូវៀត អាណាតូលី ដូប៊ីនីន ថា សហរដ្ឋអាមេរិកពុំធ្លាប់បានទទួលពាក្យជាផ្លូវការថាខ្លួនពុំត្រូវបានស្វាគមន៍ឲ្យចូលរួមក្នុងសន្និសីទនេះទេ ។

ការដាច់ទំនាក់ទំនងការទូតនៅថ្ងៃទី៣ ខែឧសភា ពុំបានធ្វើឲ្យរលត់សេចក្តីសង្ឃឹមអំពីសន្និសីទឡើយ (ទោះបីជាសន្និសីទនេះត្រូវបានគិតថានឹងរលត់ក៏ដោយ) ។ នៅថ្ងៃទី១១ ខែឧសភា មន្ត្រីអាមេរិកគឺលោក ប៉ែរបេសិន បានរាយការណ៍ថា សេចក្តីសង្ឃឹមនៅមាននៅឡើយ ។ ពីរថ្ងៃក្រោយមករដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានសេចក្តីសង្ឃឹមដោយខ្លួនបានប្រាប់រដ្ឋាភិបាលអង់គ្លេសថាខ្លួននៅចាប់អារម្មណ៍អំពីរឿងនេះនៅឡើយ ។ ចាប់ពីថ្ងៃនោះដល់ដំណាច់ខែ ទ្រង់ សីហនុ បានធ្វើឲ្យកាន់តែច្បាស់ឡើងៗថា ទ្រង់ពុំចង់ឲ្យមានសន្និសីទទៀតទេ ហើយនៅដំណាច់ខែមិថុនា សហភាពសូវៀតអះអាងថាពុំមានការចេញការអញ្ជើញណាមួយទៀតទេ ។

ហេតុអ្វីបានជានៅពេលដែលអង់គ្លេសនិងអាមេរិកចុងក្រោយបង្អស់មានបំណងទ្រទ្រង់សន្និសីទនៅពេលដែលថៃនិងវៀតណាមខាងត្បូងយល់ព្រម និងនៅពេលដែលចិន សហភាពសូវៀត វៀតណាមខាងជើង និងរណសិរ្សរំដោះជាតិបានគាំទ្រផងនោះ ទ្រង់ សីហនុ បានធ្វើឲ្យរាំងស្ទះការងារនេះទៅវិញ?


កងរាជអាវុធហត្ថនៃរបបសាធារណរដ្ឋ ថតនៅពេលសម្រាកពីការងារ

ទ្រង់អាចត្រូវបានធ្វើឲ្យជឿជាក់ដូចដែលទ្រង់បានមានបន្ទូលថា អាមេរិកបានបង្អាក់វាយូរពេកហើយ ហើយបើចុងបញ្ចប់ខ្លួនចាប់អារម្មណ៍គឺគ្រាន់តែនិយាយជាមួយគូប្រឆាំងរបស់ខ្លួនអំពីបញ្ហាវៀតណាម ទ្រង់បានជឿជាក់ថា យ៉ាងហោចណាស់ក៏មានក្រុមខ្លះក្នុងរដ្ឋាភិបាលអាមេរិកប្រឆាំងនឹងព្រះអង្គដែរ ។ ពួកនោះនៅតែខ្វាចការរីករាលដាលនៃអព្យាក្រឹតភាពនិយម ហើយជឿថា សីហនុ ដែលជាអ្នកការពារដ៏ឆ្នើមនៃអព្យាក្រឹតភាពនិយមគឺជាគ្រោះថ្នាក់ចំពោះនយោបាយអាមេរិកដោយសំអាងលើហេតុផលមួយដែលយើងពុំដឹងច្បាស់ ។

ការឆ្លើយតបជាវិជ្ជមាន និងឆាប់រហ័សរបស់អាមេរិកអាចមានផ្លែផ្កាចំពោះការយល់ឃើញរបស់ទ្រង់ សីហនុ ចំពោះនយោបាយរបស់អាមេរិកដែលបកស្រាយសេចក្តីសម្រេចរបស់ទ្រង់ពុំឲ្យសន្និសីទកើតមានឡើង ។ ប៉ុន្តែទ្រង់ សីហនុ ក៏បានធ្វើសកម្មភាពក្នុងហេតុផលមួយដែលមិនទាក់ទងដោយផ្ទាល់ជាមួយនឹងការបង្អាក់របស់អាមេរិកដែរ ។ នៅក្នុងស្នាដៃមួយដែលរៀបរាប់អំពីជីវប្រវត្តិរបស់ទ្រង់ សីហនុ លោក មីលថន អូស្បន បានសរសេរថាក្នុងសន្និសីទ ក្រុងហ្សាកាតា ដែលរៀបចំឡើងដើម្បីអបអរខួបទី១០នៃសន្និសីទក្រុងបានឌុង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានស្នើសុំក្នុងនាមឯកឧត្តមផ្ទាល់កុំឲ្យទ្រង់ សីហនុ ចូលរួមក្នុងសកម្មភាពជាមួយសន្និសីទ ដែលទ្រង់បានគាំទ្រជាយូរមកហើយនោះ ពីព្រោះវាអាចធ្វើឲ្យមានផលមិនល្អដល់សម្ព័ន្ធមិត្តវៀតណាមដែលជាសម្ព័ន្ធមិត្តរបស់ប្រទេសចិន ។ លោក អូស្បន បានសរសេរថា «ឆ្លើយតបចំពោះសំណើនេះគឺមួយឆ្នាំ មុនពេលដែលទ្រង់ត្រូវបានផ្តល់កន្លែងកិត្តិយសក្បែរ ម៉ៅ សេទុង ។ ក្នុងពិធីអបអរខួបទី១៥ នៃបដិវត្តន៍ចិនក្នុងក្រុងប៉េកាំង ទ្រង់ សីហនុ ពុំមានជម្រើសផ្សេងក្រៅពីធ្វើតាមសំណើនោះឡើយ» ។

ប្រភពអាមេរិក និងចិន បានបង្ហាញភ័ស្តុតាងអំពីការអះអាងដែលពុំមានមូលដ្ឋានរបស់ អូស្បន នេះ ។ នៅព្រលឹមថ្ងៃទី ២៦ ខែមេសា (ថ្ងៃបាតុកម្ម) របាយការណ៍របស់សេ.អ៊ី.អាមួយបានសន្និដ្ឋានថាការគាំទ្ររបស់ចិនចំពោះសន្និសីទជានិច្ចកាលគ្រាន់តែជាការបន្លំភ្នែកប៉ុណ្ណោះ ពីព្រោះចិនខ្លាចការកើនឡើងឥទ្ធិពលរបស់សូវៀតលើក្រុងហាណូយ ។ ដូច្នេះចិនត្រូវធ្វើ «ការប្រឹងប្រែងយ៉ាងខ្លាំងក្លា...កុំឲ្យសន្និសីទនេះចេញជារូបរាងដោយធ្វើឲ្យនាយករដ្ឋមន្ត្រីកម្ពុជាជឿជាក់ថា ការចរចាគឺពុំចាំបាច់ទេ» ។ ពីរសប្តាហ៍ក្រោយមក ឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងភ្នំពេញ អ៊ីយប៊ែរ អេម៉ា អាហ្គូ បានប្រាប់ ប៊ែរចេសិន សឹងតែ


លោកសេនាប្រមុខ លន់ ណុល

ដូចគ្នាដែរថា «ស្ទើរតែប្រាកដមួយរយភាគរយ... ជូ អេនឡាយ បានប្រាប់ទ្រង់ សីហនុ ក្នុងក្រុងហ្សាកាតាថា ចិនកុម្មុយនិស្ត មិនប្រាថ្នាឲ្យមានសន្និសីទក្នុងពេលបច្ចុប្បន្ននេះទេ ហើយសីហនុ មានបំណងបំពេញបំណងមិត្តរបស់គាត់» ។ ចិនចាត់ទុកសន្និសីទដែលបានស្នើឡើងនេះជាល្បិចអាក្រក់របស់អាមេរិកដើម្បីយកជ័យជម្នះនៅវៀតណាម ។

ដូច្នេះការដកការគាំទ្ររបស់ទ្រង់ សីហនុ ក្រោមឥទ្ធិពលរបស់ចិន ហាក់ដូចជាហេតុផលផ្ទាល់ដែលនាំឲ្យសន្និសីទពុំបានលេចរូបរាងឡើង ។ ដោយបានកត់សម្គាល់ថា សន្និសីទនឹងពុំអាចត្រូវបានរៀបចំឡើងទៀតទ្រង់ សីហនុ បណ្តោយឲ្យមានបាតុកម្មនៅទូតអាមេរិក ដែលនេះជាលទ្ធផលនៃកំហឹងជាយូរនិងជាប្រចាំរបស់ព្រះអង្គចំពោះអាមេរិកដែលត្រូវបានចោទថាគាំទ្រខ្មែរសេរីដែលធ្វើប្រតិបត្តិការយោធាឆ្លងព្រំដែនពីប្រទេសវៀតណាម ជាលទ្ធផលនៃការបង្អាក់របស់អាមេរិកចំពោះសន្និសីទ និងការក្តៅក្រហាយជារឿយៗរបស់ព្រះអង្គចំពោះឥរិយាបថអាមេរិកដែលចាត់ទុកទ្រង់ និងកម្ពុជាថាជាអាយ៉ងរបស់ខ្លួន និងជាលទ្ធផលនៃសម្ពាធនយោបាយក្នុងប្រទេស ។ ទ្រង់បានធ្វើការសុំទោសតាមរយៈអត្ថបទមួយរបស់ គ្រីស័រ ។

ទោះជាសន្និសីទជាបញ្ហាសំខាន់ដែលនាំទៅដល់ការធ្វើបាតុកម្មក៏ពិតមែន ប៉ុន្តែវាពុំមែនជាមូលហេតុសំខាន់បំផុតនៃការផ្តាច់ទំនាក់ទំនងការទូតឡើយ ។ តាមពិតទៅវារឹតតែមិនមែនទៅទៀតដែលថា ទ្រង់ សីហនុ ចង់ឲ្យបាតុកម្មនេះក្លាយជាដើមហេតុនៃការផ្តាច់ទំនាក់ទំនងនោះ ។ វាសឹងតែប្រាកដមួយរយភាគរយដែលថាហេតុផលផ្ទាល់នៃការផ្តាច់នេះគឺឧបទ្ទវហេតុមួយទៀតនៅព្រំដែន ។ នៅថ្ងៃទី២៨ ខែមេសា ពីរថ្ងៃបន្ទាប់ពីថ្ងៃបាតុកម្ម យន្តហោះបួនគ្រឿងដែលគិតថាជាយន្តហោះវាយប្រហាររបស់វៀតណាមខាងត្បូង បានវាយប្រហារមកលើភូមិច័ន្ទតាទេព (ឬជាមតាទេព) និងភូមិម្រាមទាករបស់កម្ពុជាក្នុងខេត្តកំពង់ចាម ។ ភូមិទាំងពីរនេះស្ថិតនៅប្រមាណ៤គីឡូម៉ែត្រពីព្រំដែនវៀតណាម ។ ក្មេងប្រុសម្នាក់អាយុ១៣ឆ្នាំ ត្រូវបានសម្លាប់ហើយអ្នកផ្សេងទៀតត្រូវបានធ្វើឲ្យរងរបួសយ៉ាងធ្ងន់ធ្ងរ ។ អនុពន្ធយោធាអាមេរិក ដែលបានចុះទៅដល់កន្លែងនៅថ្ងៃកើតហេតុបានអះអាងអំពីការស្លាប់និងបានរកឃើញស្នាមគ្រាប់បែក និងគ្រាប់រ៉ុក្កែត៣៥ ។ បើទោះបេសិនបានទាយទុកជាមុនថា ទ្រង់ សីហនុ នឹងផ្តាច់ទំនាក់ទំនងដោយសារឧបទ្ទវហេតុដែលកើតមាននៅព្រំដែនពុំមែនដោយអត្ថបទរបស់ទស្សនាវដ្តីញូវស៊ីកទេ ។ ជាការប៉ុនប៉ងចុង


ព្រះករុណា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ

ក្រោយដើម្បីស្រោចស្រង់ស្ថានការណ៍ទ្រង់បានស្នើឲ្យមានការសុំទោស និងបង់សងភ្លាមៗដល់ជនរងគ្រោះ ។

ការពិតស្ថានការណ៍អាក្រក់ជាងការដែល ប៊ែរចេសិន បានគិតពីដំបូងទៅទៀត ។ ការស៊ើបអង្កេតភ្លាមៗបានកំណត់ថា យន្តហោះនោះគឺរបស់អាមេរិក ពុំមែនរបស់វៀតណាមទេ ។ ជាលទ្ធផលក្នុងកិច្ចប្រឹងប្រែងបង្ការការកាត់ផ្តាច់ទំនាក់ទំនង ប៊ែរចេសិន បានស្នើឲ្យសហរដ្ឋអាមេរិកធ្វើការសុំទោស និងផ្តល់សំណងជាបន្ទាន់ ។ កំណត់ហេតុនេះត្រូវបានរៀបចំនិងបញ្ជូនទៅសេតវិមាន នៅថ្ងៃទី១ ខែឧសភា ។ ប៉ុន្តែកំណត់ហេតុនោះពុំត្រូវបានបញ្ជូនឲ្យទ្រង់ សីហនុ ទេ ។ នេះប្រហែលជាការព្យាយាមទប់ស្កាត់ការផ្តាច់ទំនាក់ទំនង ។ បន្ទាប់ពីការផ្តាច់ទំនាក់ទំនងរវាងប្រទេសទាំងពីរ កម្ពុជាមន្ត្រីក្រសួងការបរទេសមួយរូបដែលសុំមិនបញ្ចេញឈ្មោះ បានប្រាប់អំពីការប៉ាន់ស្មានរបស់ខ្លួនឲ្យភ្នាក់ងារ សេ.អ៊ី.អា ម្នាក់ដឹងថា ហេតុផលដែលទ្រង់ សីហនុ ផ្តាច់ទំនាក់ទំនងគឺរដ្ឋាភិបាលវៀតណាមពុំទទួលស្គាល់អំពីការភ័ន្តច្រឡំក្នុងការទម្លាក់គ្រាប់បែកលើភូមិកម្ពុជានៅថ្ងៃទី២៨ ខែមេសា ។

នៅពេលដែលទ្រង់ សីហនុ បានផ្តាច់ទំនាក់ទំនងជំនួយការម្នាក់បានប្រាប់ប្រធានាធិបតី ចនសុន ថា ទ្រង់ធ្វើនេះដោយផ្អែកលើមូលដ្ឋានពីរៈ អត្តបទរបស់ គ្រីស័រ និងការទម្លាក់គ្រាប់បែកនៅព្រំដែន ។ លោក ម៉ាក់ ចច ប៊ុនឌី ដែលជាទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានាធិបតីក៏បានប្រាប់លោកប្រធានាធិបតីដែរថា «កម្ពុជាបានដាក់បន្ទុកស្មើគ្នាលើទស្សនាវដ្តីញូវស៊ីក និងការវាយប្រហារតាមអាកាសមកលើភូមិរបស់កម្ពុជា» ។ ជំនួយការរបស់លោកប្រធានាធិបតី ចនសុន បាននាំឲ្យលោកប្រធានាធិបតីយល់ខុស ព្រោះកំណត់សម្គាល់ជាក់ស្តែងការផ្តាច់ទំនាក់ទំនងគឺទាក់ទិនតែជាមួយការវាយប្រហារលើភូមិកម្ពុជាប៉ុណ្ណោះ (ដែលកម្ពុជានៅតែសន្មតថាជាសកម្មភាពរបស់វៀតណាមខាងត្បូង) ។ ពុំមានកត្តាផ្សេងទៀតរាប់ទាំងអត្តបទរបស់ គ្រីស័រ ផងត្រូវបានលើកឡើងនោះទេ ។ ការភ័ន្តច្រឡំដំបូងអំពីភាពចម្បងនៃការវាយប្រហារនៅព្រំដែនចំពោះមូលហេតុនៃការផ្តាច់ទំនាក់ទំនងបានរលាយបាត់ភ្លាមៗ ។ មន្ត្រីកម្ពុជាបានកំណត់ច្បាស់ថា ការបញ្ចប់សកម្មភាពឆ្លងកាត់ព្រំដែនគឺជាលក្ខខណ្ឌតែមួយគត់នៃការធ្វើឲ្យមានទំនាក់ទំនងជាថ្មី ។ ទ្រង់ សីហនុ បានមានបន្ទូលប្រាប់មន្ត្រីបារាំងថា ការផ្តាច់ទំនាក់ទំនងនេះបណ្តាលមកពីការលុកលុយជាច្រើនលើកច្រើនសានៅតាមព្រំដែន ហើយទ្រង់រីករាយនឹងធ្វើឲ្យមានទំនាក់ទំនងជាថ្មី ប្រសិនបើសហរដ្ឋអាមេរិកបញ្ឈប់បញ្ហាទាំងនោះ ។ មន្ត្រីក្រសួងការបរទេសរូបនោះបានឲ្យដឹងទៀតថា បើភ្លាមៗនោះវៀតណាមខាងត្បូងព្រមទទួលខុសត្រូវសូមទោសហើយផ្តល់សំណងនោះ កម្ពុជាក៏អាចបិទភ្នែក បិទច្រមុះ ចំពោះឧបទ្ទវហេតុខ្លះៗនៅតាមព្រំដែនបាន ។

ដូច្នេះការវាយប្រហារដោយទម្លាក់គ្រាប់បែក និងគ្រាប់រ៉ុក្កែតលើភូមិច័ន្ទតាទេព និងភូមិម្រាមទាក គឺជាមូលហេតុផ្ទាល់នៃការផ្តាច់ទំនាក់ទំនង ។ ឧបទ្ទវហេតុបែបនេះរាប់រយដែលពាក់ព័ន្ធនឹងបុគ្គលិកវៀតណាមខាងត្បូង ឬបុគ្គលិកអាមេរិក ក៏ជាមូលហេតុចម្បងមួយដែរ ។ ការចោទថាអាមេរិកគាំទ្រចំពោះខ្មែរសេរីដែលជាសត្រូវដ៏ជូរចត់របស់ទ្រង់ សីហនុ ក៏ដូចជាការបផ្អាក់សន្និសីទហ្សឺណែវដែលបានស្នើឡើងរបស់អាមេរិក សុទ្ធតែរួមចំណែកបណ្តាលឲ្យមានការផ្តាច់ទំនាក់ទំនងខាងលើ ។ កត្តាផ្សេងទៀតដែលពុំសូវមានលក្ខណៈជាក់ស្តែងដូចជាឥរិយាបថរបស់អាមេរិកដែលទុកកម្ពុជាដូចជាអាយ៉ងរបស់ខ្លួន និងរឿងដែលធ្វើឲ្យឃើញអាក្រក់ជាងភាពជាក់ស្តែងក្នុងកាសែតអាមេរិក បានរួមចំណែកបង្កើតឲ្យមានបរិយាកាសប្រឆាំងអាមេរិកជាទូទៅមួយក្នុងប្រទេសកម្ពុជា ។

ចំណុចក្តៅនៃសង្គ្រាមវៀតណាមជាមូលហេតុដែលបានធ្វើឲ្យវិវាទដ៏តានតឹងដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាងរបស់ខ្លួន (វៀតណាមខាងត្បូង និងថៃ) កាន់តែមានភាពធ្ងន់ធ្ងរថែមទៀត ។ វិវាទនេះបានរុញច្រានភាពតានតឹងក្នុងទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកដែលជាសម្ព័ន្ធមិត្តរបស់ប្រទេសទាំងពីរនេះឲ្យកាន់តែមានសភាពដុយស្រុយខ្លាំងឡើង ។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការគិតគូរអំពីសង្គ្រាមត្រជាក់ជាសំខាន់ដែលបានដាក់ឥទ្ធិពលដ៏ស្រួចស្រាល់ដល់អ្នកធ្វើនយោបាយអាមេរិក ។ អ្នករៀបចំនយោបាយអាមេរិកទាំងនោះ ពុំមែនពុំដឹងអំពីចរិតនៃបញ្ហារបស់កម្ពុជាក្នុងតំបន់នោះទេ ក៏ប៉ុន្តែជាទូទៅអ្នករៀបចំនយោបាយទាំងនោះពិនិត្យការវិវឌ្ឍ

នៃសភាពការណ៍តាមរយៈកែវឆ្លុះនៃសង្គ្រាមត្រជាក់ ជាពិសេសតាមរយៈវិវាទដ៏តានតឹងប្រឆាំងនឹងពួកកុម្មុយនិស្តចិន ពីព្រោះថានៅត្រឹមឆ្នាំ១៩៦៥ អ្នករៀបចំនយោបាយអាមេរិក បានដឹងយ៉ាងច្បាស់អំពីវិវាទដ៏តានតឹងរវាងសូវៀត និងចិន ។ សូម្បីតែនៅពេលដែលកត្តាតំបន់ត្រូវបានទទួលស្គាល់បែបនេះក៏ដោយ សហរដ្ឋអាមេរិកជានិច្ចកាលស្ទើរតែយល់ថាកត្តាទាំងនេះពុំសំខាន់ស្មើទៅនឹងការពិចារណាអំពីសង្គ្រាមត្រជាក់ឡើយ ។ វាជាបច្ច័យដ៏អាក្រក់ដែលធ្វើឲ្យទ្រង់ សីហនុ ខ្វល់ជាខ្លាំង ក៏ប៉ុន្តែក្នុងកាលៈទេសៈនោះការប្រឆាំងនិងការរីករាលដាលនៃលទ្ធិកុម្មុយនិស្តជាអន្តរជាតិជាកត្តាសំខាន់ជាងដែលជាអត្ថិភាពត្រូវយកចិត្តទុកដាក់ជាដំបូង ។

ការប៉ាន់ស្មាននេះពុំមែនមានន័យថាស្នើកុំឲ្យទ្រង់ សីហនុ ទទួលខុសត្រូវចំពោះការធ្វើឲ្យទំនាក់ទំនងមានលក្ខណៈកាន់តែយ៉ាប់យ៉ឺននោះទេ ។ ប៉ុន្តែសំខាន់បំផុតទ្រង់ សីហនុ ពុំមានការលម្អៀងទៅរកការគាំទ្រពួកកុម្មុយនិស្តនោះទេ ។ តាមពិតទ្រង់បាននិងកំពុងលុបបំបាត់ពួកកុម្មុយនិស្ត និងពួកឆ្វេងនិយមក្នុងប្រទេសរបស់ទ្រង់ ។ ទ្រង់យល់ថា ពួកនេះជាការគំរាមកំហែងដល់របបរាជានិយម ហើយទ្រង់ខ្លាចការបង្រួបបង្រួមរបស់វៀតណាមនៅក្រោមការគ្រប់គ្រងរបស់ពួកកុម្មុយនិស្ត ។ បំណងដ៏លើសលប់របស់ទ្រង់គឺការពារឯករាជ្យរបស់កម្ពុជា ហើយតាមការប៉ាន់ស្មានផ្ទាល់របស់ទ្រង់ នយោបាយមិនចូលបក្សសម្ព័ន្ធបម្រើផលប្រយោជន៍ច្រើនបំផុតសម្រាប់កម្ពុជា ។ ការជ្រើសរើសបន្ទាត់នយោបាយនេះកាន់តែមានភាពសមហេតុផលថែមទៀតចាប់ពីពេលមានគូសត្រូវដ៏យូរអង្វែងពីរនៅជំរំខាងលិច ។ ជាងនេះទៅទៀតនៅដំណាក់កាលចុងក្រោយបំផុតទ្រង់ជឿថា សហរដ្ឋអាមេរិកពុំអាចយកជ័យជម្នះនៅវៀតណាមបានទេ ហើយដើម្បីការពារបូរណភាពនៃប្រទេសរបស់ទ្រង់ ទ្រង់ចាំបាច់ត្រូវមានទំនាក់ទំនងល្អជាមួយ ចិន និងបណ្តាប្រទេសកុម្មុយនិស្តផ្សេងៗទៀត ។ តាមដែលឯកអគ្គរដ្ឋទូត ស្ត្រុស បានរំឭក ទ្រង់ សីហនុ ពុំមែនកុម្មុយនិស្តនិយម ប៉េកាំងនិយម ឬហាណូយនិយមទេ ទ្រង់គឺសីហនុនិយម កម្ពុជានិយម ហើយទ្រង់ធ្វើតែអ្វីៗដែលទ្រង់យល់ថានឹងធ្វើឲ្យមានការរីកចម្រើនដល់ប្រទេសរបស់ព្រះអង្គផ្ទាល់ ។ ទ្រង់ចង់រក្សាវាជាប្រទេសឯករាជ្យមួយ ។ ដូច្នេះមូលហេតុចម្បងនៃបរាជ័យក្នុងការរក្សាទំនាក់ទំនងមិត្តភាពរវាងកម្ពុជានិងអាមេរិក គឺអសមត្ថភាពរបស់អាមេរិកក្នុងការបង្កើតនូវនយោបាយមួយដែលមានភាពទន់ភ្លន់គ្រប់គ្រាន់ដើម្បីសម្របនឹងអព្យាក្រឹតភាពរបស់កម្ពុជាក្នុងពេលដែលខ្លួនធ្វើការប្រឆាំងនឹងនិន្នាការវាតទីនិយមដ៏គ្រោះថ្នាក់របស់ពួកកុម្មុយនិស្តក្នុងតំបន់អាស៊ី-អគ្នេយ៍ ។

ថ្វីបើការប្រមើលមើលដ៏ស៊ីជម្រៅអំពីផលវិបាកនៃការផ្តាច់ទំនាក់ទំនងការទូតវាហួសអំពីក្របខ័ណ្ឌនៃអត្ថបទនេះក្តី ការវាយតម្លៃជាបឋមមួយបានឲ្យដឹងថាវាជាផ្នែកមួយនៃព្រឹត្តិការណ៍បន្តបន្ទាប់គ្នាមួយខ្សែដែលនាំទៅដល់សោកនាដកម្មមួយចំពោះកម្ពុជា ។ ទំនាក់ទំនងការទូតពុំត្រូវបានស្តារបនាឡើងវិញរហូតដល់ឆ្នាំ១៩៦៩ ។ ក្នុងអំឡុងពេលនោះសហរដ្ឋអាមេរិកក៏បានប៉ុនប៉ងបង្កអស្ថេរភាពដល់រដ្ឋាភិបាលរបស់ទ្រង់សីហនុ ។ នៅឆ្នាំ១៩៦៩ សហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកជាសម្ងាត់លើទឹកដីកម្ពុជា ។ បន្ទាប់មកក្នុងខែមីនា ឆ្នាំ១៩៧០ លន់ ណុល និងស៊ីសុវត្ថិ សិរិមតៈ បានទម្លាក់ទ្រង់ សីហនុ តាមរយៈរដ្ឋប្រហារមួយដែលមានលក្ខណៈអាមេរិកនិយម (ហើយអាចទ្រទ្រង់ដោយសហរដ្ឋអាមេរិកផង) ។ ដោយខ្វល់យ៉ាងខ្លាំងនឹងការផ្លាស់ប្តូរស្ថានការណ៍នេះ ទ្រង់ សីហនុ បានអំពាវនាវឲ្យប្រជាជនធ្វើការគាំទ្រចលនាប្រឆាំងរបស់ខ្មែរក្រហម ។ ក្នុងខែមេសា ទ័ពអាមេរិកនិងវៀតណាមខាងត្បូងបានចូលលុកលុយប្រទេសកម្ពុជាដោយសំអាងថាធ្វើការបំផ្លាញការិយាល័យមជ្ឈិមរបស់ពួកកុម្មុយនិស្តសម្រាប់គ្រប់គ្រងវៀតណាមខាងត្បូង ។ សកម្មភាពទាំងពីរខាងលើបានធ្វើឲ្យសង្គមកម្ពុជាកាន់តែមានអស្ថិរភាពខ្លាំងឡើងថែមទៀត ។ ទាំងនេះបាននាំទៅដល់សង្គ្រាមស៊ីវិល ៥ឆ្នាំ ដែលបណ្តាលឲ្យមានការវិនាសខ្ទេចខ្ទី ។ ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ប្រទេសទាំងមូល ហើយបានដឹកនាំប្រទេសយ៉ាងសាហាវឃោរឃៅបំផុតដែលក្នុងពេលនោះប្រជាជនកម្ពុជាប្រហែល២លាននាក់ (ក្នុងចំណោមប្រជាជនទាំងអស់ដែលមានចំនួនមិនដល់៨លាននាក់ផង) បានស្លាប់បាត់បង់ជីវិត ។ ប្រសិនបើសហរដ្ឋអាមេរិកនិងកម្ពុជាអាចដោះស្រាយវិវាទរបស់ខ្លួនដោយឈរលើដំហរស្ថាបនាម៉្លេះសមកម្ពុជាអាចត្រូវបានរួចចាកផុតពីរបបវាលពិឃាតដែលកម្ពុជាបានឆ្លងកាត់ក្នុងអតីតកាលដ៏ថ្មីៗនេះ ។

**វ៉ែយនតុន វ៉េ្លមម័រ**

# គំរូមួយនៃភ័ស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

## (ភាគ២)



គណៈប្រតិភូចិនទស្សនាអង្គរវត្ត

ជាបន្ថែម ក្នុងខណៈដែលអ្នកទោសដែលបានសារភាពអំពីសកម្មភាពរបស់ខ្លួនតំណាងឲ្យបក្សកុម្មុយនិស្តកម្ពុជានិងព្រមទាំងបាន «សារភាព» ថាបានប្រព្រឹត្តសកម្មភាពដែលក្បត់នឹងបក្សកុម្មុយនិស្តកម្ពុជាផងនោះ អ្នកទោសមួយចំនួនដែលចម្លើយសារភាពរបស់ពួកខ្លួនត្រូវបានចម្លងជូនដល់មេដឹកនាំខ្មែរក្រហមដែលនៅរស់រៀបរាប់យ៉ាងវែងអន្លាយអំពី «សេចក្តីណែនាំ» ឬ «ផែនការ» ដែលទទួលបានពី «អង្គការ» ដែលពាក់ព័ន្ធដល់ការ «កម្ទេច» ឬ «ការបោសសម្អាត» ដែលជាពាក្យរបស់បក្សកុម្មុយនិស្តកម្ពុជាប្រើប្រាស់ជារឿយៗជំនួសឲ្យពាក្យ «ប្រហារជីវិត» ។ សាច់រឿងទាំងនេះដែលផ្តល់ដោយអ្នកទោស ជួនកាលត្រូវបានគាំទ្រដោយចំណាររបស់អ្នកសួរចម្លើយ ។ ចម្លើយសារភាពផ្នែកនេះអាចផ្តល់នូវភ័ស្តុតាងយ៉ាងហោចណាស់ភ័ស្តុតាងបញ្ជាក់អំពី «ការដឹងឮ» ដែលមានពិរុទ្ធភាពចំពោះមនុស្សមួយចំនួនដែលចម្លើយសារភាពនេះ ត្រូវបានចារបញ្ជូនទៅឲ្យ ពាក់ព័ន្ធនឹងការសម្លាប់មន្ត្រីអតីតរបបសាធារណរដ្ឋ និង «ជនក្បត់» របស់បក្សដែលត្រូវបានចោទប្រកាន់ដោយពុំមានគោលសំអាង ។ នៅទីបញ្ចប់អ្នកទាំងឡាយដែល «ចម្លើយសារភាព» ត្រូវបានផ្ញើបញ្ជូនគឺស្ថិតនៅក្នុងមុខតំណែងដែលគួរតែត្រូវបានដឹងតាមរយៈឯកសារនៃការចាប់ខ្លួនទាំងនេះនៅក្នុងចម្លើយសារភាព ។ ចម្លើយសារភាពភាគច្រើនមានបញ្ជីរាយនាមបន្ថែម និងពត៌មានលម្អិតអំពី «ជនក្បត់» ដែលត្រូវបានកត់ត្រាឈ្មោះនៅក្នុងអត្ថបទដែលបានបញ្ជាក់ថា តើ «ជនក្បត់» ទាំងនោះត្រូវបានចាប់ខ្លួន ឬក៏មិនទាន់ចាប់ ។ មិនតែប៉ុណ្ណោះ ចម្លើយសារភាពមួយចំនួនទំនងជាយ៉ាងហោចណាស់ត្រូវបានផ្ញើរួចហើយទៅឲ្យបុគ្គលជាក់លាក់ ដើម្បីបញ្ជាក់ជូនថាអ្នកណាដែលគួរចាប់ខ្លួននិងបញ្ជូនទៅមន្ទីរស-២១ ឬក៏ចាត់ការទៅតាមវិធានការដែលត្រូវបានប្រើប្រាស់ប្រឆាំងនឹង «ជនក្បត់» ។

### នួន ជា

ចំពោះ នួន ជា «ចម្លើយសារភាព»ចុះខែតុលា ឆ្នាំ១៩៧៧ របស់កម្មាភិបាលវរសេនាតូច១៧៤ នៃកងពលធំ ភូមិភាគកណ្តាល ឈ្មោះ ញៀម ស៊ឹម ហៅ សូត្រ ដែលត្រូវបានចារផ្ញើជូនទៅ

លេខាធិការបក្សរង្វមមានចំណារមួយពីអ្នកសួរចម្លើយមិត្ត សូត្រ ដែលពន្យល់ថា «**ទាល់តែខ្ញុំធ្វើទារុណកម្មវាទើបវាសារភាពរឿងដែលបានធ្វើជាអ្នកឲ្យព័ត៌មានដល់ប៉ូលិស និងសេ.អ៊ី.អា ជាខ្មែរសង្កាត់រហូតដល់ពេលចាប់ខ្លួន**» ។ «ចម្លើយសារភាព» ដែលចុះកាលបរិច្ឆេទក្នុងខែដដែលរបស់អ្នកទោស សៀង ប៉ូយ ហៅ សៀន ដែលជាយុទ្ធជននៅបាក់ព្រា ស្រុកដូនទ្រី និងបណ្តាស្រុកដទៃទៀតនៃតំបន់៤ ភូមិភាគឦសានរួមមាននូវចំណាររបស់អ្នកសួរចម្លើយប្រហាក់ប្រហែលគ្នានេះដែរចម្លើយសារភាពនេះពន្យល់ប្រាប់ថាដំបូងអ្នកទោស «មិនសារភាព» ប៉ុន្តែនៅពេលដែលអ្នកសួរចម្លើយរូបនោះចាប់ផ្តើមធ្វើទារុណកម្ម អ្នកទោសក៏សុខចិត្តឆ្លើយសារភាពអំពីការទាក់ទងជាខ្មែរសង្កាត់សកម្មភាពនិងផែនការនានារហូតមកទល់ពេលអង្គការចាប់ខ្លួន ។ ចម្លើយសារភាពរបស់ សៀន បានចង្អុលបង្ហាញថា នួន ជា បានដឹងពីការប្រហារជីវិតដែលនាំឲ្យ នួន ជា មានពិរុទ្ធភាព ។ ក្នុងការនិយាយសំដៅទៅលើកងទ័ពរបបសាធារណរដ្ឋខ្មែរ ចំណាររបស់អ្នកសួរចម្លើយបានសង្ខេបអំពីផ្នែកនានានៃចម្លើយសារភាពរបស់ សៀន ថា «កាលពីដើមឆ្នាំ១៩៧៦ សេចក្តីណែនាំរបស់អង្គការគឺបោសសម្អាតពួកបណ្តាសក្តិទាំងអស់នៅស្រុកបាក់ព្រា ដើម្បីកម្ទេចពួកនេះចោល» ។ មិនតែប៉ុណ្ណោះចំណារនោះក៏បាននិយាយដែរថាកាលពីខែកុម្ភៈ ឆ្នាំ១៩៧៧ សៀន ត្រូវបានចាត់តាំងឲ្យ «ដឹកនាំទ័ពទៅបោសសម្អាតមន្ត្រីបណ្តាសក្តិទាំងអស់នោះនៅពេលនោះគឺនៅក្នុងស្រុកដូនទ្រី» ។ ដោយយោងតាមចំណារនេះទ័ពខ្មែរក្រហមបានចាប់ «មន្ត្រីបណ្តាសក្តិជាច្រើន..ហើយបានកម្ទេចមន្ត្រីទាំងនោះចោល» ។ អត្ថបទចម្លើយសារភាពផ្នែកសំខាន់ដែលអ្នកសួរចម្លើយផ្តល់កំណត់ហេតុយ៉ាងពេញលេញអំពី «ចម្លើយសារភាព» ផ្តល់នូវព័ត៌មានលម្អិតនៃកិច្ចប្រតិបត្តិការទាំងពីរខាងលើ ។ អត្ថបទនោះបានកំណត់អត្តសញ្ញាណអង្គភាពដែលពាក់ព័ន្ធក្នុងយុទ្ធនាការដើមឆ្នាំ១៩៧៦ ថាជាអនុសេនាធំលេខ៤៥៣ នៃតំបន់៤ ហើយអត្ថបទនោះនិយាយថាកងពលតូចនេះត្រូវបានចាត់តាំងឲ្យ «ដឹកនាំទ័ពទៅបោសសម្អាតមន្ត្រីបណ្តាសក្តិនៅក្នុងស្រុកខ្ទបហៅបាក់ព្រា (លេខ៤១) ក្នុងតំបន់៤» ។ ដោយយោងតាម «ចម្លើយសារភាព» ទាំងនោះ យុទ្ធនាការបោសសម្អាតខែកុម្ភៈ ឆ្នាំ១៩៧៧ បានប្រើ «ទ័ពមួយអនុសេនាតូចឲ្យបោសសម្អាតសត្រូវនៅក្នុងស្រុកដូនទ្រី ដោយអនុលោមទៅតាមផែនការរបស់អង្គការ» ។ ការកម្ទេចក៏ត្រូវបាននិយាយជាបន្ថែមទៀតនៅក្នុង «ចម្លើយសារភាព» របស់ គង់ គាន ហៅ អ៊ឹង វេត លេខាវរសេនាតូចក្នុងកងពលធំលេខ១៦៤ របស់គណៈកម្មាធិការមជ្ឈិមដែលមានចំណារមួយនិយាយថា ផ្ញើជូន នួន ជា «ផ្ទាល់» ។ «ចម្លើយសារភាព» ទាំងនេះមានសេចក្តីអត្ថាធិប្បាយបន្ថែមដោយអក្សរដៃរបស់ ឌុច ។ ចម្លើយសារភាពមួយពន្យល់ថា «យើងបានកម្ទេច» ឈ្មោះ អឿន ហៅ សុផល ។ ចំណារមួយទៀតនិយាយថា «ដោយយោងទៅតាមព័ត៌មានរបស់ខ្ញុំ» មនុស្សម្នាក់ដែល



នួន ជា

ត្រូវបានហៅថា «អា តាន់ ម៉េង» ត្រូវបានកម្ទេច «ក្នុងឆ្នាំ ១៩៧៨» ។ សេចក្តីអត្ថាធិប្បាយទីពីររបស់ ឌុច បន្ថែមថា «មូលដ្ឋានបានកម្ទេច» ឈ្មោះ សំ ។

អត្ថបទចម្លើយសារភាពផ្នែកសំខាន់នៃ«ចម្លើយសារភាព» ទាំងនេះរួមបញ្ចូលបន្ថែមនូវការពិពណ៌នាអំពីការសន្ទនាកាលពីខែ មិថុនា ឆ្នាំ១៩៧៧ រវាងលេខាវរសេនាតូចនៃកងពលលេខ ១៦៤ និងលេខាវរសេនាតូចវៀតណាម ។ ក្នុងកិច្ចសន្ទនានោះ លេខាវរសេនាតូចមួយទៀតបានប្រកាសថា÷

***ឥឡូវនេះយើងធ្វើមិនបានទេមូលហេតុបែកគ្នា ដូច្នេះហើយទើបយើងធ្វើមិនបាន តែក្នុងនេះក៏យើងមិនឈប់ទេខែណាឆ្នាំណា យើងធ្វើបានគឺត្រូវតែធ្វើ ។ ដូច្នេះយើងត្រូវតែបន្តសកម្មភាពរបស់យើងតាមរូបភាពជាក់ស្តែងនិងស្របច្បាប់ដើម្បីកុំឲ្យដំណើរការបដិវត្តន៍លឿន ទម្រាំសភាពការណ៍អនុគ្រោះឲ្យយើងបាន ។ ហេតុនេះស្នើកុំឲ្យបែកការណ៍ ដឹងតែគ្នាយើងបានហើយគឺយើងធ្វើជាសភាពធម្មតា ។***

នៅទីបញ្ចប់អ៊ីៗទាំងអស់នៃ «ចម្លើយសារភាព» ខាងលើបាននិយាយអំពីការចាប់ខ្លួនជាច្រើនហើយផ្តល់ឈ្មោះ «ជនក្បត់» «បណ្តាញសេ.អ៊ី.អា» និងអ្នកដែលពេញចិត្តដែលនៅមានទំហំយ៉ាងធំហើយហៀបនឹងត្រូវចាប់ខ្លួន ឬយ៉ាងហោចណាស់អាចគ្រោះថ្នាក់ដល់ការចាប់ខ្លួន ។ តាមធម្មតាឈ្មោះអ្នកទាំងឡាយដែលជាប់ពាក់ព័ន្ធត្រូវបានវាយគ្រូសៗពេញអត្ថបទសំខាន់ៗនៃ «ចម្លើយសារភាព» ហើយបន្ទាប់មកសរុបបញ្ជីឈ្មោះខ្សែក្បត់ ឬខ្សែបណ្តាញបន្ថែមនៅខាងមុខ ឬខាងក្រោយនៃអត្ថបទនេះ ។ «ចម្លើយសារភាព» របស់ សៀន មានសេចក្តីបន្ថែមមានចំណងជើងថា «តារាងឈ្មោះជនក្បត់នៅក្នុងប្រវត្តិរូបរបស់ សៀង ប៉ូយ ហៅ សៀន» ។ បញ្ជីនោះរួមមានឈ្មោះមនុស្ស ១២នាក់ដែលចារថាបានចាប់ខ្លួនហើយ និង២៩នាក់ទៀតដែល សៀន បានផ្តល់ឈ្មោះថាជា «ជនក្បត់» ក៏ប៉ុន្តែទំនងជាពុំទាន់ចាប់ខ្លួនទេ ។ «ចម្លើយសារភាព» របស់ ញៀម ស៊ុម ហៅ សូត្រ រួមមានសេចក្តីបន្ថែមដែលមានចំណងជើងថា «តារាងជនក្បត់ដែលមានឈ្មោះនៅក្នុងប្រវត្តិរូប» ដែលចុះបញ្ជីឈ្មោះមនុស្ស៨នាក់ថាបានចាប់ខ្លួនរួចហើយ ហើយផ្តល់ឈ្មោះ «ជនក្បត់» ១៩នាក់ទៀតថាពុំទាន់បានចាប់ខ្លួននៅឡើយ ។

ឯកសារមួយទៀតដែលផ្ញើជូនទៅឲ្យ នួន ជា ទំនងជាមានព័ត៌មានអំពីការចាប់ខ្លួនមិនត្រឹមតែសម្រាប់ស្រាវជ្រាវយកព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែតម្រូវឲ្យមាន «វិធានការ» ។ ការចាប់ខ្លួនទាំងនេះមាននិយាយក្នុង «ចម្លើយសារភាព» របស់ ខែក ប៊ិន ហៅ ស៊ូ អតីតកម្មាភិបាលតំបន់ភូមិភាគឧត្តរដែលត្រូវបានចាត់តាំងឲ្យដឹកនាំគណៈកម្មាធិការទំនាក់ទំនងបញ្ហាព្រំដែនកម្ពុជា-ថៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការចាប់ខ្លួនទាំងនោះក៏មានចំណារមួយទំនងជាចារទៅឲ្យ នួន ជា ដែរនិយាយថា÷

***បងជាទីគោរព***

***១) ចម្លើយទាំងនេះពាក់ព័ន្ធមិត្ត ឃ្លាំង វេន ខូយ គូ មួនជាដើម ។ល ។ ទន្ទឹមនឹងនោះចម្លើយទាំងនោះពាក់ព័ន្ធនឹងគ្រឿន ។***

***២) បញ្ជីឈ្មោះនៅចុងបញ្ចប់សរុបអ្នកដែលពាក់ព័ន្ធនឹងឈ្មោះនេះជាជនក្បត់ ។***

សេចក្តីបន្ថែមដែលមានចំណងជើងថា «ខ្ញុំសូមរាយការណ៍ជូនអង្គការអំពីសេ.អ៊ី.អាដែលបានចូលរួមក្នុងសកម្មភាពក្បត់របស់ខ្ញុំ» រួមមានឈ្មោះមនុស្សចំនួន១៦នាក់ ដែលត្រូវបានកត់សម្គាល់ដោយចំណារសរសេរដៃថាត្រូវបាន «ចាប់ខ្លួនរួចហើយ» ។ ឈ្មោះមួយចំនួនទៀតមានចំណារដែរថា «មិនទាន់ចាប់» ប៉ុន្តែខ្លះទៀតមានសញ្ញាសួរ សម្គាល់ឈ្មោះទាំងនោះទៀតផង ។ ***(នៅមានត)*** **ស៊ីវ ហេង៉រ**

## ពាក្យស្លោកខ្មែរក្រហម

◆ **បង្កើនកម្លាំងចិត្ត កម្លាំងកាយ កម្លាំងបញ្ញាទាំងអស់របស់បុគ្គល របស់អង្គភាព និងរបស់ជាតិទាំងមូល សាមគ្គីជាធ្លុងមួយ តស៊ូកម្ចាត់ខ្មាំងគ្រប់ប្រភេទ ពិសេសខ្មាំងយួនឈ្លានពានលើទឹកដី រក្សាការពារជាតិ និងពូជសាសន៍កម្ពុជា ឱ្យគង់វង្សទាំងស្រុងជារៀងរហូត!**

◆ **អ្វីៗដែលប៉ះពាល់ដល់ជាតិ ប្រជាជនបដិវត្តន៍ និងបក្ស មិនត្រូវគិត ឬមិនត្រូវធ្វើឱ្យសោះ។**

◆ **កម្ចាត់ជាច់ខាតភ្នាក់ងារសេ.អ៊ី.អាឱ្យអស់ពីអង្គភាព និងពីទឹកដីកម្ពុជាជារៀងរហូត។**

*(ដកស្រង់ចេញពីសៀវភៅខ្មែរក្រហម លេខ០៧៦កណហ)*

# ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦៖

## តើអាចយកមកប្រើប្រាស់តាមនីតិវិធីបែបណាមកធ្វើការវិនិច្ឆ័យទោសរបបកម្ពុជាប្រជាធិបតេយ្យ?

### (ដំណកស្រង់មាត្រាសំខាន់ៗមួយចំនួន)










ដោយឈរលើគោលការណ៍ «គ្មានច្បាប់ គ្មានបទឧក្រិដ្ឋ» មានន័យថា «ច្បាប់ព្រហ្មទណ្ឌគ្មានអនុភាពជាប្រតិសកម្មទេ គឺថាបទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះនឹងមិនអាចត្រូវផ្តន្ទាតាមទោសរបស់ច្បាប់ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ» ។ ច្បាប់ព្រហ្មទណ្ឌកម្ពុជាមុនឆ្នាំ១៩៧៥ នឹងជាប្រភពច្បាប់ដើមដែលពាក់ព័ន្ធនឹងបទល្មើសដែលបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះគឺក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

ឧក្រិដ្ឋកម្មកម្រិតធ្ងន់មួយចំនួនដែលបានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ស្ថិតនៅតែជាបទឧក្រិដ្ឋក្រោមច្បាប់នេះដដែល ទោះបីជានៅក្នុងសម័យកាលនៃរបបជាបន្តបន្ទាប់មកទៀត ដូចជារបបសង្គមរាស្ត្រនិយម របបសាធារណរដ្ឋខ្មែរ និងរបបខ្មែរក្រហម ។ ពុំមានភ័ស្តុតាងដែលអះអាងថា របបកម្ពុជាប្រជាធិបតេយ្យបានលុបចោល ឬប្រកាសមិនទទួលស្គាល់នូវក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ដែលបានចូលជាធរមានជាស្រេចនៅពេលដែលរបបនេះបានឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ នោះទេ ។

ថ្វីបើរបបកម្ពុជាប្រជាធិបតេយ្យមានបំណងយ៉ាងច្បាស់ដើម្បីបង្កើតការចាប់ផ្តើមថ្មីមួយគឺ «ឆ្នាំសូន្យ» នៅកម្ពុជាក៏ដោយ ក៏យើងពុំអាចសន្និដ្ឋានដោយគ្មានភ័ស្តុតាងថា របបនេះបានលុបចោលនូវឧក្រិដ្ឋភាពនៃអំពើរំលោភជាក់ស្តែងដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មដោយប្រទេសនានាស្ទើរតែទាំងអស់នេះបានឡើយ ។

ជាងនេះទៅទៀត សូម្បីតែការបដិសេធចោលយ៉ាងច្បាស់ណាមួយក៏នឹងមិនអាចជួយអំពើខ្មែរក្រហមឲ្យរួចផុតពីទោសឧក្រិដ្ឋក្រោមច្បាប់កម្ពុជានៃរបបមុនៗបានឡើយ ។ ទោះជាខ្មែរក្រហមព្យាយាមទាញនូវការបដិសេធមិនទទួលស្គាល់ច្បាប់ ដែលនៅជាធរមានមុនរបបរបស់ខ្លួនក្នុងគោលបំណងដើម្បីកែតម្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិជាសារវន្តយ៉ាងណាក៏ដោយ ក៏ពុំអាចការពារអំពើរបស់ខ្លួនឲ្យរួចផុតពីពិរុទ្ធភាពបានឡើយ ។

ការប៉ុនប៉ងលុបចោលទាំងស្រុងនូវច្បាប់មុនៗ ដោយរបបកម្ពុជាប្រជាធិបតេយ្យ អាចបន្ធូរទោសកំហុសរបស់សមាជិកនៃរបបនេះដែលមានឋានៈតូចទាប ឬមិនគ្រប់អាយុដែលមិនអាចបានដឹងស្ថានភាពច្បាប់មុនៗ ឬក៏ពុំយល់ដឹង

អំពីភាពខុសច្បាប់នៃអំពើរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦បាន បង្ហាញនូវឧក្រិដ្ឋកម្មសំខាន់ៗដែលទទួលស្គាល់ដោយប្រទេសភាគច្រើនទូទាំងសកលលោក ។ យោងទៅលើការអនុវត្តតាមច្បាប់បារាំង ក្រមព្រហ្មទណ្ឌនេះបានចែងដោយផ្អែកដូចខាងក្រោមនេះ÷

**មាត្រា២១៖ ទោសឧក្រិដ្ឋមានបីយ៉ាង÷**

១) សម្លាប់

២) ដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត

៣) ដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់កាល ។

ទោសសម្លាប់ជាទោសឧក្រិដ្ឋថ្នាក់ទីបី ។ បទឧក្រិដ្ឋណាត្រូវផ្តន្ទាដោយសម្លាប់ បទឧក្រិដ្ឋនោះជាបទឧក្រិដ្ឋថ្នាក់ទីបី ។

ទោសដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិតជាទោសឧក្រិដ្ឋថ្នាក់ទីពីរ ។ បទឧក្រិដ្ឋណាត្រូវផ្តន្ទាទោសដោយដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត បទឧក្រិដ្ឋនោះជាបទឧក្រិដ្ឋថ្នាក់ទីពីរ ។

ទោសដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់ជាទោសឧក្រិដ្ឋថ្នាក់ទីមួយ ។ បទឧក្រិដ្ឋណាត្រូវផ្តន្ទាដោយដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់ជាបទឧក្រិដ្ឋថ្នាក់ទីមួយ ។

**មាត្រា២២៖ ទោសមជ្ឈិមមានពីរយ៉ាងគឺ÷**

១) ទោសគុក

២) ទោសពិន័យ ។

បណ្តាទោសទាំងពីរយ៉ាងនេះទោសម្យ៉ាងៗមានថ្នាក់បីៗ គឺថ្នាក់ទីបី ថ្នាក់ទីពីរ










និងថ្នាក់ទីមួយ ។

**ទោសមជ្ឈិមថ្នាក់ទីបី៖**

ក) ដាក់គុកពីមួយឆ្នាំទៅប្រាំឆ្នាំ

ខ) ពិន័យ (ជាប្រាក់)

**ទោសមជ្ឈិមថ្នាក់ទីពីរ៖**

ក) ដាក់គុកពីមួយខែទៅមួយឆ្នាំ

ខ) ពិន័យ (ជាប្រាក់)

**ទោសមជ្ឈិមថ្នាក់ទីមួយ៖**

ក) ដាក់គុកពីប្រាំមួយថ្ងៃ ទៅមួយខែ

ខ) ពិន័យ (ជាប្រាក់)

បណ្តាទោសមជ្ឈិមទាំងបីថ្នាក់នេះ ចៅក្រមនឹងយកតែទោសគុក ឬតែទោសពិន័យទៅផ្តន្ទាក៏បាន ឬយកទាំងគុក ទាំងពិន័យទៅផ្តន្ទាក៏បាន ។

បទមជ្ឈិមណាត្រូវផ្តន្ទាដោយទោសមជ្ឈិមថ្នាក់ទីបី បទមជ្ឈិមនោះជាបទមជ្ឈិមថ្នាក់ទីបី ។

បទមជ្ឈិមណាត្រូវផ្តន្ទាដោយទោសមជ្ឈិមថ្នាក់ទីពីរ បទមជ្ឈិមនោះឈ្មោះថាបទមជ្ឈិមថ្នាក់ទីពីរ ។

បទមជ្ឈិមណាត្រូវផ្តន្ទាដោយទោសមជ្ឈិមថ្នាក់ទីមួយ បទមជ្ឈិមនោះឈ្មោះថាបទល្មើសមជ្ឈិមថ្នាក់ទីមួយ ។ មានសណ្ឋានជាច្រើនដែលតុលាការអាចបន្ថយឬបង្កើននូវទោសបញ្ញត្តិ អាស្រ័យទៅលើសភាពទម្ងន់នៃបទល្មើស ។ ទម្ងន់នៃបទល្មើសគឺពិនិត្យទៅលើវិធីនៃប្រព្រឹត្តកម្មស្ថានភាពជនរងគ្រោះហើយនិងប្រវត្តិឧក្រិដ្ឋរបស់ជនល្មើស ។

**មាត្រា៥០១៖** ជនណាសម្លាប់មនុស្ស ជននោះមានពិរុទ្ធជាបានប្រព្រឹត្តបទមនុស្សឃាត ។បើមនុស្សនោះស្លាប់

បណ្តាលមកពីអំពើឥតចេតនាទេអំពើនោះ ឈ្មោះថាមនុស្សឃាតដោយអចេតនា ។

បើមនុស្សនោះស្លាប់បណ្តាលមកពីអំពើប្រកបដោយចេតនាចង់សម្លាប់មែននោះអំពើនោះឈ្មោះថាមនុស្សឃាតដោយចេតនា ។

**មាត្រា៥០០៖** ជនណាធ្វើទារុណកម្មអ្នកដទៃដើម្បីឲ្យអ្នកនោះឈឺជាខ្លាំង ហើយធ្លាយប្រាប់ពត៌មានផ្សេងៗដែលមានប្រយោជន៍ដល់ការប្រព្រឹត្តខក្រិដ្ឋកម្ម ឬមជ្ឈិមកម្មណាមួយក្តី ដើម្បីសងសឹកឬដោយអំពើចិត្តព្រៃផ្សៃរបស់ខ្លួនក្តី ជននោះត្រូវមានទោសខក្រិដ្ឋថ្នាក់ទីបី ។

**មាត្រា៥០៥៖** ចៅក្រមអាចសន្និដ្ឋានថា ឃាតករមានវឌកចិត្តបាន កាលបើឃាតករមានអាវុធ កាលណាបើឃាតករប្រហារយ៉ាងពេញទំហឹង កាលណាបើមានរបួសរសាំច្រើនកន្លែងលើខ្លួនខ្មោច កាលណាបើឃើញថាឃាតករកាលប្រហារបានរើសរកតែកន្លែងដំណាំនៅលើខ្លួនអ្នកស្លាប់ គួរឲ្យដល់នូវសេចក្តីស្លាប់មែន ។

**មាត្រា៤៤៣៖** ជនណាបញ្ចូល ឬប៉ុននឹងបញ្ចូលទាំងបង្ខំ ឬទាំងគំរាមនូវអង្គជាតិរបស់ខ្លួនទៅក្នុងអង្គជាតិនៃស្ត្រីដែលប្រកែកមិនព្រមស្ម័គ្រផង ជននោះត្រូវទុកជាមានពិរុទ្ធក្នុងបទកំហែងរួមបវេណីដល់ទីជម្រៅ ។

បើស្ត្រីរងគ្រោះមានអាយុតិចជាងដប់បីឆ្នាំ ពិរុទ្ធជនត្រូវមានទោសខក្រិដ្ឋថ្នាក់ទីមួយ ។

បើស្ត្រីរងគ្រោះមានអាយុច្រើន










ជាងដប់បីឆ្នាំពិរុទ្ធជនត្រូវមានទោសមជ្ឈិមថ្នាក់ទីបី ។

**មាត្រា៤៩៥៖** វិហិង្សាធ្វើដោយចេតនាលើរូបអ្នកដទៃត្រូវផ្តន្ទាទោសឲ្យធ្ងន់ ឬឲ្យស្រាលរេទៅតាមទម្ងន់នៃកម្មវិបាកដែលធ្វើឲ្យខូចសុខភាពនៃអ្នករងគ្រោះនោះធ្ងន់ ឬស្រាល ហើយម្យ៉ាងវិញទៀតរេទៅតាមបទល្មើសដែលកាលប្រព្រឹត្តនោះមានប្រើអាវុធ ឬគ្មានប្រើអាវុធណាមួយទេ ។ ត្រូវទុកជាមានប្រើអាវុធគ្រាណាដែលវិហិង្សានោះបានប្រព្រឹត្តដោយប្រើវត្ថុអ្វីមួយសម្រាប់វាយ ឬសម្រាប់ធ្វើឲ្យសៅហ្មងដល់អ្នករងគ្រោះ ។

បំណងក្នុងបទនេះគឺត្រូវមានទោសដែរកាលណាបើវិហិង្សានោះបានប្រព្រឹត្តហើយតែអ្នករងអំពើបានចៀសផុតពីអំពើនោះ ។

**មាត្រា៤៨២៖** ជនណាគ្មានបានទទួលបង្គាប់ពីអាជ្ញាធរជាធម្មានុរូបនោះ និងក្រៅពីករណីនៃបទល្មើសមជ្ឈិម ឬខក្រិដ្ឋជាក់ស្តែងសោះ ហើយចាប់ឃុំនិងឃាត់ទុកនូវបុគ្គលណាម្នាក់ក្នុងរយៈវេលាមិនលើសពីដប់ថ្ងៃទេជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។ ក្នុងករណីផ្ទុយទៅវិញគឺបើលើសពីដប់ថ្ងៃឡើងទៅ ជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីបី ។

**មាត្រា២០៩៖** ការព្យាបាទដល់ជីវិតរបស់បព្វជិតក្នុងសាសនារបស់រដ្ឋនៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬនៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិ

**(តទៅទំព័រទី៥៧)**

# លក្ខខណ្ឌនៃភស្តុតាង



**(តពីលេខមុន)** **ការសាកសួរសាក្សី**

ភាគីនីមួយៗនៅក្នុងតុលាការអាចកោះហៅសាក្សីដើម្បីគាំទ្រអង្គហេតុដែលខ្លួនបានអះអាង ។ កសិណសាក្សីគឺជាប្រភពនៃភស្តុតាងមួយក្នុងចំណោមប្រភពភស្តុតាងដទៃទៀតជាច្រើន ។ ភស្តុតាងប្រភេទនេះ គឺអ្នកកាត់សេចក្តីលើអង្គហេតុពុំបានឃើញ ឬមានចំណាប់អារម្មណ៍ដោយផ្ទាល់ និងដំបូងបំផុតនៅពេលដែលហេតុការណ៍នោះបានកើតឡើង ។ ហេតុដូច្នេះអ្នកកាត់សេចក្តីលើអង្គហេតុពឹងផ្អែកជាសំខាន់ទៅលើកសិណសាក្សីនៃអ្នកដែលបានជួបប្រទះ ឬដឹងឮដំបូងគេបំផុត តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងពេលថ្មីនេះសាក្សីត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ការយល់ឃើញរបស់ខ្លួនធ្វើជាកសិណហើយអ្នកកាត់សេចក្តីអង្គហេតុត្រូវបានផ្តល់ការទុកចិត្តឲ្យមានឆន្ទានុសិទ្ធដើម្បីកំណត់ពីភាពខុសប្លែកគ្នារវាងអង្គហេតុ និងអ្វីដែលជាទស្សនៈយល់ឃើញរបស់សាក្សីដែលបានលើកឡើង ។

**១) ការសាកសួរសាក្សីរបស់ខ្លួន**

ភាគីដែលកោះហៅសាក្សីត្រូវធ្វើការសាកសួរដោយផ្ទាល់ចំពោះសាក្សីដែលខ្លួនហៅមក ។ គោលដៅនៃការសាកសួរសាក្សីរបស់ខ្លួនគឺដើម្បីគាំទ្រដល់អង្គហេតុនានាដែលមានសារៈសំខាន់ចំពោះការអះអាងរបស់ភាគីដែលបានហៅសាក្សីនោះមក ។ សំណួរនាំមុខមានន័យថាសំណួរដែល «បង្ហាញនូវចម្លើយ» ដែលហាក់ដូចជាបង្ខំឲ្យសាក្សីឲ្យផ្តល់ចម្លើយដែលចង់បាន ជាទូទៅត្រូវបានហាមឃាត់នៅក្នុងការសាកសួរសាក្សីរបស់ភាគីខ្លួន ។ ហេតុផលដែលនាំឲ្យមានច្បាប់ហាមដូច្នេះ គឺថាតុលាការភ័យខ្លាចថាសាក្សីដែលមានចរិតរួសរាយ នឹងឆ្លើយនូវអ្វីដែលអ្នកសួរចង់ឮ ដូច្នេះនឹងមិនផ្តល់នូវកសិណដែលផ្អែកលើមូលដ្ឋាននៃការដឹងឮផ្ទាល់ខ្លួនសុទ្ធសាធនោះឡើយ អ្នកសាកសួរសាក្សីនោះអាចបង្ហាញផ្លូវឲ្យឆ្លើយប៉ុន្តែអ្នកសួរត្រូវអនុញ្ញាតឲ្យសាក្សីផ្តល់នូវចម្លើយរបស់ខ្លួនផ្ទាល់ ។ ភាពជឿទុកចិត្តបានទៅលើសាក្សីគឺមានសារៈសំខាន់ណាស់ ហើយការស្តាប់នូវចម្លើយ ឬកសិណតាមពាក្យសម្តីរបស់សាក្សីនោះផ្ទាល់គឺមានសារៈសំខាន់ពាក់ព័ន្ធទៅនឹងរឿងក្តីយ៉ាងខ្លាំង ។

មានករណីលើកលែងចំពោះការហាមឃាត់មិនឲ្យប្រើសំណួរនាំមុខមានដូចខាងក្រោម៖

១) ប្រសិនបើសាក្សីមានអាកប្បកិរិយាពុំសូវរាក់ទាក់ពេលនោះសំណួរនាំមុខត្រូវបានអនុញ្ញាត ។

២) ប្រសិនបើសំណួរដែលសួរដើម្បីចង្អុលបង្ហាញនៅក្នុងអង្គហេតុដែលពុំទាក់ទងនៅក្នុងរឿងក្តីសំណួរនាំមុខត្រូវបានអនុញ្ញាតដើម្បីធ្វើឲ្យមានប្រសិទ្ធភាព ។

៣) ប្រសិនបើសាក្សីមានការភ្លេចភ្លាំងពេលនោះសំណួរនាំមុខអាចត្រូវបានអនុញ្ញាតឲ្យសួរពញ្ញាក់ការចងចាំរបស់សាក្សី ។

៤) នៅចុងក្រោយសំណួរនាំមុខអាចត្រូវបានឲ្យសួរ ប្រសិនបើសាក្សីនៅក្នុងសភាពអសមត្ថភាពលើបញ្ហាណាមួយដែលអាចធ្វើឲ្យសាក្សីនោះពុំមានលទ្ធភាពផ្តល់កសិណបាន (មានន័យថាសាក្សីក្នុងវ័យក្មេងពេក សាក្សីមិនអាចនិយាយភាសានោះបាន ល្ងង់ ឬអសមត្ថភាពផ្នែកបញ្ញា ឬមិនស្ទាហាប់) ។

សំណួរជាក់លាក់មួយចំនួនអាចត្រូវបានគេដេញដោល

ប្រឆាំងថាជាសំណួរនាំមុខ ។ ផ្ទុយទៅវិញសំណួរជាលក្ខណៈរៀបរាប់នឹងអនុញ្ញាតឲ្យសាក្សីរៀបរាប់ ប៉ុន្តែចម្លើយនោះអាចមានភស្តុតាងបុក៏សាក្សីនោះនិយាយបាំតណាបាំតណីមិនចំប្រធានបទ ។

## ២) ការសាកសួរសាក្សីដោយភាគីបដិបក្ខ

ពេលដែលភាគីដែលហៅសាក្សីបានបញ្ចប់ការសាកសួររបស់ខ្លួន ភាគីម្ខាងទៀតអាចសួរសាក្សីភាគីបដិបក្ខ ។ អាស្រ័យលើដែនសមត្ថកិច្ចនៃតុលាការ ការសាកសួរសាក្សីដោយភាគីបដិបក្ខអាចមានការកម្រិតទៅលើវិសាលភាពនៃតុលាការ ។នៅក្នុងដែនសមត្ថកិច្ចនៃតុលាការមួយចំនួនការសាកសួរដោយភាគីបដិបក្ខអាចកម្រិតចំពោះតែបញ្ហាណាដែលលេចចេញមកពីការសាកសួរសាក្សីដោយភាគីម្ខាងទៀតតែប៉ុណ្ណោះ ។ បញ្ហាដែលទាក់ទងនឹងភាពអាចជឿបានចំពោះសាក្សីអាចត្រូវបានអនុញ្ញាត ប្រសិនបើភាគីប្រឆាំងរិះរកសក្ខីកម្មដាក់ស្តែងក្នុងពេលសាកសួរភាគីបដិបក្ខ ។ វិធានជាទូទៅៈ កុំសួរនូវសំណួរដែលគ្មានចម្លើយជាគោលដៅ ។ អ្នកសួរគួរតែធានាឲ្យបានច្បាស់ថាសំណួរនោះនឹងផ្តល់ចម្លើយឲ្យបានជាទីពេញចិត្ត ។

## ៣) ការសាកសួរសាក្សីផ្ទាល់ខ្លួនឡើងវិញ

ភាគីដែលកោះហៅសាក្សីរបស់ខ្លួនមកសាកសួរមានឱកាសសាកសួរសាក្សីរបស់ខ្លួនឡើងវិញ ។ ការសាកសួរឡើងវិញជាទូទៅកម្រិតឲ្យផ្តោតចំពោះការឆ្លើយតប (បញ្ចេញយោបល់ប្រឆាំង) ចំពោះចំណុចណាដែលលើកឡើងពេលសាកសួរដោយភាគីបដិបក្ខ ។

## ៤) ការសាកសួរសាក្សីឡើងវិញដោយភាគីបដិបក្ខ

ភាគីបដិបក្ខពេលនោះអាចឆ្លើយតបចំពោះការសាកសួរសាក្សី តាមធម្មតាសាក្សីទាំងឡាយត្រូវទុកឲ្យនៅកន្លែងស្ងាត់មួយដាច់ដោយឡែក ។ នៅក្នុងកន្លែងស្ងាត់បែបនេះសាក្សីពុំអាចធ្វើការសង្កេតដឹងកសិណរបស់ភាគី ។ ធ្វើបែបនេះព្រោះគេភ័យខ្លាចថាសាក្សីទាំងនោះនឹងឆ្លើយតម្រូវនឹងកសិណរបស់សាក្សីដទៃទៀត ។

នៅក្នុងប្រព័ន្ធច្បាប់ទំនាស់ទូទៅ តុលាការពុំមានការទទួលខុសត្រូវក្នុងការបដិសេធកសិណសាក្សីដែលមិនអាចទទួលយកបានដោយតុលាការបានទេ ប៉ុន្តែមេធាវីខាងភាគីប្រឆាំងត្រូវឲ្យមានភារៈជំទាស់ទៅនឹងកសិណសាក្សី ដែលម្ខាងទៀតបានយកមកបង្ហាញនោះ ។ ប្រសិនបើការជំទាស់ពុំបានធ្វើឡើងភ្លាមៗនោះទេ (តាមធម្មតាមុនពេលសាក្សីឆ្លើយ) ការជំទាស់នោះត្រូវបានគេចាត់ទុកថាគ្មានប្រសិទ្ធភាពឡើយ ។ ម្យ៉ាងវិញទៀត ប្រសិនបើចម្លើយរបស់សាក្សីពុំអាចទទួលយកបាន មេធាវីខាងភាគីប្រឆាំងអាចត្រូវបាន



ជនរងគ្រោះដោយស្នាដៃពួកខ្មែរក្រហម

អនុញ្ញាតឲ្យឡើងប្រឆាំងសុំដកចេញនូវចម្លើយនោះពីសំណុំភស្តុតាង របស់តុលាការ ។

ការជំទាស់របស់មេធាវីភាគីប្រឆាំងអាចត្រូវបានទាត់ចោល ឬគាំទ្រ ។ ប្រសិនបើការជំទាស់នោះត្រូវបានគាំទ្រ មេធាវីម្ខាងទៀតត្រូវឡើងមកផ្តល់ភស្តុតាងដល់តុលាការដើម្បីបង្ហាញថា ហេតុអ្វីបានជាចម្លើយរបស់សាក្សីនៃភាគីខ្លួនមានការទាក់ទងនឹងរឿងក្តី ។ ការផ្តល់ភស្តុតាងនេះគឺទាក់ទងប្រសិនបើមេធាវីខាងប្រឆាំងធ្វើការអះអាងតវ៉ាដោយឈរលើមូលដ្ឋានថា កសិណសាក្សីនេះគួរតែយកមកពិចារណាក្នុងតុលាការ ។ មិនអាចយកពាក្យសម្តីនិយាយក្រៅតុលាការមកអះអាងដើម្បីបង្ហាញភស្តុតាងបញ្ជាក់ពីការពិតនៃអង្គហេតុណាមួយឡើយ ។ ប៉ុន្តែក៏ពុំមែនពាក្យសម្តីដែលនិយាយនៅក្រៅតុលាការទាំងអស់សុទ្ធតែមិនអាចយកធ្វើជាភស្តុតាងបាននោះទេ ។ ក្នុងនោះគឺសំដៅទៅលើសម្តីអះអាងទាំងឡាយដែលយកទៅតុលាការដើម្បីបង្ហាញថាការអះអាង ឬសេចក្តីអះអាងលើអង្គហេតុណាមួយគឺជាការពិតប៉ុណ្ណោះ ។ សូម្បីតែនៅក្នុងប្រព័ន្ធច្បាប់របស់អង់គ្លូអាមេរិកាំងដែលមិនទទួលយកពាក្យចចាមអារ៉ាមធ្វើជាភស្តុតាងក៏មានករណីលើកលែងជាច្រើននៅក្នុងច្បាប់នេះដែរ ។ ជាទូទៅ ពាក្យចចាមអារ៉ាម


សម្ភារផ្សេងៗ និងឧបករណ៍ធ្វើទារុណកម្ម

ប្រភេទភស្តុតាងកសិណសាក្សីពីរប្រភេទដែលធ្វើឲ្យមានការចាប់អារម្មណ៍ក្នុងការដាក់បញ្ចូលដើម្បីពិចារណា÷

១) ភស្តុតាងដែលមិនអាចសួរដេញដោលដោយភាគីបដិបក្ខ

២) ភស្តុតាងដែលពុំបានផ្តល់ដោយមានការស្បថសច្ចាប្រណិធាន ។

ភស្តុតាងពាក្យចចាមអារ៉ាមគឺជាសម្តីនិយាយក្រៅតុលាការដែលរៀបរាប់អំពីរូបរាងបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ឬអំពីការចាប់អារម្មណ៍លើអង្គហេតុ ឬព្រឹត្តិការណ៍នានា ។ ភស្តុតាងបែបនេះជាទូទៅត្រូវបានគេចាត់ទុកថាជាភស្តុតាងដែលត្រូវបានគេទាត់ចោល ។ ពាក្យចចាមអារ៉ាមមិនអាចទទួលយកភស្តុតាងបាន ពីព្រោះជនដែលនិយាយ (អ្នកប្រកាសអះអាង) គឺពុំមានវត្តមាននៅចំពោះមុខតុលាការដើម្បីឲ្យភាគីបដិបក្ខសួរដេញដោលឡើយ ហើយអ្នកនិយាយនោះក៏ពុំបានធ្វើសច្ចាប្រណិធានចំពោះមុខច្បាប់នៅពេលដែលនិយាយពាក្យសម្តីទាំងនោះដែរ ។ សាក្សីត្រូវបានទទួលយកប្រសិនបើពាក្យនោះឆ្លុះបញ្ចាំងការពិតដែលគេគ្រប់គ្នាបានដឹង (មានន័យថាជាការពិតដែលកើតឡើងហើយមាននៅក្នុងឯកសារសាធារណៈ) ឬប្រសិនបើបរិយាកាសជុំវិញពាក្យសម្តីនោះនាំឲ្យអ្នកវិនិច្ឆ័យអង្គហេតុជឿថាពាក្យសម្តីនោះកើតឡើងដោយឯកឯងគ្មានគេប្រឌិតអាចឲ្យជឿបានហើយពាក់ព័ន្ធរឿងក្តី។ ឧទាហរណ៍ ចំពោះករណីលើកលែងពាក្យសម្តីដែលនិយាយក្នុងសភាពអន្ទះសារអាចយកកសិណជាពាក្យចចាមអារ៉ាមនេះមកធ្វើជាភស្តុតាងបាន ប្រសិនបើអ្នកនិយាយនោះពិតជាក្នុងសភាព

អន្ទះសារមែន ហើយពុំមានមូលហេតុ ឬហេតុផលអ្វីដល់គេក្នុងការកុហកនោះ ។ ភ័ស្តុតាងដែលអាចយកមកដាក់បញ្ចូលក្រោមច្បាប់មិនទទួលយកជាភស្តុតាងនូវពាក្យចចាមអារ៉ាមនេះរួមបញ្ចូលភ័ស្តុតាងជាកាយវិការដែរ ។ ក្នុងប្រព័ន្ធច្បាប់នានាដែលមានក្រុមប្រឹក្សាគុលាការ ជារឿយៗមានការមន្ទិលសង្ស័យលើសមត្ថភាពរបស់ក្រុមប្រឹក្សាគុលាការក្នុងការបែងចែកឲ្យដាច់ស្រឡះ ថាតើមួយណាជាពាក្យចចាមអារ៉ាម និងមួយណាជាភ័ស្តុតាងដែលមានកសិណសាក្សីអះអាងបញ្ជាក់ ។ ការព្រួយបារម្ភមួយចំនួនកើតឡើងដោយទាក់ទងទៅនឹងលិខិតថ្លែងសម្បថនានា (សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរធ្វើឡើងដោយសច្ចាប្រណិធាន) វិធីយកសក្ខីកម្ម (សំណួរផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ) និងដោយភាគីម្ខាងទៀត ។ មានបញ្ហា៤ ដែលទាក់ទងទៅនឹងសម្តីនិយាយនៅក្រៅគុលាការៈ **១) ភាពមិនច្បាស់លាស់ ២) ការដឹងឮមិនត្រឹមត្រូវ ៣) ការចងចាំមិនបានល្អ និង ៤) ភាពមិនស្មោះត្រង់ ។ បញ្ហាទាំង៤ខាងលើនេះអាចបង្ហាញឲ្យឃើញច្បាស់ ប្រសិនបើអ្នកសួរចម្លើយជាភាគីប្រឆាំងអាចសួរសាក្សីនោះដោយផ្ទាល់ ។**

ចំពោះការសួរចម្លើយខ្វែង មេធាវីខាងជំទាស់មានបំណងសួរដេញដោលពីចម្លើយរបស់សាក្សីនោះ ។ ការសួរដេញដោលទាក់ទងដល់ការវាយប្រហារលើភាពជឿជាក់បានចំពោះសាក្សីនោះ ។ មានបច្ចេកទេសក្នុងការសួរដេញដោលចំនួន៥គឺ÷

១) បញ្ហាអត្តចរិតៈ មេធាវីខាងភាគីប្រឆាំងអាចព្យាយាមដើម្បីបង្ហាញថាសាក្សីដែលភាគីម្ខាងទៀតហៅមកពុំស្មោះត្រង់ ដោយបង្ហាញថាសាក្សីនោះធ្លាប់បានជាប់ទោសពីបទប្រព្រឹត្តអំពើឧក្រិដ្ឋ (ជាពិសេសទាក់ទងទៅនឹងបទរំលោភបំពានសេចក្តីទុកចិត្ត) ដែលប្រព្រឹត្តមុនពេលបានប្រព្រឹត្តនូវអំពើអាក្រក់ផ្សេងៗទៀត (ដូចជាការយកលុយពីប្រធានរបស់ខ្លួន ការគេចពន្ធ) ឬថាសាក្សីនោះមានកេរ្តិ៍ឈ្មោះមិនល្អជាដើម ។ល ។

២) ចម្លើយគ្មានភាពស៊ីគ្នាទៅនឹងចម្លើយលើកមុន កាលពីមុនសាក្សីបានផ្តល់ចម្លើយមួយដែលវាមិនស៊ីគ្នាទៅនឹងចម្លើយ ឬកសិណសាក្សីដែលខ្លួនបានធ្វើលើកនេះ ។(ឧទាហរណ៍តាមរយៈការតម្កល់ទុកនូវចម្លើយសាក្សីបានមកពីការសម្ភាសមុនពេលកាត់ក្តី) ប្រការនេះអាចកើតឡើងតាមពីររបៀបៈ ភ័ស្តុតាងនៃចម្លើយគ្មានភាពស៊ីគ្នានឹងចម្លើយពីលើកមុនអាចបង្កើតឲ្យមានការសង្ស័យដោយផ្ទាល់លើភាពត្រឹមត្រូវនៃចម្លើយលើកនេះ ហើយបង្ហាញថាសាក្សីអាចផ្តល់ចម្លើយភូតកុហកទៀតផង ។

៣) ភាពលម្អៀងៈ សាក្សីលម្អៀងទៅលើ ឬប្រឆាំងភាគីម្ខាងដោយឈរលើមូលដ្ឋានថា ភាគីម្ខាងជាគ្រួសារ ទំនាក់ទំនងផ្ទាល់ខ្លួនផ្សេងៗ ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ភាពប្រទូស្តរាយក្នុងអតីតកាល ចំពោះភាគីម្ខាងទៀត ឬដោយផ្អែកលើមូលហេតុផ្សេងទៀត ។

៤) ពិការភាពផ្នែកវិញ្ញាណ និងភាពខុះចន្លោះដែលទាក់ទងៈ សាក្សីមិនអាចស្តាប់ឮនូវអ្វីដែលខ្លួនអះអាងថាបានស្តាប់ឮ ឬប្រសិនបើការពិពណ៌នាអំពីព្រឹត្តិការណ៍ណាមួយដែលមិនអាចជឿបានដោយសារការខូចត្រចៀកស្តាប់មិនឮ ។

៥) ការជំទាស់ៈ ការផ្តល់ភ័ស្តុតាង ឬកសិណសាក្សីដែលបង្ហាញថាចម្លើយដែលសាក្សីទី១បានលើកឡើងគឺមិនត្រឹមត្រូវ ។ តាមធម្មតាការជំទាស់នេះអនុញ្ញាតទៅបានទាល់តែមានភ័ស្តុតាងសំខាន់ដើម្បីប្រឆាំងទៅនឹងបញ្ហាមិនទាក់ទងក្នុងរឿងក្តី ។

សាក្សីជំនាញគឺជាមនុស្សដែលមានចំណេះដឹងជំនាញ ហើយដែលជួយដោះស្រាយរឿងក្តីស្មុគស្មាញមួយ ។ តាមធម្មតាសាក្សីជំនាញធ្វើកសិណនៅពេលណាដែលមានរឿងក្តីស្មុគស្មាញ ហើយតម្រូវឲ្យមានការជួយបកស្រាយពីអ្នកជំនាញ ។ តាមធម្មតាគេមិនហៅអ្នកជំនាញមកធ្វើការវាយតម្លៃភ័ស្តុតាងសាមញ្ញៗនោះទេ ។ សាក្សីជំនាញអាចជួយផ្តល់យោបល់ទាំងឡាយដែលអាចទាញចេញពីអង្គហេតុមួយចំនួនដែលលំបាកសម្រេច ។ មានតម្រូវការចាំបាច់ពីរដែលត្រូវឆ្លើយតបមុនពេលទទួលយកកសិណរបស់អ្នកជំនាញ ។

១) អ្នកជំនាញត្រូវតែមានបុគ្គលិកលក្ខណៈគ្រប់គ្រាន់ជាអ្នកជំនាញក្នុងផ្នែកនេះ ។ គេអាចធ្វើការសាកល្បងដោយឲ្យសាក្សីឆ្លើយនូវសំណួរទាំងឡាយអំពីការសិក្សាទំនាក់ទំនងសាធារណៈ ឬមុខជំនាញរបស់សាក្សីជាដើម ។ល ។

២) កសិណសាក្សីត្រូវមានជំនាញច្បាស់ពីប្រធានបទដែលទាក់ទងទៅនឹងរឿងក្តី ។

**អេលីហ្សាប៊ែត ខាន់ស្តាក់**

អត្ថបទដោយ ឆាំង សុខ សមាជិកព្រឹទ្ធសភាជាតិ



# វត្ថុអស្ចារ្យពីរប្រភេទ

«ទួលស្លែង» ជាអគារបីជាន់ធ្វើអំពីឥដ្ឋ–ស៊ីម៉ង់ត៍នៃអតីតវិទ្យាល័យទួលស្វាយព្រៃ ក្រុងភ្នំពេញ ។ ប៉ុល ពត បានប្រើអគារទួលស្លែងនេះធ្វើជាពន្ធនាគារ ឃុំឃាំង ធ្វើទារុណកម្មយកចម្លើយ និងសម្លាប់ខ្មែរអស់ប្រហែលពីរម៉ឺននាក់ ។ ក្រោយបរាជ័យប៉ុលពតក្នុងឆ្នាំ១៩៧៩មក ទួលស្លែងត្រូវបានរក្សាទុកជាសារមន្ទីរតម្កល់វត្ថុតាងទាំងឡាយនៃការកាប់សម្លាប់ប្រល័យពូជសាសន៍នៅកម្ពុជា ។

សព្វថ្ងៃនេះ ទួលស្លែងបានធ្វើឲ្យមហាជនទូទាំងសកលលោក



ទទួលដឹងឮយ៉ាងរន្ធត់តក់ស្លុតនូវការកាប់សម្លាប់ខ្មែរដែលមានទំហំធំជាងការកាប់សម្លាប់បំផុតពូជពួកជ្វីហ្វចំនួន៦លាននាក់ ដោយ ហ៊ីត្ល័រ នៅក្នុងសង្គ្រាមលោកលើកទីពីរទៅទៀត ។

ប៉ុន្តែខ្មែរយើងមួយចំនួនបែរជាមានគម្រោងការជុតឆ្អឹងជនរងគ្រោះនៅទួលស្លែងទាំងអស់នេះបូជាធ្វើបុណ្យទៅវិញ ។ ការបូជាធ្វើបុណ្យនូវអដ្ឋិធាតុជាវត្ថុតាងនៃអំពើអមនុស្សធម៌ដ៏ធំធេងឥតអៀនខ្មាសដែល ប៉ុល ពត បានប្រព្រឹត្តមកលើជាតិខ្មែរគ្នាឯងនៅពេលដែលខ្លួនបានកាន់អំណាចមានន័យគួរឲ្យតក់ស្លុត

ព្រឹឆ្អឹងខ្នង មិនខុសគ្នាពីការគាស់រំលាយប្រាសាទអង្គរវត្តដែលជាតំណាងអរិយធម៌ខ្មែរចោលឡើយ ។

នៅពេលដែលខ្មែរបានឡើងដល់កំពូលឥទ្ធិពលនៅក្នុងអាស៊ី-អគ្នេយ៍ពីសតវត្សរ៍ទី៧ ដល់សតវត្សរ៍ទី១៣ ខ្មែរបានកសាងប្រាសាទក្រុមអង្គរវត្តមួយចំនួន ។ នៅពេលដែលខ្មែររអិលធ្លាក់កប់ដល់បាតអវិជ្ជាព្រៃផ្សៃដែលពន្លឺអរិយធម៌ចាំងមិនដល់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរបានកាប់សម្លាប់គ្នាឯងចោលអស់បីលាននាក់ ។ តំណាងវាលពិឃាតមួយនៅទួលស្លែងក៏បានកសាងឡើង ។ វត្ថុទាំងពីរនេះសុទ្ធសឹងជា «វត្ថុអស្ចារ្យ» ដែលបញ្ញាមនុស្សធម្មតាពុំអាចគិតស្មានថាកើតមានបាន ។

ប្រាសាទអង្គរវត្តបានធ្វើឲ្យពិភពលោកកោតស្ញប់ស្ញែងសរសើរដល់ទេពកោសល្យនៃការកសាងរបស់ខ្មែរ ឯទួលស្លែងវិញក៏បានធ្វើឲ្យពិភពលោកដដែលនេះតក់ស្លុតខ្ញើមរអើមដល់ថ្លើមខ្មៅងងឹតរបស់ខ្មែរដែលមានពូជជាអ្នកកសាងប្រាសាទអង្គរវត្តដដែល ។ វត្ថុទាំងពីរបានក្លាយទៅជាសម្បត្តិវប្បធម៌របស់មនុស្សលោកទាំងមូល ។ ខ្មែរដែលជាអ្នកផ្ដើមកសាង ឥឡូវគ្រាន់តែមានភារកិច្ចយ៉ាងធ្ងន់ធ្ងរជាអ្នកអភិរក្សវត្ថុអស្ចារ្យទាំងពីរទុកជាកេរដំណែលជូនមនុស្សលោកប្រើប្រាស់ជាឧបករណ៍សម្រាប់ត្រិះរិះតទៅ ។

ពិតមែនតែវត្ថុអស្ចារ្យទាំងពីរមានបាតុភាពក្រៅផ្ទុយខុសគ្នាស្រឡះដូចនរកនិងឋានសួគ៌យ៉ាងណាក៏ដោយ ក៏ «ការកសាង» ឲ្យមានឡើងនូវវត្ថុទាំងពីរតម្រូវឲ្យមានយុទ្ធវិធីកម្រោងការផ្លូវចិត្ត ផ្លូវប្រាជ្ញា ផ្លូវកាយ ផ្លូវធនធានសេដ្ឋកិច្ច និងផ្លូវរដ្ឋបាលយ៉ាងល្អិតល្អន់វិសេសវិសាល ដើម្បីចាំបាច់មនុស្សរាប់លាននាក់ដែលមានឧត្ដមគតិផ្សេងៗគ្នាឲ្យជឿឈ្លក់ទៅក្នុងជំនឿតែមួយឥតមានងាករេចេញបាន ។

នៅក្នុងប្រទេសកម្ពុជា មុនពេលសង្គ្រាមជាមួយ ប៉ុល ពត យើងតែងបានឮរឿងនិទានចាស់មួយនិយាយតៗគ្នាដូចតទៅ÷

កាលសម័យអតីតកាលកន្លងយូរអង្វែងមកហើយមានព្រះមហាក្សត្រមួយព្រះអង្គសោយរាជ្យនៅនគរពារាណសី មានព្រះនាមល្បីល្បាញអស្ចារ្យដូចរន្ទះបាញ់ចេញពីទិសទាំងប្រាំបីស្របគ្នា ។ ក្នុងរាជ្យរបស់ព្រះអង្គដែលមានរយៈកាល៨០ឆ្នាំ ព្រះមហាក្សត្រអង្គនេះបានបណ្ដុះបណ្ដាលរាស្ត្ររបស់ព្រះអង្គឲ្យមានកម្លាំងបរិបូណ៌សម្រាប់ធ្វើចម្បាំងវាតត្បាតពង្រីកទឹកដីរបស់ព្រះអង្គ ព្រមទាំងស្ថាបនាក្រុមកំផែង មហាប្រាសាទ មហាព្រះរាជវាំងធំស្កឹមស្កៃ ពាសពេញផែនដី ។

លុះព្រះអង្គទ្រង់សោយទិវង្គតទៅ ចៅរបស់ព្រះអង្គក៏ត្រូវបានឡើងសោយរាជ្យបន្ត ។ តែលុះបានទតឃើញថារាជសមិទ្ធិព្រះអយ្យកោរបស់ព្រះអង្គមានសភាពធំស្កឹមស្កៃពេក ដូច្នេះព្រះរាជកុមារព្រះមហាក្សត្រថ្មីទាល់ព្រះតម្រិះសញ្ជប់សញ្ជឹងលើព្រះរាជបល្ល័ង្កមិនដឹងធ្វើដូចម្ដេចតទៅទៀតដើម្បីឲ្យសម្រេចសមិទ្ធផលលើសព្រះអយ្យកោដែលបានកើតមានសម្បើមស្កឹមស្កៃមកហើយ ។

ព្រះមហាក្សត្រថ្មីអង្គនេះក៏មានព្រះបន្ទូលទៅឧបរាជរបស់ព្រះអង្គឲ្យកោះនិមន្តតាឥសីម្នាក់នៅក្នុងព្រៃហេមពាន្តដែលមានព្រះនាមល្បីខ្ទរខ្ទារដើម្បីទស្សន៍ទាយថ្វាយព្រះអង្គថាតើព្រះអង្គត្រូវកសាងវត្ថុអ្វីដើម្បីធ្វើឲ្យព្រះរាជកិត្តិនាមរបស់ព្រះអង្គល្បីល្បាញខ្ទរខ្ទារលើសពីព្រះកិត្តិនាមរបស់ព្រះអយ្យកោព្រះអង្គ ។



ក្រោយពីបានរញ៉ីរញ៉ៃសញ្ជប់សញ្ជឹងវាយលេខចុះឡើងអស់ចំនួនប្រាំពីរថ្ងៃរួចមក លោកតាឥសីលុតជង្គង់ក្រាបទូលព្រះមហាក្សត្រថ្មីនេះវិញថា ដើម្បីបំពេញព្រះរាជមហិច្ឆតាដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ជ្រោងកិត្តិនាមឲ្យអណ្តែតផុតព្រះកិត្តិនាមព្រះអយ្យកោរបស់ព្រះអង្គទៀតនោះ ព្រះអង្គជាព្រះមហាក្សត្រថ្មីត្រូវឈប់កសាងសមិទ្ធិអ្វីៗទាំងអស់ ហើយងាកទៅកេណ្ឌទ័ពទាំងក្នុងប្រទេសនិងក្រៅប្រទេសវាយកម្ទេចសមិទ្ធផលទាំងប៉ុន្មានដែលព្រះរាជអយ្យកោរបស់ព្រះអង្គបានកសាងមកហើយឲ្យខ្ទេចខ្ទីទៅជាផេះ ។

ដូច្នេះហើយទើបនៅក្នុងរាជព្រះមហាក្សត្រថ្មីនេះ ព្រះអង្គបានកេណ្ឌពលជាច្រើនលាននាក់ទាំងក្នុងប្រទេសទាំងក្រៅប្រទេសវាយកម្ទេចគាស់ផុតមហាកំផែង មហាប្រាសាទ ព្រះរាជវាំង កុដិវត្តអារាម សាលារៀន សារមន្ទីរជាតិ ព្រមទាំងអ្វីៗឯទៀតទាំងអស់ដែលជាសមិទ្ធផលរបស់ព្រះរាជអយ្យកោរបស់ព្រះអង្គចោលឲ្យរលាយសាបសូន្យ ។ មហាប្រទេសព្រះអង្គត្រូវវិនាសខ្ទេចខ្ទីបាត់ឈ្មោះសូន្យឈឹងពីពិភពលោក ។ ចំណែកព្រះមហាក្សត្រអង្គនេះវិញ ព្រះអង្គត្រូវបានស្តេចមហាចក្រពត្តិគ្រប់ទិសទីនាហ្មឺន និងរាស្ត្រគ្រប់ប្រទេស បាក់បបខ្ចបខ្ចាច ។ លុះព្រះអង្គសោយទិវង្គតទៅ ព្រះរាជកិត្តិយសរបស់ព្រះអង្គក៏នៅតែល្បីល្បាញលើសព្រះនាមមហាក្សត្រឯទៀតទាំងអស់ថាជាព្រះអធិរាជមួយអង្គគត់ដែលមានឥទ្ធិពលដ៏មហិមាអាចបំផ្លាញមហានគរព្រះអង្គទាំងមូលឲ្យខ្ទេចខ្ទីទៅជាផេះដូចជាដកព្រះខ័នយកទៅឆូតមួយឆ្វាច់លើពួកខ្សាច់ដូច្នោះ ។

នេះគ្រាន់តែជារឿងនិទានចាស់មួយ ។ ប៉ុន្តែរឿងនិទាននេះបានផ្តល់នូវគតិជាក់ស្តែងមួយស្របគ្នានឹងបញ្ហាកម្ពុជាបច្ចុប្បន្នស្របគ្នានឹងមតិខ្លះដែលជំរុញថា ត្រូវរំលាយសារមន្ទីរទួលស្លែងដើងឯក ដុតបូជាធ្វើបុណ្យ, ស្របគ្នានឹងព្រឹត្តិការណ៍ខ្មែរក្រហមប៉ុលពត ។ ប្រហែលជាប៉ុលពតបានគិតគូរពីរឿង «ល្បីឈ្មោះ» នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០-៦០ដែរ ឬជាមួយនឹងឥសីដែលធ្លាប់ល្បីល្បាញជាអ្នកសច្ចៈមិនពុករលួយ មានក្បួនសេដ្ឋកិច្ចថ្នាក់បណ្ឌិតចាស់គំរិលជាប់ជាមួយខ្លួន ឈ្មោះ ខៀវ សំផន? ក្រុមប្រាសាទអង្គរវត្តបានកសាងឡើងនៅចន្លោះសតវត្សរ៍ទី៨ និងទី១១ ដោយទេពកោសល្យព្រះមហាក្សត្រខ្មែរជាច្រើនព្រះអង្គ ។ ព្រះមហាក្សត្រគ្រប់អង្គមានព្រះតម្រិះ វិធីកេណ្ឌប្រជាជនខ្មែរនិងឈ្លើយសង្គ្រាមបរទេសបានជាច្រើនលាននាក់ទៅជីកភ្នំ កាប់ព្រៃ កាត់ថ្ម កាយដី សាងប្រាសាទផង និងបើកយុទ្ធនាការធ្វើចម្បាំងដណ្តើមយកទឹកដី ទ្រព្យសម្បត្តិ ប្រជាជនពីប្រទេសជិតខាងមកប្រើប្រាស់ជាឈ្លើយចំណុះជួយកសាងអរិយធម៌យ៉ាងរុងរឿងរបស់ខ្មែរផង ។ តាំងពីពេលមនុស្សលោកបានចាប់ផ្តើមកសាងអរិយធម៌របស់ខ្លួនជាយូរលង់ណាស់មកហើយមនុស្សលោកទាំងអស់បានកសាងសំណង់ដែលចាត់ទុកថាជា«វត្ថុអស្ចារ្យ» បាន៧ក្នុងភពចាស់ និង៧ក្នុងភពថ្មី ។ យើងអាចរាប់ប្រាសាទអង្គរវត្តចូលក្នុងចំណោមវត្ថុអស្ចារ្យរបស់មនុស្សលោក ។ ក្រៅពីនេះវត្ថុអស្ចារ្យ៧ទៀតមានៈ ១) ប្រាសាទតាស្ហម៉ាហាល់ដែលអធិរាជឥណ្ឌាព្រះនាម ស្ហាស្ហជាហន បានសង់នៅប្រទេសឥណ្ឌាប៉ែកខាងជើងក្នុងឆ្នាំ១៨៣០ ដល់ឆ្នាំ១៨៤២ ធ្វើជាចេតិយសម្រាប់តម្កល់សពព្រះអគ្គមហេសីរបស់ព្រះអង្គ ។ ២) មហាកំផែងប៉ែកខាងជើងប្រទេសចិនដែលបានសង់ឡើងបន្តិចម្តងៗពីឆ្នាំ១៣៦៣ ដល់ឆ្នាំ១៦៤៤ ជាជញ្ជាំងសម្រាប់ការពារតទល់



នឹងការរាតត្បាតពីសត្រូវខាងក្រៅ ។ មហាកំផែងនេះមានកម្ពស់មធ្យម៧ម៉ែត្រ និងមានបណ្តោយប្រវែង ២,២៤០គីឡូម៉ែត្រ ។ ៣) រូបចម្លាក់ក្បាលមួយកម្ពស់៩ម៉ែត្រកន្លះ ឆ្លាក់លើថ្មភ្នំភ្លើងនៅលើកោះនាមហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូងដែលបានរកឃើញក្នុងឆ្នាំ១៧២២ ។ ៤) វិមានអែហ្វែលនៅក្រុងប៉ារីសប្រទេសបារាំង ដែលបានសង់ឡើងក្នុងឆ្នាំ១៨៨៩ សម្រាប់ធ្វើពិពណ៌នៅលើមាត់ទន្លេសែន មានកម្ពស់៣០០ម៉ែត្រ ហើយដែលជានិមិត្តរូបប្រទេសបារាំងសព្វថ្ងៃ ។ ៥) ព្រះវិហារសំណង់ភ្នំខ្លានិងព្រះរាជវាំងនៅប្រទេសហ្គាតេម៉ាឡានៅអាមេរិកខាងត្បូង សង់ឡើងចំនួន៣០០ឆ្នាំមុនគ្រិស្តសករាជ ។ ៦) «កប៉ាល់ហោះ» អវកាសរបស់អាមេរិកដែលចាប់បង្ហោះដំបូងបង្អស់ក្នុងឆ្នាំ១៩៨១ ជាយានសម្រាប់ធ្វើដំណើរទៅវិញទៅមកពីផែនដីទៅអវកាសជាយានសម្រាប់ផ្ទុកផ្កាយរណបយកទៅបង្ហោះនៅអវកាស ឬដឹកជញ្ជូនវិស្វករអវកាសពីរ-បីនាក់ទៅជួសជុលផ្កាយរណបដែលខូចនៅក្នុងអវកាសឲ្យដំណើរការឡើងវិញ ។ ៧) ព្រះវិហារស្តារត្រ៍ប្រទេសបារាំងសង់ឡើងក្នុងសតវត្សរ៍ទី១២ និង១៣នៅលើភ្នំតូចមួយ ។ ព្រះវិហារនេះមានកញ្ចក់ពណ៌ខៀវចំនួន១៧៣ ដែលបង្កើតជាពន្លឺខៀវស្រទំយ៉ាងអស្ចារ្យមួយគួរស្ញប់ស្ញែង ។

អរិយធម៌ខ្មែរក៏ត្រូវឡើងចុះដូចគ្នានឹងអរិយធម៌ធំៗឯទៀតនៅក្នុងលោកដែរ ។ ការធ្វើសង្គ្រាមទន្ទ្រានលុកលុយប្រទេសក្រៅផង ការធ្វើសង្គ្រាមការពារជាតិទប់ទល់នឹងការប៉ុនប៉ងរាតត្បាតពីក្រៅផង ការកេណ្ឌប្រជាជនដាក់ជាឈ្លើយឲ្យធ្វើការជាទម្ងន់ទាំងយប់ទាំងថ្ងៃផង ព្រមទាំងការរឹបអូសប្រមូលមាសប្រាក់សម្បត្តិទ្រព្យនានារបស់ប្រជាជនទៅទប់ទល់ក្នុងការចំណាយសង់ប្រាសាទសិលាយ៉ាងធំស្កឹមស្កៃផង ការឈ្លោះបែកបាក់គ្នាផ្ទៃក្នុងច្បាំងគ្នាឯងយកឈ្នះចាញ់ដល់ស្លាប់ ដណ្តើមអំណាច ដណ្តើមស្រី ដណ្តើមបល្ល័ង្កឥតឈប់ផង ដោយឥតមានគម្រោងការធ្វើសម្បទានជាបន្ទាស់អ្វីមួយសម្រាប់បន្ទូរនិងស្តារកម្លាំងជាតិក្រៅពីឈ្លក់ស៊ីប់ក្នុងកង្វល់ធ្វើសឹកយកឈ្នះ ធ្វើស្រែយកស្រូវ និងកសាងប្រាសាទស្កឹមស្កៃពីថ្មសិលាឥតឈប់រាប់សតវត្សរ៍ ទាំងអស់នេះបានធ្វើឲ្យកម្ពុជាហត់នឿយ រីងស្ងួតទាំងធនធានធម្មជាតិ ទាំងធនធានមនុស្ស ទាំងធនធានសេដ្ឋកិច្ច ទាំងធនធានគំនិតប្រាជ្ញាឈ្លាសវៃ ហើយបានធ្វើឲ្យកម្ពុជាបានបោះបង់ចោលទាំងអស់នូវអ្វីៗដែលធ្លាប់ជាជីវិតរស់រវើករបស់ជាតិខ្មែរសម័យមហានគរ ។ សត្រូវធំតូចពីខាងក្រៅក៏ចូលមកលុកលុយរាតត្បាតបំផ្លាញបានយ៉ាងងាយ បាននាំមកឲ្យខ្មែរនូវគំនិតចាញ់និយម ។ ទីបំផុតកម្ពុជាងាកក្រោយចាប់ពិចារណា កើតធម៌សង្វេគ ធម៌អនិច្ចា ធម៌សោកសៅ ចំពោះសមិទ្ធផលដែលខ្លួនបានរចនាកសាងមក ។ តាំងពីពេលនោះកម្ពុជាក៏បានធ្លាក់ទ្រុឌទ្រោមកប់ខ្លួនចុះលែងកម្រើក បែកបាក់គ្នារតាត់រតាយនៅក្នុងព្រៃជ្រៅនៅក្នុងសេចក្តីអស់សង្ឃឹមស្ងាត់ស្ងៀមអស់រយៈពេល៧០០ឆ្នាំ ។

ប្រាសាទអង្គរវត្តបានវិនាសពីសតិអារម្មណ៍ខ្មែរអស់ទៅហើយ នៅពេលដែលបារាំងរកឃើញប្រទេសកម្ពុជារួចហើយបានដាក់កម្ពុជានៅក្រោមការត្រួតត្រារបស់ខ្លួនក្នុងឆ្នាំ១៨៦៣ ។ ប្រជាជនខ្មែរសម័យមហានគរចំនួន២២លាននាក់ ត្រូវខ្មាំងដែលឈ្នះសង្គ្រាមសម្លាប់ចោលខ្លះ កៀងទៅធ្វើជាឈ្លើយ-ស្លាប់ក្នុងសង្គ្រាមខ្លះ និងក្លាយទៅជាប្រជាជនរបស់គេខ្លះ ។ នៅសល់តែខ្មែរ៨០ម៉ឺននាក់ដែលរក្សាដីទុកបានមួយក្រវេចតូចនៅមានឈ្មោះ



ថា «កម្ពុជា» រហូតមកដល់បច្ចុប្បន្នកាលនេះ ។

តែការរកឃើញប្រាសាទអង្គរវត្ត បានធ្វើឲ្យខ្មែរភ្ញាក់មមីមមើដឹងខ្លួនក្រោកឡើងសម្លឹងមើលវត្ថុតាងនៃអរិយធម៌ដែលដូនតាខ្លួនបានកសាង និងរំឭកដល់ដើមកំណើតរបស់ខ្លួនជាជាតិមួយធ្លាប់មានឫទ្ធិបុទ្ធិខ្លាំងក្លានៅទ្វីបអាស៊ី ។ សេចក្តីសង្ឃឹមក្នុងអាយុជីវិតជាតិ និងក្នុងការកសាងជាតិក៏បានកម្រើកកើតឡើង ។ បន្តិចម្តងៗ មួយរយឆ្នាំក្រោយ បារាំងបានដាក់កម្ពុជាក្រោមអាណាព្យាបាលរបស់គេប្រជាជនខ្មែរនៅក្នុងដីកម្ពុជាតូចដែលនៅសល់នេះបានកើនចំនួនបាន៧លាននាក់វិញ ហើយក៏បានរៀបចំស្ថាប័នរដ្ឋជាកម្ពុជាឯករាជ្យថ្មីមួយនៅអាស៊ីភាគអគ្នេយ៍ ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ខ្មែរពុំទាន់មានឱកាសសិក្សាពីចរិត ពីចរិយាជាតិ តាមប្រវត្តិសាស្ត្ររបស់ខ្លួនឡើយ ។ ខ្មែរបច្ចុប្បន្នពុំទាន់ដែលបានទទួលស្គាល់កំហុសខ្លួនឯងលើខ្មែរគ្នាឯង លើជាតិខ្លួនឯងណាមួយសោះ ។ បញ្ញវន្តខ្មែរបច្ចុប្បន្នច្រើនច្រឡំច្របូកច្របល់ទ្រឹស្តីនយោបាយបរទេសជាមួយឧត្តមគតិជាតិខ្មែរ ប្រយោជន៍បុគ្គលជាមួយប្រយោជន៍ជាតិ គោលបំណងឬសេចក្តីប្រាថ្នាជាមួយការជាក់ស្តែង ការស្រមើស្រមៃនិងការពិត ភាពខាងក្នុងនិងសម្បកក្រៅ ទំនៀមទម្លាប់ ឬជំនឿផ្តេសផ្តាសជាមួយសាសនាជាតិ ។ ខ្មែរបច្ចុប្បន្នពុំទាន់បានចាប់ភ្លឹកសោះថា នៅពេលខ្លះខ្មែរអាចធ្វើទារុណកម្មយ៉ាងឃោរឃៅលើខ្មែរគ្នាឯង ឬអាចសម្លាប់ខ្មែរគ្នាឯងចោលយ៉ាងរង្គាល ។ ដោយហេតុថាមានបរទេសជិតខាងបានដណ្តើមយកទឹកដីកម្ពុជាអស់ជាច្រើនភាគមកហើយ ខ្មែរបច្ចុប្បន្នតែងបញ្ចេះកំហឹងទម្លាក់កំហុសទាំងនោះទៅលើជាតិដទៃទៅវិញ ។

ដូច្នេះហើយ ខ្មែរបច្ចុប្បន្នតែងមានជំនឿលើការស្ងួតបូតទន់ភ្លន់ ស្រគត់ស្រគំ ញញឹមញញែម របស់ខ្មែរដែលគ្រាន់តែជាបាតុភាពក្រៅសើៗតែប៉ុណ្ណោះ ។ ក្រៅពីនេះខ្មែរបច្ចុប្បន្នក៏នៅតែស្មានខុសថា ភ័ក្ត្រញញឹមជាអមតៈនៅលើកំពូលប្រាសាទអង្គរវត្តទាំងឡាយជាភ័ក្ត្រញញឹមប្រិមប្រិយ ស្កប់ស្កល់ពេញចិត្តរបស់ប្រជាជនខ្មែរ ដោយភ្លេចគិតថាភ័ក្ត្រញញឹមនេះជាព្រះភ័ក្ត្ររបស់ព្រះព្រហ្ម ។ ដូច្នេះខ្មែរបច្ចុប្បន្នក៏បានភ្លេចចាប់ភ្លឹកសិក្សាឲ្យបានជ្រៅជ្រះហ្មត់ចត់នូវសិលាចារឹកតាមកំផែង និងតាមជញ្ជាំងប្រាសាទទាំងនោះ ដែលស្តីអំពីការពិតជាក់ស្តែងនៃជីវិតខ្មែរសម័យមហានគរ ។

ក្នុងពេលបច្ចុប្បន្នដ៏ខ្លីមួយភ្លែតនោះនៅពេលដែលខ្មែរដឹកនាំជាតិខ្លួនឯងជាជាតិឯករាជ្យ ខ្មែរបានភ្ញាក់ស្មៀតចាញ់បោកកលល្បិចពួក «ចោរហាវយ» ខ្មែរក្រហម បន្ទូរស្មារតីប្រុងប្រយ័ត្នបណ្តោយឲ្យខ្មែរក្រហមសម្លាប់ចោលយ៉ាងរង្គាលបានយ៉ាងស្រួលអស់ប្រជាពលរដ្ឋស្លូតត្រង់បីលាននាក់ ។ ទាំង ប៉ុល ពត ទាំង អៀង សារី ទាំង ខៀវ សំផន ទាំង នួន ជា ទាំង តាម៉ុក ទាំងប្រជាជនស្លូតត្រង់ សុទ្ធតែនៅនាំគ្នាញញឹមគ្មានឈប់ ។ យើងនាំគ្នាគិតប៉ុនប៉ងជុតបូជាទួលស្លែងចោល ហើយយើងនឹងទម្លាក់កំហុសទាំងនេះទៅលើជាតិដទៃណាមួយ ។ បន្តិចទៀតយើងនាំគ្នានិយាយដោយញញឹមញញែមថា «ឧបទ្ទវហេតុខ្មែរក្រហម» ជាការឧប្បត្តិកឡើងដោយជាតិដទៃណាមួយនោះឯងសម្រាប់បង្ខូចឈ្មោះ «បងសាឡុតស» និង «បងខៀវសំផន» ដែលជាវីរជនស្អាតស្អំ រារាំងកុំឲ្យវីរជនដ៏ប្រពៃនេះចូលរួមក្នុង «មហាសាមគ្គីបង្រួបបង្រួមជាតិ» បានឡើយ ។ (នៅមានត)



# តើអ្វីទៅជាខ្មែរក្រហម?

**ទស្សនៈទី១ៈ** ពេលដែលខ្ញុំនិយាយ «ខ្មែរក្រហម» ខ្ញុំចង់និយាយអំពី «អង្គការ» បង្កើតឡើងដោយ ប៉ុល ពត ហើយនិងជនទាំងឡាយដែលរួមចំណែកក្នុងអង្គការនោះ ។ ឥឡូវ ប៉ុល ពត ស្លាប់បាត់ទៅហើយ ហើយអង្គការរបស់ខ្លួនក៏ត្រូវធ្វើឲ្យលំរលាយ ឬអាចនិយាយបានថាត្រូវបានប្រែក្លាយឲ្យទៅជាអង្គការផ្សេងជាច្រើន ។ ខ្ញុំចង់និយាយថា ដូចជាអ្នកដឹកនាំនយោបាយ និងកូនទាហានដែលធ្លាប់ចូលរួមចំណែកនៅក្នុងអង្គការនោះជាពិសេស ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យរបស់ អៀង សារី និងប្រជាជនដែលរស់នៅអន្លង់វែង និងអ្នកដែលគាំទ្រពួកទាំងអស់នោះ ។ **ក្រេក អ៊ិចឆេសាន់**

◆◆◆

**ទស្សនៈទី២ៈ** ខ្ញុំព្យាយាមមិនប្រើពាក្យ «ខ្មែរក្រហម» ព្រោះពាក្យនេះមានន័យទូលំទូលាយពេកហើយជាពាក្យឥតប្រយោជន៍ ។ ខ្ញុំចូលចិត្តប្រើពាក្យថា «កម្ពុជាប្រជាធិបតេយ្យ» និងបក្សកុម្មុយនិស្តកម្ពុជា ។ ខ្ញុំគិតថា សមាជិកភាពរបស់បក្សគឺជាចំណុចសំខាន់សម្រាប់បែងចែកន័យនៃពាក្យនេះឲ្យមានបានច្បាស់ ។ ពាក្យ «ខ្មែរក្រហម» ធ្វើឲ្យមានការភ័ន្តច្រឡំជាមួយបញ្ហាផ្សេងៗទៀត ។ **ដេវីដ ឆេនដល័រ**

◆◆◆

**ទស្សនៈទី៣ៈ** ពាក្យថា «ខ្មែរក្រហម» ជាពាក្យដែលបង្កើតឡើងដោយ «សម្តេចសីហនុ» ។ នៅក្នុងសុន្ទរកថាមួយគួរឲ្យជក់ចិត្តនាពាក់កណ្តាលទសវត្សរ៍ឆ្នាំ៦០ ព្រះអង្គបានហៅខ្មែរកុម្មុយនិស្តនិងក្រុមឆ្វេងនិយមថាដែលជាពាក្យបារាំងប្រែមកថា «ខ្មែរក្រហម» ។ នៅពេលជាមួយគ្នានោះដែរព្រះអង្គបានហៅពួកដែលគាំទ្ររដ្ឋាភិបាលសហរដ្ឋអាមេរិកថាជា «ពួកខ្មែរខៀវ» ។ ប៉ុន្តែគួរឲ្យសោកស្តាយសារពត៌មានមួយ ពិសេសគឺសារពត៌មានអង់គ្លូសាក់សុងតែម្តង នៅតែប្រើពាក្យថា «ខ្មែរក្រហម» ។ ពាក្យនេះមិនមែនជាពាក្យត្រឹមត្រូវជាក់លាក់ឡើយសម្រាប់ហៅចលនាបក្សកុម្មុយនិស្តកម្ពុជា ហើយក៏មិនមែនពាក្យដែលសម្តេចសីហនុ ប្រើនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៦០ដែរ ។ ពេលដែលខ្ញុំស្ថិតនៅប្រទេសចិន ខ្ញុំតែងតែមានបញ្ហាទាំងជាមួយជនជាតិចិន ព្រមទាំងជាមួយពួកខ្មែរក្រហម នៅពេលដែលខ្ញុំប្រើពាក្យនេះ ។ ពួកខ្មែរក្រហមស្អប់ពាក្យនេះណាស់ ហើយតែងតែហៅខ្លួនឯងថា «កម្ពុជាប្រជាធិបតេយ្យ» ។ **ហ្វូលីយ៉ូ ហៀលជ្រេស**

◆◆◆

**ទស្សនៈទី៤ៈ** ពាក្យ «ខ្មែរក្រហម» បម្រើផលប្រយោជន៍ស្មើគ្នារវាងអ្វីដែល «ស» និងអ្វីដែល «ខ្មៅ» នៅក្នុងប្រវត្តិសាស្ត្រ ។ អាចថាវាមានពណ៌ប្រផេះ ។ វាក៏ជាពាក្យដែលស្រពិចស្រពិលរវាងការពិតនិងការក្លែងបន្លំដែរ ។ នៅក្នុងផ្លូវច្បាប់ពាក្យ «ខ្មែរក្រហម» មិនគួរត្រូវបានលើកយកមកប្រើប្រាស់ទេ ព្រោះដោយសារវាពុំបានធ្វើការកំណត់ជាផ្លូវការ និងពីភាពជាក់លាក់របស់វា ។ ពាក្យថា «របបកម្ពុជាប្រជាធិបតេយ្យ» ឬ «បក្សកុម្មុយនិស្តកម្ពុជា» ឬ «គណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា» គួរតែត្រូវបានយកមកប្រើប្រាស់ជំនួសឲ្យពាក្យ «ខ្មែរក្រហម» នៅក្នុងផ្លូវច្បាប់និងការពិភាក្សាជាផ្លូវការនានា ។ **ឆាំង យុ**

◆◆◆

**ទស្សនៈទី៥ៈ** ពាក្យថា «ខ្មែរក្រហម» គឺគ្មានន័យទាល់តែសោះ ហើយគួរតែចៀសវាងប្រើពាក្យនេះនៅពេលណាដែលអាចធ្វើទៅបាន ហើយគួរតែត្រូវបានជំនួសដោយពាក្យអ្វីដែលច្បាស់ហើយចំៗជាងនេះ ឧទាហរណ៍ពាក្យថា «សមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា» «យុទ្ធជន» «កម្មាភិបាល» បក្សនៃរបបកម្ពុជាប្រជាធិបតេយ្យជាដើម ។ល ។ ពាក្យនេះត្រូវបានបង្កើតឡើងដោយសម្តេចសីហនុ ដើម្បីហៅពួកឆ្វេងនិយមកម្ពុជា (និយាយឲ្យចំគឺពួកកុម្មុយនិស្ត) ដែលក្នុងគំនិតព្រះអង្គផ្ទាល់ក្រុមនេះមិនចុះញ៉មជាមួយវៀតណាមឡើយ ។ មានខ្មែរមួយក្រុមទៀតមានឈ្មោះថា «ខ្មែរវៀតមិញ» ក្រុមនេះប្រឆាំងនូវអ្វីដែលព្រះអង្គទ្រង់មានព្រះតម្រិះថាត្រឹមត្រូវ (ដូចជាអ្នកយោធានិយម អ្នកប្រជាធិបតេយ្យ ។ល ។) ។ ពាក្យ «ខ្មែរក្រហម» បានក្លាយជាពាក្យសម្រាប់សម្គាល់ការរំលោភបំពានដែលបង្ហាញពីសារជាតិប្រល័យពូជសាសន៍ ឬក៏យ៉ាងហោចណាស់ត្រឹមជាសារជាតិឃាតកម្មដែរ ។ ដូច្នេះពាក្យនេះក្រសោបនូវផ្ទាកសញ្ញានយោបាយដែលគ្មានភាពសុក្រិតគួរឲ្យគ្រោះថ្នាក់ ។ តុលាការមួយនឹងប្រហែលជាអាចរែករកមុខបានដឹងច្បាស់ថាតើអ្នកណាខ្លះជាឧក្រិដ្ឋជន

ប្រល័យពូជសាសន៍ហើយអ្នកណាមិនមែនជាឧក្រិដ្ឋជនប្រល័យពូជសាសន៍ ។

**ស៊ីវ ហេង់រ**

◆◆◆

ខ្ញុំយល់ថាពាក្យ «ខ្មែរក្រហម» ថាជាពាក្យកាត់ឲ្យខ្លីមួយ ដែលក្រសោបទៅលើព្រឹត្តិការណ៍ប្លែកៗគ្នានៅក្នុងរយៈពេលផ្សេងៗគ្នានៃប្រវត្តិសាស្ត្រកម្ពុជា ។

ក) ជាដំបូងនៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំយល់ថាពាក្យនេះត្រូវបានប្រើប្រាស់ជាដំបូងដោយសម្តេច សីហនុ ដើម្បីនិយាយសំដៅដល់ចលនាបដិវត្តន៍ «ក្រហម» ដែលប្រយុទ្ធប្រឆាំងនឹងព្រះអង្គ ។

ខ) នៅក្នុងសម័យ លន់ ណុល ពាក្យ «ខ្មែរក្រហម» សំដៅទៅលើកងកម្លាំងចលនាតស៊ូរួមបញ្ចូលទាំងសម្តេច សីហនុ រណសិរ្សបង្រួបបង្រួមជាតិនិងរដ្ឋាភិបាលរាជានិយមបង្រួបបង្រួមជាតិ ។

គ) នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពាក្យខ្មែរក្រហមនេះត្រូវបានប្រើប្រាស់សំដៅលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលកំពុងកាន់អំណាច ។

ឃ) ចាប់តាំងពីឆ្នាំ១៩៧៩ពាក្យខ្មែរក្រហមនេះត្រូវបានប្រើប្រាស់សំដៅទៅលើសមាសភាពនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ហើយបានបន្តការតស៊ូប្រឆាំងនឹងរដ្ឋាភិបាលថ្មីដែលបានវាយផ្តួលរំលំរដ្ឋាភិបាលរបស់ពួកខ្លួន ។ **ហេរ៉ឡេន ហ្វាទីស**

---

**(តមកពីទំព័រ៤៥)** តាមច្បាប់សាសនាត្រូវផ្តន្ទាទោសឧក្រិដ្ឋថ្នាក់ទីបី ។

**មាត្រា២៨១:** ដែលហៅថាបំពេញមុខងាររដោយរំលោភអំណាចនោះគឺបំផ្លាញដោយចេតនានូវសិទ្ធិរបស់បុគ្គលដទៃដែលគ្មានខុសអ្វីសោះគឺឲ្យខូចសិទ្ធិធ្វើនយោបាយ សិទ្ធិស៊ីវិល ឬសិទ្ធិគ្រួសារដែលសម្រាប់ទុកឲ្យពលរដ្ឋគ្រប់គ្នាពេញផ្ទៃព្រះរាជាណាចក្រ ឬឲ្យពលរដ្ឋខានប្រើប្រាស់សេរីភាពរបស់ខ្លួន ជាសិទ្ធិនិងសេរីភាពដែលពលរដ្ឋនឹងបាត់បង់ទៅវិញបានតែក្នុងករណីដែលច្បាប់បានសម្តែងយ៉ាងច្បាស់លាស់ណាស់ ។

**មាត្រា៧៧:** ជនណាមានបំណងនឹងប្រព្រឹត្តបទល្មើសជននោះត្រូវមានទោស ។ ដែលហៅថាបំណងគឺអំពើដែលមានលក្ខខណ្ឌពីរយ៉ាងដូចតទៅនេះ÷

១) ការចាប់ផ្តើមធ្វើនូវអំពើល្មើសណាមួយ

២) អំពើនោះមិនបានសម្រេចទៅវិញ ដោយសារមានកាលៈទេសៈអ្វីមួយមកបង្អាក់ឲ្យខានសម្រេចខុសពីឆន្ទៈនៃចារី ។

**មាត្រា៧៨:** ការរៀបចំបម្រុងនឹងប្រព្រឹត្តបទល្មើសមិនទាន់ទុកជាការចាប់ផ្តើមប្រព្រឹត្តបានទេ ។

**មាត្រា៧៩:** បំណងនឹងប្រព្រឹត្តបទឧក្រិដ្ឋណាមួយត្រូវទុកដូចជាបានប្រព្រឹត្តបទឧក្រិដ្ឋនោះដែរ ។

**មាត្រា៨០:** បំណងក្នុងបទមជ្ឈិមនឹងទុកដូចជាបានប្រព្រឹត្តបទមជ្ឈិមនោះបានលុះណាតែមានបទបញ្ញត្តិជាពិសេសនៃច្បាប់បានបញ្ជាក់ទៀតផងទើបបាន ។

**មាត្រា៨១:** បំណងក្នុងលហុកម្មមិនត្រូវធ្វើទោសទេ ។

**មាត្រា៨២:** ជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្មទោសកម្មណាមួយដោយផ្ទាល់ក្តី ដោយប្រយោលក្តី ជននោះត្រូវមានទោសដូចជាអាទិចារី ។ ការរួមប្រព្រឹត្តដោយផ្ទាល់ នោះទុកជាសហចារីឯការរួមប្រព្រឹត្តដោយប្រយោលទុកជាសមគំនិត ។

**មាត្រា៨៣:** ការរួមប្រព្រឹត្តដោយប្រយោល ឬដោយសមគំនិត នឹងអាចមានទោសបានក៏លុះណាតែអំពើនោះបានសម្រេចមកពីការនាំអាទិ៍ ការឲ្យអនុទ្ទេស ការផ្តល់មធ្យោបាយ ការជួយ ឬការទំនុកបម្រុង ។

ក៏ប៉ុន្តែច្បាប់ឆ្នាំ១៩៥៦មិនកំណត់ឲ្យច្បាស់នូវឧក្រិដ្ឋកម្មដូចជាឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬក៏ឧក្រិដ្ឋកម្មសង្រ្គាមឡើយ ។ ប៉ុន្តែច្បាប់នេះផ្តោតការយកចិត្តទុកដាក់ច្រើនជាងទៅលើត្រឹមតែឧក្រិដ្ឋកម្មក្នុងប្រទេសតែប៉ុណ្ណោះ ។

ដោយអនុលោមទៅតាមគោលការណ៍ «គ្មានច្បាប់ គ្មានបទឧក្រិដ្ឋ» ដើម្បីដាក់ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥-៧៩ តម្រូវឲ្យយកក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មកពិនិត្យដែលច្បាប់នេះនៅជាធរមាននៅពេលដែលរបបនេះឡើងកាន់អំណាចឆ្នាំ១៩៧៥ ។ ដើម្បីធ្វើឲ្យការយកមកអនុវត្តនូវក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានតម្លាភាព រដ្ឋសភាជាតិ ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ អាចអនុម័តច្បាប់ពិសេសមួយទទួលស្គាល់ការយកច្បាប់នេះមកអនុវត្តចំពោះឧក្រិដកម្មចន្លោះឆ្នាំ១៩៧៥-៧៩ ។ មាត្រា ឬវាក្យខណ្ឌណាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនាពេលបច្ចុប្បន្នដូចជា មាត្រាដែលចែងពីការដាក់ទោសប្រហារជីវិតចំពោះឧក្រិដ្ឋកម្មមួយចំនួននឹងបាត់សុពលភាព ។

**អាលីហ្សាប៉ែត វ៉ាន់ស្វាក់**

# សុបិនអាក្រក់នៅតែមិនទាន់រលត់

ក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរនាខែមេសា ឆ្នាំ១៩៧៥ ខ្ញុំជាក្មេងម្នាក់ដែលមានអាយុ១៣ឆ្នាំប៉ុណ្ណោះ ។ អាយុ១៣ឆ្នាំគឺជាអាយុមួយដែលច្រើនជ្រុលធ្វើឲ្យខ្ញុំមិនអាចបំភ្លេចបាននូវអ្វីដែលបានកើតឡើង និងតិចពេកមិនអាចឲ្យខ្ញុំទទួលបាននូវអ្វីដែលខ្ញុំជួបប្រទះនិងឆ្លងកាត់ក្នុងប្រវត្តិសាស្ត្រដ៏ជូរចត់នាពេលថ្មីៗនេះរបស់កម្ពុជា ។ ២៥ឆ្នាំគត់ក្រោយមក គឺក្នុងពិធីបុណ្យចូលឆ្នាំខ្មែរឆ្នាំ២០០០ ខ្ញុំបានអង្គុយនៅជាន់លើបំផុតនៃ «ផ្ទះសំណាក់ប្រជាប្រិយ» នៅម្តុំដែលខ្ញុំធ្លាប់រស់នៅកាលពីសង្គមចាស់ (មុនរបបខ្មែរក្រហម) ហើយរំឭកឡើងវិញនូវអនុស្សាវរីយ៍ចាស់ ។ ពីលើដំបូលអគារ ផ្ទះសំណាក់ប្រជាប្រិយនេះដែលស្ថិតនៅម្ខាងថ្នល់នៃស្ទឹងសៀមរាប និងទីតាំងផ្ទះចាស់របស់ខ្ញុំ ខ្ញុំគិតអំពីអ្វីដែលបានកើតឡើងចំពោះទឹកដីកំណើតជាទីស្រឡាញ់របស់ខ្ញុំប្រជាជនរបស់ខ្ញុំ គ្រួសាររបស់ខ្ញុំ និងខ្លួនខ្ញុំផ្ទាល់ ។ ខ្ញុំសន្មតថា ខ្ញុំកំពុងប៉ុនប៉ងស្វែងយល់ និងរកហេតុផលនៃព្រឹត្តិការណ៍ដ៏ខ្លោចផ្សាដែលបានកើតឡើងនៅទីនេះកាលពី២៥ឆ្នាំមុន ។ ២៥ឆ្នាំហាក់ដូចជារយៈពេលមួយយូរ ប៉ុន្តែសម្រាប់រូបខ្ញុំវាគ្រាន់តែជា «ថ្ងៃម្សិលមិញ» ប៉ុណ្ណោះ ។ ការចងចាំដែលពុំអាចបំភ្លេចបានអំពីថ្ងៃដែលបានកន្លងទៅគឺនៅថ្មីក្នុងអារម្មណ៍របស់ខ្ញុំនៅឡើយ ។ ឥឡូវនេះពិភពលោកបានដឹងជាទូទៅអំពីអ្វីដែលបានកើតឡើងចំពោះកម្ពុជាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ រឿងដែលគួរឲ្យកត់សម្គាល់បំផុតនោះគឺពិភពលោកបានដឹងអំពីរយៈកាលនៃការភ័យខ្លាចរបស់ខ្មែរក្រហម និងមរតកវាលពិឃាតរបស់របបនេះ ។ នេះជាសុបិនអាក្រក់ដែលខ្ញុំគួរតែបំភ្លេចចោលទាំងស្រុង ។ ជាអកុសល ខ្ញុំពុំអាចបំភ្លេចអតីតកាលដ៏គួរឲ្យភ័យខ្លាចក្នុងប្រវត្តិសាស្ត្រកម្ពុជា និងក្នុងឆាកជីវិតរបស់ខ្ញុំនេះបានឡើយ ។ ចង់មិនចង់សុបិនអាក្រក់នេះជាផ្នែកមួយនៃជីវិតរបស់ខ្ញុំ ។ ខ្មែរក្រហមមានមុខនៅលើទំព័រសារព័ត៌មានសាជាថ្មីម្តងទៀតបន្ទាប់ពី២៥ឆ្នាំបានកន្លងផុតទៅ ។ ប្រហែលយុត្តិធម៌ (ពុំមែនការសងសឹកទេ) សម្រាប់សមាជិកគ្រួសាររបស់ខ្ញុំ ដែលត្រូវបានសម្លាប់ និងការឈឺចាប់របស់ខ្លួនខ្ញុំផ្ទាល់ កំពុងតែខិតជិតមកដល់ខណៈដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការចរចាគ្នាដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតចុងក្រោយដែលជាក្រុមឃាតករសម្លាប់មនុស្សជាង៣លាននាក់ ។ ខ្ញុំនៅតែមានសង្ឃឹមចំពោះយុត្តិធម៌ ព្រោះខ្ញុំដឹងថាការសងសឹកគឺសាហាវខ្លាំងណាស់ ។ ខ្ញុំពុំច្បាស់ក្នុងខ្លួនសោះថាហេតុអ្វីបានខ្ញុំចង់មកកាន់ខេត្តសៀមរាបម្តងទៀតនៅពេលដ៏ជាក់លាក់នេះ ។ ប្រហែលជាខួបទី២៥ នៃការដួលរលំរបស់កម្ពុជាក្រោមដៃខ្មែរក្រហមដែលបណ្តាលចិត្តខ្ញុំឲ្យមកទីនេះក៏ថាបាន ។ ប្រហែលវាជាក្រុងបុរាណដ៏អស្ចារ្យដែលជាកន្លែងរស់នៅដ៏ល្អសម្រាប់ខ្ញុំកាលពីកុមារភាព ។ ប្រហែលជាស្នាមញញឹមប្រកបដោយភាពអំណត់របស់ប្រជាជនសាមញ្ញនៅសៀមរាបដែលធ្វើឲ្យខ្ញុំត្រឡប់មកទីនេះជាថ្មី ។ ប្រហែលជាខ្ញុំមកសៀមរាបដើម្បីគិតអំពីអនុស្សាវរីយ៍ល្អៗ និងអាក្រក់ទាំងឡាយនាយុវវ័យរបស់ខ្ញុំដើម្បីផ្សះផ្សា និងធ្វើឲ្យសះស្បើយ ។ ទោះជាដោយហេតុផលអ្វីក៏ដោយ ខ្ញុំដឹងថា ខ្ញុំត្រូវការត្រឡប់មកទឹកដីកំណើតរបស់ខ្ញុំ ។


ការដ្ឋានលើកទំនប់ក្នុងរបបខ្មែរក្រហម

បុណ្យចូលឆ្នាំខ្មែរ នាឆ្នាំ២០០០បានចាប់ផ្តើមនិងបញ្ចប់ទៅដោយភាពសប្បាយអធិកអធមយ៉ាងអស្ចារ្យ ។ ប្រជារាស្ត្រមកពីភូមិតូចធំក្នុងព្រះរាជាណាចក្រកម្ពុជា (និងទូទាំងពិភពលោក) បានមកចូលរួមក្នុងពិធីបុណ្យប្រចាំឆ្នាំដ៏ធំបំផុតនេះ ។ ល្បែងប្រជាប្រិយត្រូវបានលេងហើយហ្វូងមនុស្សបានចូលរួមអបអរទាំងយប់ទាំងថ្ងៃ ពេញទាំង៣ថ្ងៃ ដើម្បីស្វាគមន៍ទេវតាឆ្នាំថ្មី ។ ទិដ្ឋភាពពេលនោះគឺអស្ចារ្យណាស់គឺដូចជាអំឡុងពេលមួយនាអតីតកាលដែលខ្ញុំបានចងចាំ ។ វាជាទំនៀមទម្លាប់មួយដែលខ្មែរក្រហមបានព្យាយាមលុបបំបាត់ (និងបានបរាជ័យទាំងស្រុង) ពីផ្នត់គំនិតរបស់ប្រជាជនខ្មែរដ៏ក្លៀវក្លាទាំងនេះក្នុងសម័យកាលដ៏ឆ្កួតលីលារបស់ខ្លួន ។ប្រជាជនខ្មែរនៅដឹងថាតើត្រូវអបអរនិងរស់នៅយ៉ាងដូចម្តេចក្នុងពេលរីករាយក៏ដូចជាក្នុងពេលឈឺចាប់គឺពួកគាត់ពុំខ្វល់អំពីបញ្ហាខាងលើនេះឡើយ ។ ថ្ងៃ១៧ ខែមេសា ដែលជាខួបទី២៥នៃជ័យជម្នះរបស់ខ្មែរក្រហមបានមកដល់ភ្លាមៗបន្ទាប់ពីពិធីបុណ្យចូលឆ្នាំខ្មែរ ដោយពុំមានព្រឹត្តិការណ៍អ្វីធំដុំគួរឲ្យកត់សម្គាល់ឡើយ ។ ប្រជាជនខ្មែរឆ្អែតឆ្អន់នឹងពួកខ្មែរក្រហមគ្រប់គ្រាន់ហើយពួកគាត់ចង់បំភ្លេចរឿងខ្មែរក្រហមជាងទោះជាវានៅតែបន្តតាមលងពួកគាត់ក៏ដោយ ។ ខ្ញុំអង្គុយម្នាក់ឯងលើកៅអីវែងធ្វើពីស៊ីម៉ងត៍ ជាមួយភេសជ្ជៈដ៏ត្រជាក់ស្រេបរបស់ខ្ញុំ ហើយធ្វើការគិតពិចារណាអំពីអតីតកាល ។ ខ្ញុំបានសម្លឹងមើលទីតាំងផ្ទះចាស់របស់ខ្ញុំដែលស្ថិតនៅម្ខាងស្ទឹងសៀមរាប ដែលពេលនេះបានកាន់កាប់ដោយបងប្អូនសាច់ឆ្ងាយរបស់ខ្ញុំ ។ ទឹកភ្នែកពីរតំណក់បានហូរកាត់ថ្ពាល់ទាំងពីររបស់ខ្ញុំ ។ ទោះជាខ្ញុំព្យាយាមខ្លាំងយ៉ាងណាក៏ដោយ វាជាការលំបាកណាស់ក្នុងការទប់ទឹកភ្នែកកុំឲ្យហូរ ។ ការរំជួលញាប់ញ័រចិត្តជានិច្ចកាលឡើងដល់កម្រិតកំពូលគ្រប់ពេលដែលខ្ញុំមានវត្តមាននៅសៀមរាប ។ លើកនេះក៏ដូចលើកមុនៗដែរ ។



ទីតាំងផ្ទះចាស់របស់ខ្ញុំជាកន្លែងចុងក្រោយដែលអនុស្សាវរីយ៍ល្អៗក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរនាខែមេសា ឆ្នាំ១៩៧៥ នៅតែជិតជាប់ក្នុងអារម្មណ៍ដ៏រវើរវាយរបស់ខ្ញុំ ។ វាជាពេលមួយដែលសមាជិកគ្រួសាររបស់ខ្ញុំទាំងអស់ និងរូបខ្ញុំផ្ទាល់នៅធ្វើសកម្មភាពប្រចាំថ្ងៃជាធម្មតានៅឡើយ ។ ខ្ញុំចង់រំឭកឡើងវិញនូវអនុស្សាវរីយ៍មុនពេលដែលពួកខ្មាំងខ្មែរក្រហមក្នុងឯកសណ្ឋានខោខ្មៅ អាវខ្មៅ និងស្បែកជើងសង្រែកហូជីមិញ ដើរចូលសៀមរាបជាមួយនឹងកាំភ្លើងអាកា៤៧ និងបេ៤០របស់ខ្លួនក្នុងឆ្នាំ១៩៧៥ ។

ខ្ញុំត្រូវជីកកកាយយ៉ាងជ្រៅចូលទៅក្នុងប្រអប់នៃការចងចាំនៅក្នុងខួរក្បាលរបស់ខ្ញុំដែលត្រូវបានហែកហួរដើម្បីអាចត្រឡប់ទៅសម័យកាលនោះឲ្យទាន់ពេលវេលា ។ រំពេចនោះខ្ញុំបានត្រឡប់ទៅដល់ពិភពចាស់ដែលខ្ញុំបានចាកចេញយ៉ាងឆ្ងាយមកកសាងជីវិតថ្មីនៅអាមេរិក ។ តាមដែលខ្ញុំបានដឹង ខ្ញុំនៅតែជាខ្មែរម្នាក់ក្នុងជំនាន់ពោរពេញទៅដោយភាពវង្វេងវង្វាន់នាពេលនោះ ។ ហើយសុបិនអាក្រក់បណ្តាលមកពីពួកខ្មែរក្រហមនៅតែតាមលងក្នុងសុបិនរបស់ខ្ញុំនាពេលរាត្រី ។

សុបិនអាក្រក់ដ៏គួរឲ្យភ័យរន្ធត់បានកើតមានម្តងទៀតក្នុងដំណេកដ៏ស្កប់ស្កល់នារាត្រីថ្ងៃ១៧ មេសា ឆ្នាំ២០០០ ។ ខ្ញុំបានឃើញ ប៉ុល ពត និងមនុស្សពីរ-បីនាក់ផ្សេងទៀតយ៉ាងច្បាស់ក្នុងឯកសណ្ឋានពណ៌ខ្មៅដ៏ទុយ៌សរបស់ខ្លួនដើរមករកខ្ញុំ ។ ប៉ុល ពត មានកាំភ្លើងខ្លីធ្វើនៅអាមេរិកក្នុងដៃស្តាំរបស់ខ្លួន ។ ប៉ុល ពត ជាមេក្រុម ។ ប៉ុល ពត គ្រវីបង្វាញកាំភ្លើងជុំវិញ ប៉ុន្តែមិនដឹងជាយ៉ាងម៉េច ប៉ុល ពត ពុំប៉ុនប៉ងធ្វើការបាញ់ប្រហារ

ដូចដែលខ្ញុំរំពឹងទុកនោះទេ ។ ខ្ញុំពួនក្រោយដើមឈើមួយទៅតាមសភាវគតិដើម្បីបិទបាំងខ្លួនដោយសង្ឃឹមថាអាចចៀសផុតពីការដែលពួកនោះឃើញ ។ ជាអកុសលភ្នែករបស់ខ្ញុំបានប្រទះនឹងភ្នែក ប៉ុល ពត ហើយក៏សម្លឹងគ្នាជាប់ ។ ខ្ញុំពិតជាភ័យខ្លាំងណាស់ ។ ប៉ុល ពត មកកាន់តែជិតឡើងៗដោយបង្ហាញនូវភាពសង្កត់សង្កិន និងភាពក្រេវក្រោធរបស់ខ្លួន ។ ប៉ុល ពត បន្តគ្រវីកាំភ្លើងខ្លីតទៅទៀត មិនដឹងជាដោយហេតុផលអ្វីបានជា ប៉ុល ពត ពុំបាញ់ ។ «ចាប់ផ្ដើម! យកវាទៅ!» ប៉ុល ពត បានស្រែកយ៉ាងច្បាស់ដាក់ខ្ញុំបែបនេះក្នុងពេលដែលគាត់ដាក់កាំភ្លើងចុះ ។ ខ្ញុំពុំច្បាស់ថាត្រូវធ្វើអ្វីឡើយហើយរេរាមួយស្របក់ក៏សួរថា «តើអ្នកចង់បានអ្វីពីខ្ញុំ?» ប៉ុល ពត បានផ្ងៀងក្បាលមករកខ្ញុំហើយបញ្ជាថាៈ «ចាប់ផ្ដើមទៅ! បញ្ចប់ជីវិតខ្ញុំទៅ! យកការសងសឹករបស់អ្នកទៅ! សម្លាប់ខ្ញុំទៅ!» ។ ខ្ញុំបានចាប់ក្បាល ប៉ុល ពត ហើយបានព្យាយាមច្របាច់កគាត់ដោយដៃស្ដាំរបស់ខ្ញុំយ៉ាងពេញទំហឹង ។ ខ្ញុំបានត្រៀមខ្លួនជាស្រេចដើម្បីសម្លាប់ ប៉ុល ពត ដែលនៅរស់រានមានជីវិតយ៉ាងប្រាកដទោះជា ប៉ុល ពត ពុំមានសុខភាពល្អក៏ដោយ ។ ខ្ញុំអាចឮសម្លេងមនុស្សថប់ដង្ហើមជិតស្លាប់ ប៉ុន្តែស្នាមញញឹមនៅលើមុខរបស់ ប៉ុល ពត គឺអាក្រក់ណាស់ ។អាក្រក់បំផុតគឺស្នាមញញឹមរបស់មនុស្សជិតស្លាប់ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជា ប៉ុល ពត ចង់ឲ្យខ្ញុំសម្លាប់គាត់ខ្លាំងបែបនេះ ។ នៅពេលដែលខ្ញុំច្របាច់ក និងព្យាយាមសម្លាប់គាត់កាន់តែខ្លាំង ប៉ុល ពត ញញឹមមករកខ្ញុំដោយសេចក្ដីពេញចិត្តកាន់តែខ្លាំងដែរ ។ ប៉ុល ពត ចំអកដាក់ខ្ញុំ ។ វាហាក់ដូចជា ប៉ុល ពត កំពុងតែនិយាយមកកាន់ខ្ញុំថា «អ៊ូ! ល្អណាស់! សម្លាប់ទៅ! សម្លាប់ទៅ! សម្លាប់ឥឡូវនេះទៅ!» ។ ខ្ញុំបែរជាលែង ប៉ុល ពត ឲ្យផុតពីដៃមរណៈរបស់ខ្ញុំ ។ ខ្ញុំមិនចង់ធ្វើជាឃាតករសម្លាប់បុរសចំណាស់រូបនេះទេ ទោះជាមនុស្សនោះជា ប៉ុល ពត ជា ឃាតករសម្លាប់សមាជិកគ្រួសាររបស់ខ្ញុំនិងមនុស្សរាប់លាននាក់ផ្សេងទៀតក៏ដោយ ។ ខ្ញុំមិនចង់ធ្វើជាឃាតករឃោរឃៅដូច ប៉ុល ពត ទេ ។ ការសម្លាប់អ្នកដទៃពុំមែននៅក្នុងឈាមរបស់ខ្ញុំពីកំណើតឡើយ ។ ខ្ញុំពុំមែនជាពេជ្ឈឃាត ដូចដែល ប៉ុល ពត ធ្លាប់ធ្វើនោះទេ ទោះជាខ្ញុំស្អប់និងខ្លាចមេដឹកនាំខ្មែរក្រហមដ៏អាក្រក់នេះខ្លាំងយ៉ាងណាក្ដី ។ ប៉ុល ពត បានជជែកតវ៉ាជាមួយខ្ញុំយ៉ាងដូច្នេះថាៈ «អ្នកត្រូវតែសម្លាប់ខ្ញុំ! អ្នកត្រូវតែធ្វើបែបនេះ! អ្នកត្រូវតែសម្លាប់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចរួចផុតពីទោសកម្ម» ។

រំពេចនោះខ្ញុំយល់យ៉ាងច្បាស់ថាបន្ទាប់មក ប៉ុល ពត នឹងទៅជាយ៉ាងណា ។ គាត់ចង់ឲ្យខ្ញុំដែលជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងឡាយរបស់គាត់សម្លាប់គាត់ដើម្បីឲ្យគាត់អាចរួចពីខ្នះខ្លាញ់ដ៏ក្ដៅរាប់រយអង្សានៅឋាននរក ។ ប៉ុល ពត ត្រូវតែអនុញ្ញាតឲ្យជនរងគ្រោះរបស់ខ្លួនជាង៣លាននាក់ ធ្វើការសងសឹកមកលើខ្លួនដើម្បីឲ្យខ្លួនអាចរួចពីខ្នះខ្លាញ់ដ៏ក្ដៅរាប់រយអង្សារដែល ប៉ុល ពត កំពុងតែនៅក្នុងនោះ ។ ខ្ញុំបានប្រាប់ ប៉ុល ពត ដោយត្រង់ៗថាៈ «ទេ! ខ្ញុំមិនចង់ចុះនរកជាមួយអ្នកដោយការសម្លាប់អ្នកទេ ។ ខ្ញុំសូមបដិសេធមិនធ្វើការសងសឹកអ្នកឯងទេ» ។

ក្នុងសភាពដ៏គួរឲ្យអាណិត ប៉ុល ពត បានហុចកាំភ្លើងខ្លីរបស់គាត់ឲ្យខ្ញុំដោយអង្វរខ្ញុំថា «អ្នកឯងត្រូវតែធ្វើការសងសឹក ព្រោះអ្នកអាចជួយកុំឲ្យខ្ញុំឈឺចុកចាប់ជាងនេះ ។ សូមជួយខ្ញុំផង ខ្ញុំសូមអង្វរ ឯងគ្រាន់តែសម្លាប់ខ្ញុំប៉ុណ្ណោះទេ» ។

ខ្ញុំបានត្រឹមតែមិនអើពើចំពោះការអង្វរកដោយក្ដីសោកសៅសូមក្ដីមេត្តារបស់បុរសចំណាស់នេះ ហើយបែរមុខចេញពីបុរសចំណាស់ដែលពោរពេញដោយក្ដីទុក្ខព្រួយនេះតែប៉ុណ្ណោះ ។ នៅពេលដែលខ្ញុំក្រឡេកទៅរកសម្រែកដ៏ឈឺចាប់របស់ ប៉ុល ពត កាំភ្លើងខ្លីគាត់កំពុងតែរលាយនៅក្នុងដៃ ។ រូបរបស់ ប៉ុល ពត បានរលុបបាត់បន្តិចម្ដងៗ ប៉ុន្តែសម្រែកនៃការឈឺចាប់របស់ ប៉ុល ពត នៅតែបន្ត ។ ខ្ញុំពុំមានសេចក្ដីភ័យខ្លាចចំពោះមេដឹកនាំខ្មែរក្រហមដែលនៅពេលនោះពុំមានអ្វីលើសពីខ្លាក្រដាសមួយនោះទេ ។ ខ្ញុំមានជំនឿថា ប៉ុល ពត ដែលជាមនុស្សដ៏សាហាវយង់ឃ្នង និងជាសុបិនអាក្រក់របស់ខ្ញុំ កំពុងតែដុតរោលរាលក្នុងឋាននរកអវិចីដែល ប៉ុល ពត នឹងបន្តស្ថិតនៅទីនោះរយៈពេល៣លានជីវិតមនុស្ស ឬក៏អាចច្រើនជាងនេះទៅទៀត ។

ខ្ញុំបានភ្ញាក់ពីសុបិនដែលដូចជាការពិត និងដែលធ្វើឲ្យខ្ញុំបែកញើសនិងរំជួលចិត្តយ៉ាងខ្លាំងនេះ ។ ខ្នងរបស់ខ្ញុំផ្អែកទៅនឹងជញ្ជាំង ។ ខ្ញុំនៅតែមិនទាន់បាត់ខ្លាច ។ វាច្បាស់មែនទែន ។ ខ្ញុំនៅចាំគ្រប់សេចក្ដីលម្អិតទាំងឡាយគឺហាក់ដូចជាសុបិនអាក្រក់នេះកំពុងតែកើតមានឡើងក្នុងជីវិតពិតជាក់ស្ដែងដូច្នោះដែរ ។ ម៉ោង២ទៀបភ្លឺទៅហើយ ។ ចាប់ពីពេលនោះដល់រាត្រីបន្ទាប់

ខ្ញុំដេកពុំលក់សោះ ។

ខ្ញុំបានដឹងរឿងជាច្រើន ទាំងនេះគឺថា ប៉ុល ពត និង ខ្មែរក្រហមដែលបានស្លាប់បាត់បង់ជីវិតផ្សេងទៀត ឥឡូវនេះ កំពុងតែរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរក្នុងខ្ទះខ្ទាញ់ដ៏ក្តៅរាប់រយ អង្សារនាឋាននរកចំពោះការដែលខ្លួនបានបំផ្លាញជីវិតប្រជាជន ខ្មែរម្នាក់ក្នុងសម័យកាលដ៏ឈឺចាប់ខ្លោចផ្សារបស់ខ្លួន ។ ពួកនេះ នឹងស្ថិតនៅទីនោះរយៈពេលរាប់លានជីវិតមនុស្សទៀតគឺរយៈ ពេលជីវិតមនុស្សសម្រាប់ជីវិតមួយដែលពួកនេះបានសម្លាប់ ។ គិតដល់រឿងនេះខ្ញុំហាក់មានអារម្មណ៍ចង់សងសឹក ។ ពួកខ្មែរ ក្រហមពីរ-បីរយនាក់ទៀតនៅអាចមានពេលលុបលាងបាបកម្ម របស់ខ្លួនមុននឹងទៅកាន់ភពថ្មីទៀត ។ ពួកខ្មែរក្រហមទាំងនេះក៏ នៅមានពេលសម្រាប់អង្វរសូមក្តីប្រោសប្រណីនិងក្តីអត់ឱនពី សំណាក់ជនរងគ្រោះរបស់ខ្លួន ខណៈដែលពួកខ្លួននៅមានជីវិត រស់នៅលើផែនដីនេះ ។ ពួកខ្មែរក្រហមទាំងនេះត្រូវតែធ្វើកិច្ចការ នេះក្នុងពេលឥឡូវ ។ ព្រោះនៅពេលដែលខ្លួនឆ្លងទៅកាន់ភព ផ្សេង (ដូចជា ប៉ុល ពត, សុន សេន និង យុន យ៉ាត) ទោះបីជាអាចទៅរួចក៏លំបាកណាស់ដែរក្នុងការលុបលាងនូវបាប កម្មរបស់ខ្លួន ។ ឥឡូវជាពេលសម្រាប់ពួកខ្មែរក្រហមដែលនៅ រស់រានមានជីវិតធ្វើការកែលម្អនូវកំហុសឆ្គងដែលខ្លួនបានប្រព្រឹត្ត នាអតីតកាលឲ្យបានត្រឹមត្រូវឡើងវិញ ។ ចេញមុខប្រឈមនឹង ការពិតហើយអង្វរសូមក្តីអត់ឱនទោសពីប្រជាជនខ្មែរក្នុងពេល ឥឡូវ បែបនេះពួកខ្មែរក្រហមទាំងនេះនឹងមិនត្រូវដុតរោលរាល ក្នុងឋាននរកយូរដូច ប៉ុល ពត, សុន សេន, យុន យ៉ាត និងពីរ-បីនាក់ផ្សេងទៀត ។ ពួកខ្មែរក្រហមដែលបានរៀបរាប់ ចុងក្រោយនេះកំពុងតែរងនូវការឈឺចាប់នៅក្នុងខ្ទះខ្ទាញ់ដ៏សែន ក្តៅពុំអាចទ្រាំបាននាឋាននរកចំពោះអំពើដ៏អាក្រក់របស់ខ្លួននា អតីតកាល ។ ពួកទាំងអស់នេះត្រូវតែសងចំពោះទង្វើរបស់ខ្លួន ក្នុងពេលនេះ ឬពេលបន្ទាប់ ។

រូបខ្ញុំផ្ទាល់រឹតតែមិនច្បាស់ទៅទៀតថាតើខ្មែរក្រហមដែល នៅរស់រានមានជីវិតទាំងនេះដែលដៃរបស់ខ្លួននៅតែប្រឡាក់ ឈាមប្រជាជនស្លូតត្រង់នៅឡើយអាចរស់នៅបានបន្ទាប់ពីដឹង យ៉ាងច្បាស់ថា អ្វីដែលខ្លួនបានធ្វើគឺអាក្រក់សុទ្ធសាធខុសធ្ងន់ធ្ងរ ហើយអមនុស្សធម៌បែបនេះនោះ ។ ក្រុមជនកំសាកទាំងនេះមិន ត្រូវលាក់ខ្លួនពួនអាត្មាពីក្រោយ «ការផ្សះផ្សាជាតិ» ទៀតទេ ។ ពួកនេះត្រូវតែចេញមកប្រឈមមុខនឹងការពិតឥឡូវនេះកុំឲ្យ ហួសពេលទាន់ ។ ប៉ុល ពត បានជួបការលំបាកហើយ ជនរង គ្រោះរបស់គាត់ពុំអាចរំដោះគាត់ចេញពីខ្ទះខ្ទាញ់ដែលមានកម្តៅ រាប់រយអង្សារយៈពេលរាប់លានជីវិតមនុស្សបានឡើយ ។ មាន តែពួកខ្មែរក្រហមដែលនៅរស់រានមានជីវិតទេដែលអាចរក្សា ព្រលឹងខ្លួន ឬជីវិតនៅលើផែនដីនេះបាន ។ ចេញមកប្រឈមជា មួយការពិតនិងអង្វរសូមក្តីត្រាប្រណីទោសពីប្រជាជនខ្មែរក្នុងពេល ឥឡូវនេះ! ប្រជាជនខ្មែរពុំអាចត្រាប្រណីទោសឲ្យពួកនេះបានទេ បើពួកនេះពុំទទួលស្គាល់ថាអ្វីដែលពួកខ្លួនបានធ្វើមកលើប្រជាជាតិ ខ្លួនគឺខុសធ្ងន់ណាស់ ។

**រ៉េនី យិមស៊ុត**

## គោរពជូនលោក ឆាំង យុ
## ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ប្រធានដែលបានឧបត្ថម្ភជាទស្សនាវដ្តីស្វែងរកការពិតគ្រប់លេខ ដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមដើម្បីចែកជូនអ្នកចូលរួមវេទិកា សាធារណៈជាបន្តបន្ទាប់កន្លងមកនេះ ។ ទស្សនាវដ្តីស្វែងរក ការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាកម្រងពត៌មាន មួយដែលឆ្លុះបញ្ចាំងនូវសកម្មភាពពិតជាក់ស្តែងក្នុងរបបកម្ពុជា ប្រជាធិបតេយ្យនិងជាទំព័រប្រវត្តិសាស្ត្រសម្រាប់ស្វែងរកភាព យុត្តិធម៌ក្នុងសង្គម និងទុកជាឯកសារសម្រាប់ការសិក្សាស្រាវ ជ្រាវ និងពិចារណាដល់អ្នកជំនាន់ក្រោយៗទៀត ។ ខ្ញុំសូម សម្តែងនូវការកោតសរសើរដោយស្មោះចំពោះលោកប្រធាន និងសហការីទាំងអស់ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំង កាយចិត្តគិតគូដល់ផលប្រយោជន៍ជាតិជាចម្បងព្រមទាំងជំរុញ ឲ្យដំណើរការចេញផ្សាយទស្សនាវដ្តីនេះបានជោគជ័យ ។ ជាថ្មី ម្តងទៀត ខ្ញុំសូមប្រសិទ្ធពរជ័យជូនលោកប្រធាន និងសហការី សូមជួបប្រទះតែសេចក្តីសុខចម្រើន ប្រាជ្ញាឈ្លាសវៃ បន្ត ការងារដើម្បីជាគុណប្រយោជន៍ដល់សង្គមជាតិទាំងមូលកុំបី ឃ្លៀងឃ្លាតឡើយ ។ សូមលោកប្រធានមេត្តាទទួលនូវការ ការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ ប្រធានស្តីទី

**ហៀង ខាស្នា**

# ...យើងខ្ញុំមិនភ្លេចភារកិច្ចក្នុងការស្វែងរកយុត្តិធម៌ សម្រាប់ប្រជាជនកម្ពុជាដែលទទួលរងវិនាសកម្មយ៉ាង ធ្ងន់ធ្ងរពីរបបប្រល័យពូជសាសន៍...។ ការប្រឹងប្រែងរក ចំណុចរួមរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអគ្គលេខាធិការ







# អង្គការសហប្រជាជាតិទើបបាន សម្រេចនាអាទិត្យកន្លងមក







# ហើយដំណើរការនីតិវិធី នៃផ្លូវច្បាប់នឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ។

*សុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន*

*ក្នុងឱកាសបើកកិច្ចប្រជុំ ស៊ីជី ប៉ារីស ថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០០០*

**ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ក្បាលជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល**

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 6, June 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia